ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្តីពី
# ការប្រឆាំងនឹងភេរវកម្ម
# និង
# សេចក្តីពន្យល់

ក្រសួងយុត្តិធម៌
២០០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

## អារម្ភកថារបស់

## ឯកឧត្តម អង្គ វង្សវឌ្ឍានា

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មនេះ ជាលទ្ធផលការងារអស់រយៈពេលប្រហែល ៣ ឆ្នាំ របស់ក្រសួងយុត្តិធម៌ ដែលរៀបចំឡើងដោយមានជំនួយបច្ចេកទេសពីក្រសួងអគ្គរដ្ឋអាជ្ញា នៃប្រទេសអូស្ត្រាលី។ យោងតាមការចាំបាច់ក្នុងការទប់ស្កាត់នូវបទល្មើសភេរវកម្ម ដែលអាចកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ និងនៅលើសកលលោកទាំងមូល រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែពង្រឹងច្បាប់ជាតិ និងចូលរួមឱ្យបានគ្រប់សកម្មភាពក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសភេរវកម្មដ៏សែនគ្រោះថ្នាក់ចំពោះមនុស្សជាតិនេះ ។ ដោយច្បាប់ប្រឆាំងនឹងភេរវកម្មដែលមានពីមុនមក មិនអាចទប់ស្កាត់នូវបទល្មើសភេរវកម្មដែលមានភាពទំនើបនាពេលបច្ចុប្បន្នបាន ទើបរាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីសំរេចលេខ ៧៥ សសរ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីរៀបចំច្បាប់ស្តីពីការប្រឆាំងភេរវកម្មថ្មី ដោយមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន និងតំណាងក្រសួងពាក់ព័ន្ធផ្សេងៗទៀតជាសមាជិក ។

ភេរវកម្មជាការគម្រាមកំហែងមួយយ៉ាងធំ ចំពោះសហគមន៍អន្តរជាតិទាំងមូល ក៏ដូចជាសម្រាប់ប្រជាជាតិនីមួយៗ ។ ចាប់តាំងពីការវាយប្រហារថ្ងៃទី ១១ កញ្ញា ២០០១ ទៅលើអគារពាណិជ្ជកម្ម នៅទីក្រុងញូវយកនៃសហរដ្ឋអាមេរិកមក ភេរវកម្មក្លាយជាបញ្ហាបច្ចុប្បន្នភាព និងជាការព្រួយបារម្ភដ៏ធំមួយរបស់ពិភពលោកសព្វថ្ងៃនេះ ហើយពីពេលនោះមក ជនស៊ីវិលក្លាយជាគោលដៅចំបងនៃវាយប្រហាររបស់អំពើភេរវកម្ម ។ ដូច្នេះ ជាការចាំបាច់ណាស់ដែលរដ្ឋនីមួយៗត្រូវចាត់វិធានការដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើនេះ ។ ក្នុងស្មារតីនេះ ព្រះរាជាណាចក្រកម្ពុជាយើងទើបតែបានអនុម័ត និងប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មនៅថ្ងៃទី ២០ កក្កដា ២០០៧ ថ្មីៗនេះ ។

ដើម្បីជាជំនួយស្មារតីក្នុងការស្វែងយល់អំពី អំពើដែលបង្កឱ្យមានការយកចិត្តទុកដាក់ និងការភ័យបារម្ភពីសំណាក់សហគមន៍អន្តរជាតិ ខ្ញុំសូមលើកអំពីសញ្ញាណ និងប្រវត្តិនៃពាក្យ "**ភេរវកម្ម**" ។ អ្នកទ្រឹស្តីបានព្យាយាមធ្វើការវែកញែក និងវិភាគភេរវកម្មទៅតាមខ្លឹមសារ ទម្រង់ និងប្រភេទរបស់វា

ដោយធ្វើការបែងចែកជាអាទិ៍ រវាងភេរវកម្ម និងការតស៊ូដែលធ្វើឡើងដើម្បីគោលដៅធម្មានុរូប, ភេរវកម្មបុគ្គល, ភេរវកម្មមានការចាត់តាំង, ភេរវកម្មរដ្ឋ និងភេរវកម្មសេដ្ឋកិច្ច ។

ជាទូទៅ **ភេរវកម្ម** សំដៅលើអំពើហឹង្សា (ឧបឃាត ឃាតកម្ម ការចាប់ជំរិត វិច្ឆេទកម្ម...) ដែលប្រព្រឹត្តឡើងប្រឆាំងនឹងមហាជន ធ្វើយ៉ាងណាឱ្យមានឥទ្ធិពលផ្នែកចិត្តសាស្ត្រលើមហាជន (ភាពភ័យខ្លាចតក់ស្លុត...) គ្របដណ្តប់យ៉ាងទូលាយលើសពីជនរងគ្រោះផ្ទាល់ ដើម្បីឈានទៅវាយប្រហាលើមតិមហាជនពាក់ព័ន្ធ។

ពាក្យ "**ភេរវកម្ម**" ត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាលើកដំបូងនៅអឺរ៉ុប នៅខែ វិច្ឆិកា ឆ្នាំ ១៧៩៤ ដែលសំដៅលើលទ្ធិអនុវត្តដោយរបបភិតភ័យតក់ស្លុត (Régime de la Terreur) ដែលកាលពីសម័យមុន បានគ្រប់គ្រងអំណាចដោយធ្វើការប្រយុទ្ធប្រឆាំងយ៉ាងខ្លាំង និងជាលក្ខណៈហឹង្សាចំពោះអ្នកប្រឆាំងបដិវត្តន៍ ។ ដូច្នេះកាលនោះ "**ភេរវកម្ម**" សំដៅលើបែបបទមួយនៃការគ្រប់គ្រងអំណាច តែមិនមែនជាអំពើប្រឆាំងនឹងអំណាចរដ្ឋទេ ។ ពាក្យ "**ភេរវកម្ម**" បានវិវត្តនៅសតវត្សទី ១៩ ដើម្បីសំគាល់អំពើប្រឆាំងនឹងរដ្ឋ គឺមិនមែនអំពើរបស់រដ្ឋទៀតទេ ។ ពាក្យ "**ភេរវកម្ម**" ត្រូវបានប្រើប្រាស់ក្នុងន័យនៃអំពើប្រឆាំងនឹងរដ្ឋាភិបាលនៅឆ្នាំ ១៨៦៦ សម្រាប់ប្រទេសអៀរឡង់ដ៍ និងនៅឆ្នាំ ១៨៨៣ សម្រាប់ប្រទេសរុស្ស៊ី ។ បន្ទាប់មកទៀត ពាក្យ "**ភេរវកម្ម**" ត្រូវបានប្រើប្រាស់ក្នុងន័យអវិជ្ជមាន ហើយសព្វថ្ងៃ "**ភេរវកម្ម**" សំដៅលើអំពើហឹង្សាដែលមានគោលដៅបង្ករភាពតក់ស្លុត និងដើម្បីដាក់សំពាធទៅលើរដ្ឋមួយ ។ ជាទូទៅ អំពើហឹង្សានេះប្រឆាំងនឹងជនស៊ីវិល ដើម្បីបំផ្លាញ សម្លាប់ និងកាត់អវៈយវៈ។ អំពើវាយប្រហារនេះ មានបំណងជម្រុញ និងបង្ហាញសារដែលមានលក្ខណៈមនោគមវិជ្ជា នយោបាយ ឬសាសនា តាមរយៈភាពតក់ស្លុត និងប្រព័ន្ធឃោសនា ។

ន័យនៃពាក្យ "**ភេរវកម្ម**" ដែលប្រើសព្វថ្ងៃនេះ មានលក្ខណៈប្រហាក់ប្រហែលនឹងនិយមន័យកំណត់ក្នុងច្បាប់កម្ពុជា ចុះថ្ងៃទី ០៧ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ដែលកំណត់ក្នុងមាត្រា ១ ថា *"អំពើភេរវកម្ម ជាអំពើហឹង្សាទាំងឡាយ ដែលប្រព្រឹត្តដោយជន១នាក់ ឬជន១ក្រុម ឬច្រើនក្រុម បង្កើតភាពភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឱ្យជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងឱ្យប៉ះពាល់ដល់ស្ថេរភាពនយោបាយ "* ។ គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ គេពុំឃើញមាននិយមន័យឯកភាពគ្នាតែមួយនៃពាក្យ "**ភេរវករ**" ឬ "**ភេរវកម្ម**" នៅក្នុងច្បាប់អន្តរជាតិឡើយ។ ប៉ុន្តែ អនុសញ្ញា ពិធីសារ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងភេរវកម្ម បានផ្តល់នូវការណែនាំមួយចំនួនទាក់ទងនឹងការកំណត់អំពើភេរវកម្ម ។

ក្រៅពីការបាត់បង់នូវជីវិតមនុស្ស និងការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ការវាយប្រហាររបស់ភេរវករតែងបង្ករជានិច្ចកាលនូវការឈឺចាប់យ៉ាងខ្លាំង និងការខូចខាតខាងសម្ភារៈយ៉ាងធ្ងន់ធ្ងរ។ ប្រទេស

កម្ពុជាពិតមែនតែពុំទាន់ទទួលការវាយប្រហារដោយផ្ទាល់ដោយអំពើភេរវកម្មក៏ដោយ ក៏ត្រូវប្រឈមមុខនឹងការរីករាលដាល និងទម្រង់ថ្មីៗនៃអំពើភេរវកម្ម នៅលើឆាកអន្តរជាតិ ក៏ដូចជានៅក្នុងតំបន់ដែរ ។ ហេតុដូច្នេះហើយ ទើបព្រះរាជាណាចក្រកម្ពុជា ត្រូវមានក្របខណ្ឌគតិយុត្តិពេញលេញ ដើម្បីអាចធានាបាននូវការបង្ក្រាបដែលមានប្រសិទ្ធិភាព និងឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ និងទម្រង់ថ្មីៗនៃភេរវកម្ម ។

មុនការអនុម័ត និងប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មនៅថ្ងៃទី ២០ កក្កដា ឆ្នាំ ២០០៧ ប្រទេសកម្ពុជាយើងមានច្បាប់មួយចុះថ្ងៃទី ០៧ កុម្ភៈ ឆ្នាំ ១៩៩២ ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ដែលមានតែ ៤ មាត្រាប៉ុណ្ណោះ ។ វិសាលភាពអនុវត្តនៃច្បាប់នេះ គឺអនុវត្តលើភេរវកម្ម ការចាប់ជម្រិត និងបង្ខាំងមនុស្សខុសច្បាប់ ក្នុងគោលដៅធ្វើវិទ្ធង្សនកម្ម ទារយកប្រាក់ សងសឹក ធ្វើជាចំណាប់ខ្មាំង យកទៅលក់ និងជនណាដែលប្រព្រឹត្តអំពើភេរវកម្មផ្សេងៗទៀត ។ ទាក់ទងនឹងទណ្ឌកម្ម ច្បាប់នេះបានកំណត់ទណ្ឌកម្មដាក់ពន្ធនាគារពី ១០ ទៅ ២០ ឆ្នាំ ឬ អស់ ១ ជីវិត ក្នុងករណីមានស្ថានទម្ងន់ (ស្ថានទម្ងន់ ៣ យ៉ាងគឺ : អនីតិភាពនៃជនរងគ្រោះ, មរណៈភាពរបស់ជនរងគ្រោះ និងការគិតទុកជាមុន) ។ វិសាលភាពអនុវត្តនៃច្បាប់ឆ្នាំ ១៩៩២ នេះមានលក្ខណៈចង្អៀត ដោយសារនិយមន័យមានលក្ខណៈមិនគ្រប់គ្រាន់ និងមិនអាចក្តោបឱ្យបានពេញលេញនូវរាល់សកម្មភាពភេរវកម្មស្របតាមស្មារតីនៃនីតិអន្តរជាតិ ។

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មនៅថ្ងៃទី ២០ កក្កដា ឆ្នាំ ២០០៧ នេះ ត្រូវបានរៀបចំឡើងដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទប់ស្កាត់នូវអំពើភេរវកម្ម ដែលអាចគម្រាមកំហែងដល់សន្តិភាព ស្ថេរភាព សន្តិសុខ និងភាពរុងរឿង ខាងសេដ្ឋកិច្ចរបស់ខ្លួន ។ សក្តានុពលនៃអំពើភេរវកម្ម អាចកើតឡើងនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ហើយវាគឺជាប្រការសំខាន់ណាស់ដែលប្រទេសនីមួយៗត្រូវមានក្របខណ្ឌច្បាប់ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងស្ថានភាពបែបនេះ សំដៅការពារផលប្រយោជន៍ប្រជាពលរដ្ឋ និងផលប្រយោជន៍ជាតិរបស់ខ្លួន ។ ច្បាប់នេះអនុវត្តតាមអនុសញ្ញា និងពិធីសារទាំង ១៣ របស់អង្គការសហប្រជាជាតិ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខដែលពាក់ព័ន្ធនឹងភេរវកម្ម ដើម្បីបង្កើតជាក្របខណ្ឌគតិយុត្តពេញលេញមួយប្រឆាំងនឹងភេរវកម្មឱ្យមានប្រសិទ្ធិភាព ។ ច្បាប់នេះកំណត់បទល្មើសចាំបាច់ទាំងឡាយ និងចែងពីការបង្កក និងការរឹបអូសទ្រព្យ ក៏ដូចជាយន្តការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ (ជាអាទិ៍ បត្យាប័ន និងការជួយគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសភេរវកម្ម) ។

ថ្វីត្បិតតែព្រះរាជាណាចក្រកម្ពុជា បានកសាងក្របខណ្ឌច្បាប់គ្រប់គ្រាន់សម្រាប់ប្រយុទ្ធប្រឆាំងនឹងភេរវកម្ម តែយើងនៅមានភាពថ្មីថ្មោងចំពោះការងារអនុវត្តជាក់ស្តែងនៅឡើយ ។ ដូច្នេះ

ការស្វែងយល់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារ និងវិសាលភាពអនុវត្តនៃច្បាប់ប្រឆាំងនឹងភេរវកម្ម ព្រមទាំងការអប់រំបណ្តុះបណ្តាលដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ អំពីច្បាប់ និងបច្ចេកទេសទាក់ទងនឹងការបង្ការ និងបង្ក្រាបភេរវកម្ម ជាការងារបឋមដែលត្រូវធ្វើជាចាំបាច់ មុននឹងឈានដល់ការអនុវត្តដោយប្រសិទ្ធភាពនូវច្បាប់នេះ ។

ដោយយល់ឃើញអំពីតម្រូវការចាំបាច់នេះ ក្រសួងយុត្តិធម៌ បានសហការជាមួយ ក្រសួងអគ្គរដ្ឋអាជ្ញានៃប្រទេសអូស្ត្រាលីដែលជាអ្នកបានជួយយើងក្នុងការរៀបចំច្បាប់នេះ ដើម្បីធ្វើការពន្យល់អំពីខ្លឹមសារនៃច្បាប់នេះតាមមាត្រានីមួយៗ និងបោះពុម្ពចែកជូនដល់មន្ត្រីតុលាការ មន្ត្រីអនុវត្តច្បាប់ និងស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងសម្រួលដល់ការអនុវត្តភារកិច្ចរបស់ពួកគេ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលមានសេចក្តីពន្យល់គ្រប់មាត្រាទាំងអស់នេះ នឹងក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់មួយ សម្រាប់ការបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយច្បាប់ ក៏ដូចជាការចូលរួមចំណែកលើកកំពស់នូវការយល់ដឹងអំពីច្បាប់របស់សាធារណៈជន និងសិទ្ធិទទួលព័ត៌មានអំពីច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៨

អង្គ វង្សវឌ្ឍានា

នស/រកម/០៧០៧/០១៨

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ព្រមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្ដីពី

# ការប្រឆាំងនឹងភេរវកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
1/7

# មាតិកា


ជំពូកទី ១ បទប្បញ្ញត្តិទូទៅ....................................................................១

ជំពូកទី ២ យុត្តាធិការ..........................................................................៦

ជំពូកទី ៣ បទល្មើសដែលត្រូវបានប្រព្រឹត្តនៅលើអាកាសយាន ឬ នៅអាកាសយានដ្ឋាន...៨

ផ្នែកទី ១ ការបកស្រាយ..........................................................................៨

ផ្នែកទី ២ បទល្មើសនិងទោសប្បញ្ញត្តិ..............................................................១០

ផ្នែកទី ៣ សិទ្ធិអំណាចរបស់មេបញ្ជាការអាកាស...................................................១៣

ជំពូកទី ៤ បទឧក្រិដ្ឋលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ...................................១៧

ផ្នែកទី ១ ការបកស្រាយ..........................................................................១៧

ផ្នែកទី ២ បទល្មើស ...............................................................................១៨

ជំពូកទី ៥ ការចាប់ចំណាប់ខ្មាំង..................................................................១៩

ជំពូកទី ៦ ការការពាររូបវន្តលើសារធាតុនុយក្លេអ៊ែរ និងការបង្ក្រាបលើអំពើភេរវកម្មនុយក្លេអ៊ែរ..............................................................................................២០

ផ្នែកទី ១ សេចក្តីផ្តើម............................................................................២០

ផ្នែកទី ២ ការការពាររូបវន្តដែលចាំបាច់សម្រាប់សារធាតុនុយក្លេអ៊ែរ......២២

ផ្នែកទី ៣ បទល្មើសពាក់ព័ន្ធនឹងការការពាររូបវន្តនូវសារធាតុនុយក្លេអ៊ែរ...២៤

ផ្នែកទី ៤ ការគ្រប់គ្រងអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ......................២៦

ផ្នែកទី ៥ ការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ.............................................២៦

ជំពូកទី ៧ អំពើប្រឆាំងនឹងសុវត្ថិភាពនាវាចរណ៍ផ្លូវសមុទ្រ...........................២៧

ផ្នែកទី ១ ការអនុវត្ត..............................................................................២៧

ផ្នែកទី ២ បទល្មើស...............................................................................២៨

ផ្នែកទី ៣ សិទ្ធិអំណាចរបស់មេបញ្ជាការនាវា.............................................៣០


ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ជំពូកទី ៨ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចល័តដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រ......៣២

ផ្នែកទី ១ ការបកស្រាយ......៣២

ផ្នែកទី ២ បទល្មើស......៣២

ជំពូកទី ៩ ការដាក់សញ្ញាសម្គាល់គ្រឿងផ្ទុះប្លាស្ទិកសម្រាប់គោលបំណងរកឃើញ...៣៤

ផ្នែកទី ១ ការបកស្រាយ......៣៤

ផ្នែកទី ២ បទល្មើស......៣៦

ជំពូកទី ១០ ការដាក់គ្រាប់បែកភេរវកម្ម......៣៧

ផ្នែកទី ១ ការបកស្រាយ......៣៧

ផ្នែកទី ២ បទល្មើស......៣៨

ជំពូកទី ១១ ហិរញ្ញប្បទាន និងជំនួយសម្រាប់ភេរវកម្ម......៣៩

ផ្នែកទី ១ បទល្មើស......៣៩

ផ្នែកទី ២ ការបង្កក ការដកហូត និងការរឹបអូសទ្រព្យភេរវកម្ម......៤១

ជំពូកទី ១២ បត្យាប័ន និងជំនួយទៅវិញទៅមកទាក់ទងនឹងបទល្មើស......៤៧

ផ្នែកទី ១ សេចក្តីផ្តើម......៤៧

ផ្នែកទី ២ បត្យាប័ន......៤៨

ផ្នែកទី ៣ ជំនួយទៅវិញទៅមក......៥៤

ជំពូកទី ១៣ អវសានប្បញ្ញត្តិ......៥៩

ឧបសម្ព័ន្ធ ១......៦១

ឧបសម្ព័ន្ធ ២......៦៣

ឧបសម្ព័ន្ធ ៣......៦៦

ឧបសម្ព័ន្ធ ៤......៦៧

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

7/7/1

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.– គោលបំណង

១-គោលបំណងនៃច្បាប់នេះ គឺដើម្បីផ្តល់បទប្បញ្ញត្តិដាក់ទោសឧក្រិដ្ឋចំពោះការប្រព្រឹត្ត តាមការកំណត់ដោយ :

ក-អនុសញ្ញាប្រឆាំងនឹងភេរវកម្មទាំង ១៣ របស់អង្គការសហប្រជាជាតិ និងពិធីសារទាំងឡាយដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ១ នៃច្បាប់នេះ និង

ខ-សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងភេរវកម្ម ដូចជាសេចក្តីសម្រេចលេខ ១២៦៧ លេខ ១៣៧៣ និងលេខ ១៥៤០ និង

គ-អនុសាសន៍ទាំង ៤០ និងអនុសាសន៍ពិសេសទាំង ៩ របស់ក្រុមការងារហិរញ្ញវត្ថុស្តីពីការសម្អាតប្រាក់ ។

២-ក្នុងកម្រិតមួយដែលច្បាប់នេះមិនមានចែង ចំពោះបញ្ហាទាំងឡាយដែលចាំបាច់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ដទៃទៀត រួមទាំងច្បាប់ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវយកមកអនុវត្ត ។

៣-លើសពីនេះ ច្បាប់នេះផ្តល់យន្តការតាមការកំណត់របស់អនុសញ្ញា ពិធីសារ សេចក្តីសម្រេច និងអនុសាសន៍ទាំងនេះសម្រាប់ :

ក-កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការប្រឆាំងនឹងភេរវកម្ម ដូចជាបត្យាប័ន និងជំនួយទៅវិញទៅមក និង

ខ-ការឃាត់ទុកទ្រព្យរបស់អង្គការ និងបុគ្គលដែលមានឈ្មោះក្នុងបញ្ជីរបស់គណៈកម្មាធិការដែលត្រូវបានបង្កើតឡើង ក្រោមសេចក្តីសម្រេចលេខ ១២៦៧ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និង

គ-ការដកហូតទ្រព្យកខ្វក់ និងទ្រព្យរបស់ភេរវករ និងអង្គភាព ដែលជាកម្មសិទ្ធិរបស់ ឬដែលត្រូវបានគ្រប់គ្រងដោយភេរវករ ។

**មាត្រា ២.- ការបកស្រាយ**

ភាពស្រពិចស្រពិលណាមួយ ក្នុងការបកស្រាយច្បាប់នេះ នឹងត្រូវបានដោះស្រាយ ដោយឯកសារយោងនៃអនុសញ្ញា និងពិធីសារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃ មាត្រា ១ ខាងលើនេះ ។

**មាត្រា ៣.- និយមន័យ**

វាក្យស័ព្ទបច្ចេកទេសក្នុងច្បាប់នេះ មានន័យដូចតទៅ :

១-អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងមុខងារ មានន័យថា ជាបុគ្គលមួយរូប ឬ ស្ថាប័នមួយដែលអនុវត្តដោយស្របច្បាប់នូវមុខងារនោះនៅក្នុងរដ្ឋ ។

២-បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសពាក់ព័ន្ធនឹងបទល្មើសតាម បញ្ញត្តិនៃច្បាប់នេះ មានន័យថា ជាបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលរួមមានអំពើ ឬ ការគេចវេះ ដែលអំពើឬការគេចវេះខ្លះ ឬ ទាំងអស់នោះ ប្រសិនបើប្រព្រឹត្តនៅក្នុងព្រះ-រាជាណាចក្រកម្ពុជានឹងជាបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ ។

៣-បុគ្គល មានន័យថាជារូបវន្តបុគ្គល និងនីតិបុគ្គល ដែលមិនមែនជារដ្ឋ ។

៤-ទ្រព្យ មានន័យថា :

ក-ទ្រព្យសម្បត្តិ និងធនធានសេដ្ឋកិច្ចគ្រប់ប្រភេទទាំងអស់ ទាំងរូបី ឬ អរូបី ចលនវត្ថុ ឬ អចលនវត្ថុ ទោះជាបានមកតាមវិធីណាក្តី និង

ខ-ឯកសារនិងឧបករណ៍ច្បាប់ ទោះជាក្នុងរូបភាពណាក្តី រាប់បញ្ចូល ទាំងអេឡិកត្រូនិក ឌីហ្ស៊ីតាល់ ដែលផ្តល់ភស្តុតាងកម្មសិទ្ធិចំពោះផលប្រយោជន៍លើទ្រព្យ សម្បត្តិនេះ ដែលរួមមានដូចជាឥណទានធនាគារ មូលប្បទានប័ត្រអ្នកដំណើរ អាណត្តិ ប្រេវេញ៉េ ភាគហ៊ុន សញ្ញាប័ណ្ណ មូលប័ត្រ រូបិយាណត្តិ ឬលិខិតឥណទាន ។

៥-នាវា មានន័យថា ជានាវាគ្រប់ប្រភេទដែលមិនត្រូវបានភ្ជាប់ជាអចិន្ត្រៃយ៍ទៅ និង[illegible] រួមមាន :

ក-នាវាដែលមានការគាំទ្រប្រកបដោយថាមពល ។

ខ-នាវាដែលអាចមុជទឹកបាន ឬ

គ-នាវាដទៃទៀតណាដែលអណ្តែត ។

៦-បរិវេណរដ្ឋ ឬរដ្ឋាភិបាល មានន័យថា បរិវេណអចិន្ត្រៃយ៍ ឬ បណ្តោះអាសន្ន ឬ ក៏យានជំនិះទាំងឡាយណា ដែលត្រូវបានប្រើប្រាស់ ឬកាន់កាប់ ហើយដែលសម្រាប់កាតព្វកិច្ចផ្លូវការរបស់ខ្លួនដោយ :

ក-តំណាងរដ្ឋ ឬ

ខ-សមាជិករបស់រដ្ឋាភិបាល សភា ឬ តុលាការ ឬ

គ-មន្ត្រីរបស់រដ្ឋាភិបាល ឬ អាជ្ញាធរ ឬ អង្គភាពសាធារណៈដទៃទៀត ឬ

ឃ-និយោជិត ឬ មន្ត្រីរបស់អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ។

៧-ទ្រព្យកខ្វក់ មានន័យថាជាទ្រព្យដែល :

ក-បានត្រូវ ឬ កំពុងត្រូវបានប្រើ ឬ បម្រុងនឹងត្រូវបានប្រើក្នុងការប្រព្រឹត្តបទល្មើសមួយតាមបញ្ញត្តិនៃច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ-ជាគោលដៅនៃបទល្មើស ឬ

គ-ជាផលបានមកពី ឬ ទទួលដោយផ្ទាល់ ឬ ដោយប្រយោលតាមរយៈការប្រព្រឹត្តបទល្មើស ។

## មាត្រា ៤.- ការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

១-បុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះគឺ :

ក-មានកំហុសចំពោះបទល្មើសនោះ និង

ខ-ត្រូវទទួលទោសប្បញ្ញត្តិចំពោះបទល្មើសនោះ ។

២-ការប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ អាចផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌដូចខាងក្រោមនេះ ត្រូវបានបំពេញ :

ក-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស ។

ខ-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះដោយហេតុការណ៍នៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣-អំពើត្រៀមបម្រុង ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តបទល្មើសទេ ។

**មាត្រា ៥.- អ្នកផ្តើមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ**

១-ត្រូវចាត់ទុកថាជាអ្នកផ្តើមគំនិត បុគ្គលណាដែលចាត់ចែង បញ្ជា ឬ ញុះញង់ឱ្យបុគ្គលដទៃប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ ។

២-អ្នកផ្តើមគំនិត ត្រូវទទួលទោសចំពោះបទល្មើស ដែលគេចាត់ចែង បញ្ជា ឬ ញុះញង់ឱ្យបុគ្គលដទៃប្រព្រឹត្ត ទោះបីជាបទល្មើសនោះត្រូវបាន ឬ មិនបាន ឬ ប៉ុនប៉ងប្រព្រឹត្តក្តី ។

**មាត្រា ៦.- អ្នកសមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ**

១-ត្រូវចាត់ទុកថា ជាអ្នកសមគំនិត គឺបុគ្គលណាដែលជួយសម្រួលដល់ការប៉ុនប៉ង ឬការសម្រេចបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ដោយចេតនា ។

២-អ្នកសមគំនិតត្រូវទទួលទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៧.- បទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល**

១-ច្បាប់នេះអនុវត្តចំពោះនីតិបុគ្គល ដូចគ្នានឹងការអនុវត្តចំពោះរូបវន្តបុគ្គលដែរ ។

២-នីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសណាមួយប្រឆាំងនឹងច្បាប់នេះ រាប់បញ្ចូលទាំងបទល្មើស ដែលអាចដាក់ទណ្ឌកម្មជាប់ពន្ធនាគារផងដែរ ។

៣-ប្រសិនបើនិយោជិត ភ្នាក់ងារ ឬ បុគ្គលិករបស់នីតិបុគ្គល ដែលធ្វើសកម្មភាពនៅក្នុងក្របខណ្ឌនៃការងាររបស់ខ្លួន ឬ ដោយមានការអនុញ្ញាតពីនីតិបុគ្គលចូលរួមក្នុងសកម្ម-ភាព ដែលជាបទល្មើសប្រឆាំងនឹងច្បាប់នេះ ហើយសកម្មភាពនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងនីតិបុគ្គលនោះផងដែរ ។

៤-នីតិបុគ្គលប្រព្រឹត្តបទល្មើស ប្រឆាំងនឹងច្បាប់នេះដោយចេតនា ឬ ដោយដឹងខ្លួន ប្រសិនបើខ្លួនបានអនុញ្ញាត ឬ យល់ព្រមដោយផ្ទាល់ ឬ ដោយប្រយោល ចំពោះការប្រព្រឹត្តបទល្មើសនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៥-ប្រសិនបើនីតិបុគ្គល ត្រូវបានសម្រេចឱ្យជាប់ទោស ចំពោះបទល្មើសប្រឆាំងនឹងច្បាប់នេះ តុលាការត្រូវកំណត់ពិន័យជាប្រាក់ ជំនួសឱ្យរយៈពេលជាប់ពន្ធនាគារដោយអនុលោមតាមកថាខណ្ឌទី ៦ ខាងក្រោមនេះ ។

៦-ការពិន័យជាប្រាក់សម្រាប់នីតិបុគ្គលគឺ ២.០០០.០០០ (ពីរលាន) រៀលសម្រាប់រយៈពេលជាប់ពន្ធនាគារចំនួន ១២ ខែ ដែលតុលាការនឹងដាក់លើនីតិបុគ្គលនោះ ប្រសិនបើនីតិបុគ្គលនោះជារូបវន្តបុគ្គល ។

៧-បន្ថែមលើការពិន័យជាប្រាក់ តុលាការអាចដាក់ទោសបន្ថែមណាមួយ ដូចខាងក្រោមនេះ :

ក-ការរំលាយ ។

ខ-ការដាក់ឱ្យនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ ឬ ការត្រួតពិនិត្យរបស់ស្ថាប័នដទៃទៀត ។

គ-ការហាមឃាត់លើ :

គ.១-ការធ្វើពាណិជ្ជកម្មភាគហ៊ុននៅក្នុងនីតិបុគ្គល ឬ ការអំពាវនាវរកមូលនិធិតាមគ្រប់រូបភាព ឬ

គ.២-ការចេញឧបករណ៍អាចជួញដូរបានតាមរយៈធនាគារ ឬ

គ.៣-សកម្មភាពតាមការកំណត់ផ្សេងទៀត ។

ឃ-ការបិទគ្រឹះស្ថានដែលត្រូវបានប្រើ :

ឃ.១-ដើម្បីរៀបចំការប្រព្រឹត្តបទល្មើស ឬ

ឃ.២-ដើម្បីប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬ

ឃ.៣-ដើម្បីប្រព្រឹត្តបទល្មើស ។

ង-ការផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស របស់តុលាការតាមមធ្យោបាយណាមួយ ឬ ច្រើនរបស់ដូចខាងក្រោម :

ង.១-សារព័ត៌មាន ។

ង.២-ទូរទស្សន៍ ។

ង.៣-វិទ្យុ ។

ង.៤-អាំងទែរណែត ។

ច-ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

### មាត្រា ៨.- យុត្តិកម្ម

១-បុគ្គលណាដែលប្រព្រឹត្តបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ ក្នុងស្ថានភាពការពារជាធម្មានុរូប ឬ ដោយការអនុញ្ញាតដោយច្បាប់ មិនត្រូវចាត់ទុកថា បានប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ។

២-ទោះជាក្នុងកាលៈទេសៈណាក្តី មូលហេតុនយោបាយ ទស្សនវិជ្ជា មនោគមវិជ្ជា ពូជសាសន៍ ជាតិពន្ធ សាសនា ឬ មូលហេតុដូចគ្នាដទៃទៀត ពុំអាចយកមកធ្វើជាយុត្តិកម្មនៃបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះឡើយ ។

### មាត្រា ៩.- អាជ្ញាយុកាលនៃបទល្មើស

បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ មិនអាចផុតរលត់អាជ្ញាយុកាលឡើយ ។

## ជំពូកទី ២
## យុត្តាធិការ

### មាត្រា ១០.- យុត្តាធិការកម្ពុជាតាមបញ្ញត្តិនៃច្បាប់នេះ

ច្បាប់នេះត្រូវអនុវត្តក្នុងករណីណាមួយដូចខាងក្រោម :

ក-អំពើដែលជាបទល្មើសបានកើតឡើង :

ក.១-នៅក្នុងបូរណភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ

ក.២-លើនាវា ឬ អាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីនាវា ឬ អាកាសយាននោះស្ថិតនៅទីណាក៏ដោយ ឬ

ក.៣-លើនាវា ឬ អាកាសយានដែលប្រតិបត្តិការ ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬ

ក.៤-លើនាវាបរទេស ប្រសិនបើនាវានោះចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយមានជនល្មើសនៅក្នុងនាវានោះ ឬ

ក.៥-លើនាវាបរទេសដែលអាជ្ញាធរកម្ពុជា បានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់តាមសំណើពីរដ្ឋបរទេស ឬ

ក.៦-លើអាកាសយានបរទេស ប្រសិនបើអាកាសយាននោះចុះចតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានជនល្មើសនៅក្នុងអាកាសយាននោះ ឬ

ក.៧-លើអាកាសយានដែលត្រូវបានជួល ដោយគ្មានអាកាសយានិកឱ្យបុគ្គលណាមួយដែលមានទីតាំងអាជីវកម្មចម្បង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ក.៨-លើស្ថានទូត លំនៅស្ថានទូត ឬ កុងស៊ុល ឬ ទ្រព្យសម្បត្តិដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងរដ្ឋដទៃណាមួយ ។

ខ-បទល្មើសត្រូវបានប្រព្រឹត្ត :

ខ.១-ដោយពលរដ្ឋកម្ពុជា ទោះបីជាអំពើដែលជាបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុង ឬ ក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសក្តី ឬ

ខ.២-លើពលរដ្ឋកម្ពុជា ទោះបីជាអំពើដែលជាបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុង ឬក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសក្តី ឬ

ខ.៣-លើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ដែលមានឋានៈនេះដោយសារការអនុវត្តមុខងារ ជាតំណាងឱ្យព្រះរាជាណាចក្រកម្ពុជា ឬ

ខ.៤-ដោយបុគ្គលគ្មានសញ្ជាតិ ដែលមានលំនៅ ឬ ទីសំណាក់ជាប់លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាអំពើដែលជាបទល្មើសនោះ ត្រូវបានប្រព្រឹត្តនៅក្នុង ឬ ក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសក្តី ឬ

ខ.៥-ដោយមានគោលបំណងបង្ខំឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ទោះបីជាអំពើដែលជាបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្នុង ឬក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសក្តី ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

9/7/12

**មាត្រា ១១.- ការអនុវត្តច្បាប់នេះ ចំពោះអំពើភេរវកម្ម ដែលមានអ្នកចូលរួមប្រព្រឹត្តនៅក្នុង ព្រះរាជាណាចក្រកម្ពុជា**

១-ច្បាប់នេះត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូប ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើលក្ខខណ្ឌទាំងពីរ ដូចខាងក្រោមត្រូវបានបំពេញ :

ក-បុគ្គលនោះបានចូលរួមប្រព្រឹត្តអំពើនៅបរទេស និង

ខ-អំពើនោះជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ប្រសិនបើត្រូវបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-បុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើត្រូវតែ :

ក-ធ្វើបត្យាប័នទៅកាន់រដ្ឋណាមួយ ដែលមានយុត្តាធិការពាក់ព័ន្ធនឹងបទល្មើស ឬ

ខ-ចោទប្រកាន់ចំពោះបទល្មើសដោយយុត្តាធិការកម្ពុជា ។

៣-អំពើដែលត្រូវបានប្រព្រឹត្តនៅបរទេស ដែលជាបទល្មើសក្រោមច្បាប់របស់រដ្ឋធ្វើសំណើ ហើយដែលស្របគ្នានឹងបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាជាបទល្មើសដែលអាចធ្វើបត្យាប័ន ។ នៅពេលណាដែលបត្យាប័នមិនត្រូវបានធ្វើឡើង ជននោះនឹងត្រូវបានចោទប្រកាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបទល្មើសនោះ មិនត្រឹមតែត្រូវបានប្រព្រឹត្តនៅទីកន្លែងដែលវាបានកើតឡើងទេ គឺថែមទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។

## ជំពូកទី ៣

## បទល្មើសដែលត្រូវបានប្រព្រឹត្ត នៅលើអាកាសយាន ឬនៅអាកាសយានដ្ឋាន

### ផ្នែកទី ១

### ការបកស្រាយ

**មាត្រា ១២.- ពេលដែលអាកាសយានស្ថិតក្នុងការហោះហើរ**

១-នៅក្នុងច្បាប់នេះ អាកាសយានត្រូវបានចាត់ទុកថា ស្ថិតក្នុងការហោះហើរចាប់តាំងពីពេលដែលអាកាសយានចាប់ផ្តើមការហោះហើរ រហូតដល់បញ្ចប់ការហោះហើរ ។

២-អាកាសយានត្រូវបានចាត់ទុកថា បានចាប់ផ្តើមការហោះហើរ នៅពេលណាដែលទ្វារខាងក្រៅចុងក្រោយបំផុតរបស់អាកាសយានត្រូវបានបិទ ដើម្បីត្រៀមធ្វើចលនាដំបូងនៃអាកាសយាន សម្រាប់គោលបំណងចាប់ផ្តើមហោះហើរ ។

៣-ត្រូវចាត់ទុកថា អាកាសយានចាប់ផ្តើមការហោះហើរ ប្រសិនបើអាកាសយាននោះបានធ្វើចលនានៅមុនពេលដែលទ្វារខាងក្រៅត្រូវបានបិទ សម្រាប់គោលបំណងចាប់ផ្តើមការហោះហើរ ។

៤-ការហោះហើររបស់អាកាសយានត្រូវចាត់ទុកថា បានបញ្ចប់នៅពេលដែលទ្វារខាងក្រៅទីមួយត្រូវបានបើក ក្រោយពេលដែលអាកាសយានធ្វើការចុះចត ហើយឈប់ស្ងៀមបន្ទាប់ពីការចាប់ផ្តើមហោះហើរ លើកលែងករណីដូចមានបញ្ញត្តនៅក្នុងកថាខណ្ឌទី ៥ ទី ៦ និងទី ៧ នៃមាត្រានេះ ។

៥-ប្រសិនបើអាកាសយានធ្វើការចុះចតដោយបង្ខំ នោះការហោះហើររបស់អាកាស-យានត្រូវចាត់ទុកថា បានបញ្ចប់ នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ច បានកាន់កាប់ទទួលខុសត្រូវលើអាកាសយាន មនុស្ស និងទ្រព្យសម្បត្តិលើអាកាសយាននោះ ។

៦-ក្រោយពេលអាកាសយាន ចាប់ផ្តើមការហោះហើរ ប្រសិនបើអាកាសយានត្រូវបានកម្ទេច នៅមុនពេលដែលការហោះហើរ ត្រូវបានចាត់ទុកថាបញ្ចប់ តាមបញ្ញត្តិនៃកថា-ខណ្ឌទី ៤ ឬ ទី ៥ នៃមាត្រានេះ នោះការហោះហើររបស់អាកាសយានត្រូវចាត់ទុកថា បានបញ្ចប់នៅពេលដែលអាកាសយាននោះត្រូវបានកម្ទេច ។

៧-ក្រោយពេលអាកាសយាន ចាប់ផ្តើមការហោះហើរ ប្រសិនបើអាកាសយានត្រូវបានបោះបង់ចោល នៅមុនពេលដែលការហោះហើរ ត្រូវបានចាត់ទុកថា បញ្ចប់តាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ឬ ទី ៥ នៃមាត្រានេះ នោះការហោះហើររបស់អាកាសយានត្រូវចាត់ទុកថា បានបញ្ចប់នៅពេលណាដែលអាកាសយាននោះត្រូវបានបោះបង់ចោល ។

**មាត្រា ១៧.- ពេលអាកាសយានស្ថិតក្នុងសេវាកម្ម**

ត្រូវបានចាត់ទុកថា អាកាសយានស្ថិតក្នុងសេវាកម្ម នៅពេលដែលចាប់ផ្តើមការរៀបចំអាកាសយាន ដោយបុគ្គលិកលើដី ឬ ដោយក្រុមអាកាសយានិក មុនពេលចាប់ផ្តើមការហោះហើរ និងបញ្ចប់ក្នុងអំឡុងពេល ២៤ ម៉ោង ក្រោយពីការចុះចតរបស់អាកាសយាន ។

២-ពេលអាកាសយានស្ថិតក្នុងសេវាកម្មរួមបញ្ចូលទាំងអំឡុងពេលដែលអាកាសយានស្ថិតនៅក្នុងការហោះហើរផងដែរ ។

**មាត្រា ១៤.– ការលើកលែងចំពោះការអនុវត្តជំពូកនេះ**

ជំពូកទី ៣ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តចំពោះអាកាសយាន ដែលត្រូវបានប្រើប្រាស់ក្នុងសេវាកម្មយោធា គយ ឬ នគរបាលឡើយ ។

## ផ្នែកទី ២

## បទល្មើស និងទោសប្បញ្ញត្តិ

**មាត្រា ១៥.– ការដណ្តើមកាន់កាប់អាកាសយាន**

១-បុគ្គលស្ថិតក្នុងអាកាសយាន ដែលស្ថិតនៅក្នុងការហោះហើរ បានដណ្តើមការកាន់កាប់អាកាសយាន ដោយប្រើហិង្សា ឬគំរាមនឹងប្រើហិង្សា ឬ ដោយវិធីផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ប្រសិនបើអំពើដណ្តើមកាន់កាប់ត្រូវបានប្រព្រឹត្ត ឬ ក្នុងពេលជាមួយ ឬ បន្ទាប់ពីការប្រើអំពើហិង្សាដែលបណ្តាលឱ្យមានមរណភាព ឬ របួសដល់មនុស្សផ្សេងទៀត ។

**មាត្រា ១៦.– ការប្រព្រឹត្តអំពើហិង្សាលើមនុស្ស នៅលើអាកាសយានស្ថិតក្នុងពេលហោះហើរ**

បុគ្គលណាប្រព្រឹត្តអំពើហិង្សាដោយចេតនា លើបុគ្គលណាមួយផ្សេងទៀតនៅលើអាកាសយានដែលស្ថិតក្នុងការហោះហើរ ហើយដែលសកម្មភាពនេះអាចនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពហោះហើររបស់អាកាសយាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១៧.– ការកម្ទេចអាកាសយានក្នុងសេវាកម្ម ឬ ការបង្កឱ្យខូចខាតអាកាសយានក្នុងសេវាកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលកម្ទេចអាកាសយាន ឬ ធ្វើឱ្យខូចខាតដោយចេតនាដល់អាកាសយានស្ថិតក្នុងសេវាកម្ម

12/9/

ប្រសិនបើការខូចខាតនោះ បណ្តាលឱ្យអាកាសយានមិនអាចហោះហើរបាន ឬ អាចនឹងបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពហោះហើររបស់អាកាសយាននៅពេលដែលនឹងធ្វើការហោះហើរ ។

**មាត្រា ១៨.– ការដាក់ ឬ បង្កឱ្យមានការដាក់ឧបករណ៍ ឬ សារធាតុលើអាកាសយានក្នុងសេវាកម្ម**

បុគ្គលណាដែលដាក់ ឬ បង្កឱ្យមានការដាក់ឧបករណ៍ ឬ សារធាតុក្នុងអាកាសយានស្ថិតក្នុងសេវាកម្មដោយចេតនា ហើយដោយដឹងថាឧបករណ៍ ឬ សារធាតុនេះ អាចកម្ទេចអាកាសយាន ឬ បណ្តាលឱ្យមានការខូចខាតដែលនឹងធ្វើឱ្យអាកាសយានមិនអាចហោះ-ហើរបាន ឬ បណ្តាលឱ្យមានការខូចខាត ដែលអាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលដែលនឹងធ្វើការហោះហើរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ១៩.– ការកម្ទេច ឬ ការធ្វើឱ្យខូចខាត ដល់មធ្យោបាយតម្រង់ទិសហោះហើរ**

១-បុគ្គលណា ដែលកម្ទេចមធ្យោបាយតម្រង់ទិសហោះហើរដោយចេតនា ដែលបម្រើសេវាកម្មតម្រង់ទិសហោះហើរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះជនណាដែលធ្វើឱ្យខូចខាតដោយចេតនាដល់មធ្យោបាយតម្រង់ទិសហោះហើរ ឬ បង្អាក់ប្រតិបត្តិ-ការនៃមធ្យោបាយតម្រង់ទិសហោះហើរ ដែលបម្រើសេវាកម្មតម្រង់ទិសហោះហើរ ប្រសិនបើអំពើនេះអាចនាំឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អាកាសយានកំពុងហោះហើរ ។

**មាត្រា ២០.– ការផ្តល់ព័ត៌មានមិនពិត ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អាកាសយានក្នុងពេលហោះហើរ**

បុគ្គលណាដែលផ្តល់ដោយចេតនានូវព័ត៌មាន ដែលខ្លួនដឹងថាមិនពិត ហើយព័ត៌មាននេះធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អាកាសយានក្នុងពេលហោះហើរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## មាត្រា ២១.– ការប្រព្រឹត្តអំពើហិង្សានៅក្នុងអាកាសយានដ្ឋាន

១-បុគ្គលណាប្រព្រឹត្តអំពើហិង្សាលើមនុស្សដោយចេតនា ដោយប្រើសារធាតុ ឬវត្ថុណាមួយនៅក្នុងអាកាសយានដ្ឋាន ដែលបម្រើសេវាកម្មអាកាសចរណ៍ស៊ីវិល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើសកម្មភាពនោះ :

ក-អាចបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ ឬ អាចបណ្តាលឱ្យស្លាប់ និង

ខ-អាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ ដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន ឬ សុវត្ថិភាពរបស់មនុស្សនៅក្នុងអាកាសយានដ្ឋាន ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំក្នុងករណីដែលសកម្មភាពនោះ :

ក-បណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ និង

ខ-បណ្តាលឱ្យមានគ្រោះថ្នាក់ ដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន ឬ សុវត្ថិភាពរបស់មនុស្សនៅក្នុងអាកាសយានដ្ឋាន ។

៣-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីដែលសកម្មភាពនោះ

ក-បណ្តាលឱ្យមានមរណភាពនៃជនរងគ្រោះ និង

ខ-បណ្តាលឱ្យមានគ្រោះថ្នាក់ ដល់ប្រតិបត្តិការ ប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន ឬ សុវត្ថិភាពរបស់មនុស្ស នៅក្នុងអាកាសយានដ្ឋាន ។

## មាត្រា ២២.– ការកម្ទេច ការធ្វើឱ្យខូចខាតដល់សម្ភារៈបរិក្ខារនៃអាកាសយានដ្ឋាន អាកាស–យានមិនស្ថិតក្នុងសេវាកម្ម និងការបង្អាក់សេវាកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយដូចខាងក្រោម :

ក-កម្ទេច ឬ ធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់សម្ភារៈបរិក្ខារនៃអាកាសយានដ្ឋានដែលបម្រើសេវាកម្មអាកាសចរណ៍ស៊ីវិល ឬអាកាសយាន ដែលមិនស្ថិតក្នុងសេវាកម្ម និងដែលស្ថិតនៅក្នុងអាកាសយានដ្ឋានបម្រើសេវាកម្មអាកាសចរណ៍ស៊ីវិល ។

ខ-បង្អាក់សេវាកម្មរបស់អាកាសយានដ្ឋាន ដែលបម្រើសេវាកម្មអាកាសចរណ៍ស៊ីវិល ។

ប្រសិនបើការប្រព្រឹត្តិណាមួយដូចខាងលើនេះ បណ្ដាលឱ្យមានគ្រោះថ្នាក់ ឬ អាចនឹងបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន ឬ សុវត្ថិភាពរបស់មនុស្សក្នុងអាកាសយានដ្ឋាន ។

**មាត្រា ២៣.- បទល្មើសតាមបញ្ញត្តិនៃច្បាប់កម្ពុជាផ្សេងទៀតដែលត្រូវបានប្រព្រឹត្តលើអាកាសយាន**

បុគ្គលណាស្ថិតនៅលើអាកាសយានដែលបានធ្វើសកម្មភាពណាមួយ ឬ គេចវេះមិនធ្វើសកម្មភាពណាមួយ ហើយដែលសកម្មភាព ឬ ការគេចវេះទាំងនេះ ត្រូវបានច្បាប់កម្ពុជាក្រៅពីច្បាប់នេះ បញ្ញត្តិថាជាបទល្មើស ត្រូវផ្ដន្ទាទោសតាមបញ្ញត្តិច្បាប់សម្រាប់បទល្មើសដែលគេបានប្រព្រឹត្តនោះ ។

## ផ្នែកទី ៣

## សិទ្ធិអំណាចរបស់មេបញ្ជាការអាកាសយាន

**មាត្រា ២៤.- វិធានការដើម្បីការពារសុវត្ថិភាពនៅលើអាកាសយាន**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើមេបញ្ជាការអាកាសយានមានមូលហេតុសមស្របនឹងជឿថាមានបុគ្គលម្នាក់បានប្រព្រឹត្ត កំពុងប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តនៅលើអាកាសយាននូវ :

ក-បទល្មើសតាមបញ្ញត្តិនៃច្បាប់កម្ពុជា ឬ

ខ-អំពើណាមួយដែលធ្វើឱ្យមានគ្រោះថ្នាក់ ឬអាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់ :

ខ.១-សុវត្ថិភាពអាកាសយាន ឬ

ខ.២-សុវត្ថិភាពរបស់មនុស្សនៅលើអាកាសយាន ឬ

ខ.៣-សុវត្ថិភាពរបស់ទ្រព្យសម្បត្តិនៅលើអាកាសយាន ឬ

ខ.៤-សណ្ដាប់ធ្នាប់ និងវិន័យនៅលើអាកាសយាន ។

២-មេបញ្ជាការអាកាសយាន អាចចាត់វិធានការសមស្របណាមួយលើបុគ្គលដែលមានកំណត់ក្នុងកថាខណ្ឌទី ១ ដែលចាំបាច់ដើម្បី :

ក-ការពារសុវត្ថិភាពរបស់អាកាសយាន ឬ មនុស្ស ឬ ទ្រព្យសម្បត្តិនៅលើអាកាសយាន ឬ

ខ-រក្សាសណ្តាប់ធ្នាប់ និងវិន័យនៅលើអាកាសយាន ឬ

គ-អនុញ្ញាតឱ្យមេបញ្ជាការអាកាសយាន អាចប្រគល់ខ្លួនបុគ្គលនោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ ដាក់បុគ្គលនោះចុះពីលើអាកាសយានយោងតាមផ្នែកនេះ ។

៣-មេបញ្ជាការអាកាសយាន ដែលបានផ្តល់សិទ្ធិឱ្យចាប់ខ្លួន ឃាត់ខ្លួនបុគ្គលណាម្នាក់តាមបញ្ញត្តិនៃមាត្រានេះអាច :

ក-តម្រូវ ឬ ផ្តល់សិទ្ធិដល់សមាជិកក្រុមអាកាសយានិកដទៃទៀតឱ្យឃាត់ខ្លួនបុគ្គលនោះ ឬ

ខ-ស្នើសុំ ឬ ផ្តល់សិទ្ធិ ដល់អ្នកដំណើរឱ្យឃាត់ខ្លួនបុគ្គលនោះ ។

៤-សមាជិកក្រុមអាកាសយានិក ឬ អ្នកដំណើរ អាចចាត់វិធានការទប់ស្កាត់សមស្របដោយគ្មានការអនុញ្ញាត ប្រសិនបើមានហេតុផលសមស្របនឹងជឿថា វិធានការនោះមានលក្ខណៈចាំបាច់ជាបន្ទាន់ដើម្បី :

ក-ការពារសុវត្ថិភាពអាកាសយាន ឬ

ខ-ការពារសុវត្ថិភាពរបស់មនុស្ស ឬទ្រព្យសម្បត្តិនៅលើអាកាសយាន ។

**មាត្រា ២៥.- បុគ្គលដែលត្រូវបានឃាត់ខ្លួន**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានឃាត់ខ្លួន យោងតាមមាត្រា ២៤ ខាងលើនេះ ។

២-មេបញ្ជាការអាកាសយាន តាមការប្រញាប់ជាក់ស្តែង និងបើអាចធ្វើបានមុនពេលអាកាសយានចុះចត ត្រូវតែជូនដំណឹងដល់អាជ្ញាធរនៃទីកន្លែង ដែលអាកាសយាននឹងចុះចត អំពីបុគ្គលដែលត្រូវបានឃាត់ខ្លួននៅលើអាកាសយាន និងមូលហេតុដែលនាំឱ្យមានការឃាត់ខ្លួនបុគ្គលនោះ ។

៣-បុគ្គលដែលត្រូវបានឃាត់ខ្លួន អាចដាក់ឱ្យស្ថិតនៅក្រោមការឃាត់ខ្លួនបន្តបាននៅលើអាកាសយានដែលបានចុះចត តែនៅក្នុងស្ថានភាពដូចខាងក្រោម :

ក-បុគ្គលនោះត្រូវបានឃាត់ខ្លួន ដើម្បីមេបញ្ជាការអាកាសយានអាចប្រគល់

បុគ្គលនោះឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ

ខ-អាជ្ញាធរមានសមត្ថកិច្ចនៅទីកន្លែង ដែលអាកាសយានចុះចត បដិសេធទទួលយកបុគ្គលនោះចុះពីអាកាសយាន ឬ

គ-អាកាសយានធ្វើការចុះចតដោយបង្ខំ ហើយមេបញ្ជាការអាកាសយានមិនអាចប្រគល់បុគ្គលនោះ ឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬ

ឃ-បុគ្គលនោះយល់ព្រមឱ្យគេដាក់ខ្លួន នៅលើអាកាសយានជាបន្តទៀត ដោយស្ថិតនៅក្រោមការឃាត់ខ្លួន ។

**មាត្រា ២៦.- ការដាក់បុគ្គលណាម្នាក់ចុះពីអាកាសយាន**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើមេបញ្ជាការអាកាសយាន មានមូលហេតុសមស្របនឹងជឿថា មានបុគ្គលម្នាក់បានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តនៅលើអាកាសយាននូវអំពើណាមួយដែលធ្វើឱ្យមានគ្រោះថ្នាក់ ឬ អាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់ :

ក-សុវត្ថិភាពអាកាសយាន ឬ

ខ-សុវត្ថិភាពរបស់មនុស្សនៅលើអាកាសយាន ឬ

គ-សុវត្ថិភាពរបស់ទ្រព្យសម្បត្តិនៅលើអាកាសយាន ឬ

ឃ-សណ្តាប់ធ្នាប់ និងវិន័យនៅលើអាកាសយាន ។

២-មេបញ្ជាការអាកាសយានអាចដាក់បុគ្គលនោះ ចុះនៅក្នុងដែនដីនៃរដ្ឋណាមួយដែលអាកាសយាននោះចុះចត ។

៣-មេបញ្ជាការអាកាសយាន ត្រូវរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដែលខ្លួនបានដាក់បុគ្គលនោះចុះអំពីបុគ្គលដែលត្រូវបាន ឬ នឹងត្រូវដាក់ចុះ និងមូលហេតុនៃការដាក់ចុះនេះ ។

**មាត្រា ២៧.- បទល្មើសលើអាកាសយាន**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើមេបញ្ជាការអាកាសយានមានមូលហេតុសមស្របនឹងជឿថា មានបុគ្គលណាម្នាក់បានប្រព្រឹត្តនៅលើអាកាសយាននូវអំពើណាមួយ

ដែលមេបញ្ជាការអាកាសយានយល់ថា ជាបទល្មើសធ្ងន់ធ្ងរមួយ ប្រឆាំងនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-មេបញ្ជាការអាកាសយាន អាចប្រគល់បុគ្គលនោះឱ្យអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋអនុសញ្ញានៅក្នុងពេលអាកាសយានចុះចត ។

៣-មេបញ្ជាការអាកាសយាន តាមការប្រញាប់ជាក់ស្តែង និងបើអាចធ្វើបានមុនពេលអាកាសយានចុះចត ត្រូវតែជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ អំពីគោលបំណងរបស់ខ្លួនក្នុងការប្រគល់បុគ្គលនោះ និងមូលហេតុនៃការប្រគល់នេះ ។

៤-មេបញ្ជាការអាកាសយាន ត្រូវតែផ្តល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋនោះនូវភស្តុតាង និងព័ត៌មាននានា ដែលខ្លួនមានដោយស្របច្បាប់ ។

៥-ក្នុងមាត្រានេះ រដ្ឋអនុសញ្ញាមានន័យថា គឺជារដ្ឋមួយដែលជាភាគីនៃអនុសញ្ញាស្តីពីបទល្មើស និងសកម្មភាពដទៃទៀត ដែលត្រូវបានប្រព្រឹត្តលើអាកាសយានដែលធ្វើនៅទីក្រុងតូក្យូ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៦៣ ។

**មាត្រា ២៨.- ការមិនទទួលខុសត្រូវចំពោះការឃាត់ខ្លួនស្របច្បាប់ ជាអាទិ៍**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើបុគ្គលណាម្នាក់ នៅលើអាកាសយាន ត្រូវបានឃាត់ខ្លួន ឃុំខ្លួន ឬ ដាក់ចុះពីអាកាសយាន ដែលត្រូវបានធ្វើឡើងស្របតាមជំពូកនេះ ។

២-គ្មានបុគ្គលណាអាចធ្វើបណ្តឹងរដ្ឋប្បវេណី ឬព្រហ្មទណ្ឌទាក់ទងនឹងការឃាត់ខ្លួន ការឃុំខ្លួន ឬ ការដាក់ចុះពីអាកាសយាន ចំពោះ :

ក-ម្ចាស់អាកាសយាន ឬ

ខ-មេបញ្ជាការអាកាសយាន ឬ

គ-សមាជិកដទៃទៀតនៃក្រុមអាកាសយានិករបស់អាកាសយាន ឬ

ឃ-អ្នកដំណើរដែលធ្វើដំណើរតាមអាកាសយាន ឬ

ង-អ្នកដទៃទៀតដែលទទួលខុសត្រូវចំពោះការហោះហើរនៃអាកាសយាននោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

18/7

# ជំពូកទី ៤

# បទឧក្រិដ្ឋលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

## ផ្នែកទី ១

## ការបកស្រាយ

**មាត្រា ២៩.- និយមន័យ**

វាក្យស័ព្ទបច្ចេកទេសក្នុងច្បាប់នេះ មានន័យដូចខាងក្រោម :

បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ មានន័យដូចខាងក្រោម :

ក-ប្រមុខរដ្ឋ ។

ខ-សមាជិកមួយរូបនៃស្ថាប័នមួយ ដែលអនុវត្តមុខងាររបស់ប្រមុខរដ្ឋស្រប តាមរដ្ឋធម្មនុញ្ញរបស់រដ្ឋ ។

គ-ប្រមុខរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេស នៅពេលណាដែលប្រមុខដឹកនាំ រដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេស ស្ថិតនៅក្នុងរដ្ឋបរទេស ។

ឃ-សមាជិកនៃគ្រួសាររបស់ប្រមុខរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេសដែល អមដំណើរប្រមុខរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីការបរទេសទៅកាន់រដ្ឋបរទេស ។

ង-តំណាង ឬ មន្ត្រីនៃរដ្ឋមួយ ប្រសិនបើនៅពេល និងនៅទីកន្លែងដែលបទ ល្មើសក្រោមជំពូកនេះ ត្រូវបានប្រព្រឹត្តប្រឆាំងនឹងបូរណភាពនៃសិទ្ធិបុគ្គល សេរីភាព សេចក្តីថ្លៃថ្នូររបស់តំណាង ឬ មន្ត្រីនោះ ដែលតំណាង ឬមន្ត្រីនោះ មានសិទ្ធិក្រោមច្បាប់អន្តរជាតិ ។

ច-សមាជិកគ្រួសាររបស់តំណាង ឬ មន្ត្រីដូចមានចែងក្នុងចំណុច ង ដែលជា ផ្នែកមួយនៃផ្ទះសម្បែងរបស់គាត់ ។

# ផ្នែកទី ២

# បទល្មើស

## មាត្រា ៣០.– ឃាតកម្មលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ឬ ការវាយប្រហារដទៃទៀតលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

១-បុគ្គលណាដែលបានសម្លាប់បុគ្គល ដែលត្រូវបានការពារជាអន្តរជាតិ ដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

២-បុគ្គលដែលប្រព្រឹត្តអំពើហិង្សា ដោយចេតនាលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ត្រូវផ្តន្ទាទោសដូចខាងក្រោម :

ក-ទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនោះបណ្តាលឱ្យមានមរណភាពដល់ជនរងគ្រោះ ដោយគ្មានចេតនានឹងធ្វើឱ្យស្លាប់ ។

ខ-ទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ក្នុងករណីផ្សេងទៀត ។

## មាត្រា ៣១.– ការចាប់ពង្រត់ ការបង្ខាំង ឬ ការបំពារបំពានលើសេរីភាពរបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

១-បុគ្គលដែលចាប់ពង្រត់ ឬ ដែលបានបង្ខាំងបុគ្គលដែលត្រូវបានការពារជាអន្តរ-ជាតិដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

២-បុគ្គលដែលបំពារបំពានលើសេរីភាពរបស់បុគ្គល ដែលត្រូវបានការពារជាអន្តរ-ជាតិដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

## មាត្រា ៣២.– ការវាយប្រហារលើអគារផ្លូវការ កន្លែងស្នាក់នៅឯកជន ឬ មធ្យោបាយធ្វើដំណើររបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

១-បុគ្គលណាដែលវាយប្រហារដោយចេតនាលើអគារផ្លូវការ កន្លែងស្នាក់នៅឯកជន ឬ មធ្យោបាយធ្វើដំណើរណាមួយរបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ឬ អគារ



20/7/ឃ

ឬ អចលនទ្រព្យដទៃទៀតដែលនៅក្នុងនោះ ឬ នៅលើនោះបុគ្គលដែលត្រូវបានការពារជាអន្តរជាតិមានវត្តមាន ដែលអាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់រូបរាងកាយ ឬ សេរីភាពរបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំដល់ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៣៣.- ការគំរាមកំហែងប្រព្រឹត្តបទល្មើសលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ**

បុគ្គលដែលគំរាមកំហែងថានឹងប្រព្រឹត្តបទល្មើសក្រោមជំពូកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

## ជំពូកទី ៥
## ការចាប់ចំណាប់ខ្មាំង

**មាត្រា ៣៤.- ការចាប់ចំណាប់ខ្មាំង**

១-ការចាប់ចំណាប់ខ្មាំងត្រូវបានធ្វើឡើងដោយអំពើចាប់ ឬ ឃុំឃាំងបុគ្គលណាម្នាក់ដោយគំរាមសម្លាប់ បង្កឱ្យរបួស ឬ បន្តការឃុំឃាំង ក្នុងគោលបំណងបង្ខំឱ្យស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ នៅក្នុងរដ្ឋបរទេស ឬ ស្ថាប័នអន្តររដ្ឋាភិបាលអន្តរជាតិ ឬ បុគ្គល ឬ ក្រុមបុគ្គលដទៃទៀតឱ្យធ្វើ ឬ មិនធ្វើសកម្មភាពណាមួយជាលក្ខខណ្ឌចំហ ឬ មិនចំហ សម្រាប់ការដោះលែងចំណាប់ខ្មាំង ជាអំពើចាប់ចំណាប់ខ្មាំង ។

២-អំពើចាប់ចំណាប់ខ្មាំងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី ៦
# ការការពារជារូបវន្តលើសារធាតុនុយក្លេអ៊ែរ និងការបង្ក្រាបលើអំពើភេរវកម្មនុយក្លេអ៊ែរ

## ផ្នែកទី ១
## សេចក្តីផ្តើម

**មាត្រា ៣៥.- និយមន័យ**

វាក្យស័ព្ទក្នុងជំពូកនេះ :

១-ការដឹកជញ្ជូននុយក្លេអ៊ែរជាអន្តរជាតិ មានន័យថា ជាការបញ្ជូនសារធាតុនុយក្លេអ៊ែរ :

ក-តាមគ្រប់មធ្យោបាយដឹកជញ្ជូន ដោយមានគោលបំណងនាំយកទៅហួសពីដែនដីនៃរដ្ឋដែលជាកន្លែងចាប់ផ្តើមការបញ្ជូន និង

ខ-ដោយចាប់ផ្តើមពីការចេញដំណើរពីបរិវេណរបស់អ្នកបញ្ជូនទំនិញនៅក្នុងរដ្ឋនោះ និងដែលបញ្ចប់ដោយការមកដល់កន្លែងមួយនៅក្នុងរដ្ឋដែលជាគោលដៅចុងក្រោយនៃការបញ្ជូន ។

២-គ្រឿងនុយក្លេអ៊ែរ សំដៅលើ :

ក-គ្រឿងផ្ទុះនុយក្លេអ៊ែរ និង

ខ-គ្រឿងសម្រាប់សាយភាយវិទ្យុសកម្ម ឬ គ្រឿងដែលបញ្ចេញចុណ្ណភាគវិទ្យុសកម្ម ដែលដោយសារសមាសធាតុវិទ្យុសកម្មរបស់វា អាចបណ្តាលឱ្យមានមរណភាព របួសរូបកាយធ្ងន់ធ្ងរ ឬ មហន្តរាយចំពោះទ្រព្យសម្បត្តិ ឬ ចំពោះបរិស្ថាន ។

៣-បរិក្ខារនុយក្លេអ៊ែរ សំដៅលើ :

ក-ម៉ាស៊ីនប្រតិកម្មនុយក្លេអ៊ែរ រួមមានម៉ាស៊ីនប្រតិកម្មនុយក្លេអ៊ែរ ដែលត្រូវបានដំឡើងនៅក្នុងនាវា យានជំនិះ អាកាសយាន ឬ វត្ថុក្នុងលំហអាកាស សម្រាប់ប្រើជាប្រភពថាមពល ដើម្បីគោលបំណងជម្រុញទៅមុខ ឬ ដើម្បីគោលបំណងដទៃទៀត និង

ខ-រោងចក្រ ឬ យានប្រើប្រាស់ក្នុងផលិតកម្ម រក្សាទុក កែច្នៃ ឬ ដឹកជញ្ជូនសារ-

ធាតុវិទ្យុសកម្ម ។

៤-សារធាតុនុយក្លេអ៊ែរ គឺជាសារធាតុណាមួយដូចខាងក្រោម ៖

ក-ភ្លុយតូនីញ៉ូម លើកលែងតែភ្លុយតូនីញ៉ូម ដែលមានកំហាប់អ៊ីសូតូបលើសពី ៨០% នៅក្នុងភ្លុយតូនីញ៉ូម ២៣៨ ។

ខ-អ៊ុយរ៉ានីញ៉ូម ២៣៣ ។

គ-អ៊ុយរ៉ានីញ៉ូម ដែលត្រូវបង្កើនកម្រិតនៅក្នុងអ៊ីសូតូប ២៣៥ ឬ ២៣៣ដែលជាអ៊ុយរ៉ានីញ៉ូមដែលត្រូវបង្កើនកម្រិតនៅក្នុងអ៊ីសូតូប ២៣៥ ឬ ២៣៣ មានន័យថាជាអ៊ុយរ៉ានីញ៉ូមដែលមានអ៊ីសូតូប ២៣៥ ឬ ២៣៣ ឬ ទាំងពីរ នៅក្នុងបរិមាណមួយដែលនាំឱ្យអនុបាតនៃបរិមាណផលបូករបស់អ៊ីសូតូបទាំងនោះ មានដល់អ៊ីសូតូប ២៣៨ គឺលើសពីអនុបាតនៃអ៊ីសូតូប ២៣៥ ដល់ អ៊ីសូតូប ២៣៨ ដែលកើតឡើងនៅក្នុងធម្មជាតិ ។

ឃ-អ៊ុយរ៉ានីញ៉ូមដែលមាននៅក្នុងល្បាយនៃអ៊ីសូតូប ដែលកើតឡើងនៅក្នុងធម្មជាតិក្រៅពីទម្រង់ជារ៉ែ ឬ កាកសំណល់រ៉ែ ។

ង-សារធាតុណាមួយដែលមានសារធាតុ ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី ៤ នេះ ពីចំណុច ក ដល់ចំណុច ឃ ។

៥-សារធាតុវិទ្យុសកម្ម គឺជា ៖

ក-សារធាតុនុយក្លេអ៊ែរ និង

ខ-សារធាតុវិទ្យុសកម្មផ្សេងទៀត ដែលមានចុណ្ណភាគវិទ្យុសកម្មដែល ៖

ខ.១-ឆ្លងកាត់ការបំបែកជាដុំតូចៗដោយឯកឯង ដែលជាដំណើរការមួយដែលត្រូវបានអមជាមួយ ដោយការបញ្ចេញកាំរស្មីអ៊ីយ៉ុងមួយប្រភេទ ឬ ច្រើនប្រភេទដូចជាចុណ្ណភាគអាល់ហ្វា បេតា ឬ ណឺត្រុង និងកាំរស្មីហ្គាម៉ា និង

ខ.២-អាចដោយសារសមាសធាតុវិទ្យុសកម្ម ឬ បរមាណូរបស់វា បណ្តាលឱ្យមានការស្លាប់ ឬរបួសរូបរាងកាយធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរចំពោះទ្រព្យសម្បត្តិ ឬចំពោះបរិស្ថាន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

08/71

### មាត្រា ៣៦.- ការអនុវត្តផ្នែកទី ២ និងផ្នែកទី ៣ នៃជំពូកនេះ

ផ្នែកទី ២ និងផ្នែកទី ៣ នៃជំពូកនេះ ត្រូវអនុវត្តចំពោះសារធាតុនុយក្លេអ៊ែរ ដែលប្រើប្រាស់សម្រាប់គោលបំណងសន្តិភាព :

ក-ក្នុងរយៈពេលដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរជាអន្តរជាតិ និង

ខ-ក្នុងរយៈពេលប្រើប្រាស់ រក្សាទុកក្នុងឃ្លាំង និងដឹកជញ្ជូនក្នុងស្រុក ។

## ផ្នែកទី ២

## ការការពាររូបវន្តដែលចាំបាច់សម្រាប់សារធាតុនុយក្លេអ៊ែរ

### មាត្រា ៣៧.- ការកំណត់ប្រភេទសារធាតុនុយក្លេអ៊ែរ

សារធាតុនុយក្លេអ៊ែរនៅក្នុងជំពូកនេះ ត្រូវបែងចែកជាប្រភេទតាមតារាងដូចមាននៅក្នុងឧបសម្ព័ន្ធ ២ នៃច្បាប់នេះ ។

### មាត្រា ៣៨.- កម្រិតនៃការការពាររូបវន្ត ដែលត្រូវអនុវត្តនៅក្នុងការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរជាអន្តរជាតិ

១-កម្រិតនៃការការពាររូបវន្តលើសារធាតុនុយក្លេអ៊ែរ ក្នុងអំឡុងពេលរក្សាទុកក្នុងឃ្លាំងដែលអាចកើតឡើងដោយចៃដន្យ ចំពោះការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរជាអន្តរជាតិនោះ រួមមានវិធានការដូចខាងក្រោម :

ក-ចំពោះសារធាតុប្រភេទទី ៣ : ការរក្សាទុកក្នុងឃ្លាំងនៅក្នុងតំបន់មួយដែលការចេញចូលនៅតំបន់នោះ ត្រូវបានត្រួតពិនិត្យ ។

ខ-ចំពោះសារធាតុប្រភេទទី ២ : ការរក្សាទុកក្នុងឃ្លាំងនៅក្នុង

ខ.១-តំបន់មួយ :

ខ.១.១-ដែលស្ថិតនៅក្រោមការពិនិត្យតាមដានជាប្រចាំដោយឆ្មាំ ឬ ដោយឧបករណ៍អេឡិចត្រូនិក និង

ខ.១.២-ដែលហ៊ុមព័ទ្ធដោយរបាំងការពាររូបវន្ត និង

ខ.១.៣-ដោយមានចំនួនច្រកចូលត្រូវបានកម្រិតនៅក្រោម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

ការត្រួតពិនិត្យយ៉ាងសមស្រប ឬ

ខ.២-តំបន់មួយដែលមានការការពារជារូបវន្តកម្រិតស្មើគ្នា :

គ-ចំពោះសារធាតុប្រភេទទី ១ : ការរក្សាទុកក្នុងឃ្លាំងនៅក្នុងតំបន់ដែលត្រូវបានការពារ គឺដូចមានចែងក្នុងប្រភេទទី ២ ខាងលើ :

គ.១-ដែលការចេញចូលក្នុងតំបន់នោះ ត្រូវបានកំណត់ចំពោះតែបុគ្គលណា ដែលមានការសម្រេចអំពីការជឿទុកចិត្ត និង

គ.២-ដែលស្ថិតនៅក្រោមការពិនិត្យតាមដានដោយឆ្មាំ ដែលមានការទាក់ទងព័ត៌មានជិតស្និទ្ធជាមួយកងកម្លាំងឆ្លើយតបសមស្រប ។

២-អង្គភាពទទួលខុសត្រូវចំពោះការរក្សាទុកក្នុងឃ្លាំងនូវសារធាតុនុយក្លេអ៊ែរក៏ត្រូវតែចាត់វិធានការជាពិសេស ដើម្បីរកឱ្យឃើញ និងទប់ស្កាត់ការវាយប្រហារការចេញចូលដោយគ្មានការអនុញ្ញាត ឬការយកសារធាតុនុយក្លេអ៊ែរចេញដោយគ្មានការអនុញ្ញាត ។

៣-កម្រិតនៃការការពារជារូបវន្ត សម្រាប់សារធាតុនុយក្លេអ៊ែរ ក្នុងអំឡុងពេលដឹកជញ្ជូនជាអន្តរជាតិនោះ រួមមានវិធានការដូចខាងក្រោម :

ក-ចំពោះសារធាតុប្រភេទទី ២ និងទី ៣ ការដឹកជញ្ជូនត្រូវធ្វើឡើងនៅក្រោមការប្រុងប្រយ័ត្នជាពិសេសរួមមាន :

ក.១-ការរៀបចំជាមុនជាមួយអ្នកផ្ញើ អ្នកទទួល និងអ្នកដឹកជញ្ជូន និង

ក.២-ការព្រមព្រៀងជាមុន រវាងរូបវន្តបុគ្គល ឬ នីតិបុគ្គលអាស្រ័យតាមយុត្តាធិការ និងបទប្បញ្ញត្តិរបស់រដ្ឋដែលធ្វើការនាំចេញ នាំចូល ដោយបញ្ជាក់អំពីពេលវេលា ទីកន្លែង និងនីតិវិធីនៃការផ្ទេរការទទួលខុសត្រូវក្នុងការដឹកជញ្ជូន ។

ខ-ចំពោះសារធាតុប្រភេទទី ១ ការដឹកជញ្ជូនត្រូវធ្វើឡើង :

ខ.១-នៅក្រោមការប្រុងប្រយ័ត្នជាពិសេស ដូចកំណត់ខាងលើសម្រាប់ការដឹកជញ្ជូនសារធាតុប្រភេទទី ២ និងទី ៣ និង

ខ.២-នៅក្រោមការពិនិត្យតាមដានជាប្រចាំ ដោយការអមការពារនិង

ខ.៣-នៅក្រោមស្ថានភាពដែលធានាថា មានការទាក់ទងព័ត៌មានជិតស្និទ្ធជាមួយអ្នកទទួលហើយឆ្លើយតបសមស្រប ។

គ-ចំពោះសារធាតុអ៊ុយរ៉ានីញ៉ូមធម្មជាតិ (ក្រៅពីទម្រង់ជារ៉ែ ឬ កាកសំណល់

រ៉) នោះការការពារលើការដឹកជញ្ជូនអ៊ុយរ៉ាន្យូមធម្មជាតិ ឬអ៊ុយរ៉ាន្យូមដែលបានបំបាត់សមាសធាតុ ឬអ៊ុយរ៉ាន្យូមក្រអូបមានបរិមាណលើសពី ៥០០ (ប្រាំរយ) គីឡូក្រាម ត្រូវជូនព័ត៌មានជាមុនអំពីការបញ្ជូនទំនិញដោយបញ្ជាក់អំពី :

គ.១-វិធីដឹកជញ្ជូន និង

គ.២-ពេលវេលាគ្រោងនឹងមកដល់ និង

គ.៣-សេចក្តីបញ្ជាក់អំពីការទទួលទំនិញ ។

## ផ្នែកទី ៣

## បទល្មើសពាក់ព័ន្ធនឹងការការពាររូបវន្តនូវសារធាតុនុយក្លេអ៊ែរ

### មាត្រា ៣៩.– កិច្ចការពាររូបវន្តនូវសារធាតុនុយក្លេអ៊ែរ ក្នុងអំឡុងពេលដឹកជញ្ជូននុយក្លេ-អ៊ែរជាអន្តរជាតិ

បុគ្គលដែលបានប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃមាត្រា ៣៨ ខាងលើនេះ ដែលទាក់ទងដល់ការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ នាំចូល នាំចេញសារធាតុនុយក្លេអ៊ែរមកក្នុង ឬ ពីព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

### មាត្រា ៤០.– ការទទួល ការកាន់កាប់ ការប្រើប្រាស់ ការផ្ទេរ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ

បុគ្គលណាទទួល កាន់កាប់ ប្រើប្រាស់ ផ្ទេរ ផ្លាស់ប្តូរ បោះចោល ឬ ធ្វើឱ្យរាយប៉ាយនូវសារធាតុនុយក្លេអ៊ែរដោយចេតនា ដែលបណ្តាលឱ្យ ឬ អាចបណ្តាលឱ្យមានមរណភាព របួសធ្ងន់ធ្ងរដល់បុគ្គលណាផ្សេងទៀត ឬខូចខាតធ្ងន់ធ្ងរ ដល់ទ្រព្យសម្បត្តិ ឬ បរិស្ថាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

### មាត្រា ៤១.– ចោរកម្មសារធាតុនុយក្លេអ៊ែរ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១-បុគ្គលដែលលួចសារធាតុនុយក្លេអ៊ែរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីណាមួយដូចខាងក្រោម

ក-ការលួចប្រព្រឹត្តឡើងក្នុងពេល ឬ បន្ទាប់ពីការប្រើហិង្សា ។

ខ-ការលួចប្រព្រឹត្តឡើងដោយផ្ទាល់ដោយមនុស្សច្រើននាក់ ឬ ដោយមានការទម្លុះទម្លាយ ។

**មាត្រា ៤២.- ការបន្លំយកសារធាតុនុយក្លេអ៊ែរ**

បុគ្គលណាដែលទទួលបានសារធាតុនុយក្លេអ៊ែរ ដោយបន្លំយក ឆបោក ឬ ប្រើឧបាយកលទុច្ចរិតផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៣.- ការកំហែងយកសារធាតុនុយក្លេអ៊ែរ**

១-ការកំហែងយកមានន័យថា គឺជាអំពើដែលប្រព្រឹត្តដោយប្រើហិង្សា គំរាមកំហែងថានឹងប្រើហិង្សា ឬ បង្ខិតបង្ខំ ឬ បំភិតបំភ័យតាមគ្រប់រូបភាព ដើម្បីទទួលបាននូវសារធាតុនុយក្លេអ៊ែរ ។

២-ការកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៤៤.- ការគំរាមកំហែងប្រើប្រាស់សារធាតុនុយក្លេអ៊ែរ**

១-បុគ្គលណា គំរាមកំហែងថានឹងប្រើប្រាស់សារធាតុនុយក្លេអ៊ែរ ដោយចេតនាដើម្បីសម្លាប់ ឬ បង្កឱ្យមានរបួសដល់បុគ្គលណាផ្សេងទៀត ឬ បង្កឱ្យមានមហន្តរាយធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ឬ បរិស្ថាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

២-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ចំពោះបុគ្គលណាដែលគំរាមថានឹងប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តិនៅក្នុងមាត្រា ៤១ (ចោរកម្មសារធាតុនុយក្លេអ៊ែរ) ខាងលើនេះ ដោយមានគោលបំណងបង្ខំឱ្យ :

ក-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ខ-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

គ-បុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយឱ្យធ្វើ ឬ មិនធ្វើនូវសកម្មភាពណាមួយ ។

## ផ្នែកទី ៤

## ការគ្រប់គ្រងអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ

### មាត្រា ៤៥.– ការផលិត ប្រើប្រាស់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ គីមី និង ជីវសាស្ត្រ

១-បុគ្គលណាផលិត ទិញ លក់ កាន់កាប់ អភិវឌ្ឍ ដឹកជញ្ជូន ផ្ទេរ ឬ ប្រើដោយចេតនានូវអាវុធនុយក្លេអ៊ែរ អាវុធគីមី ឬ អាវុធជីវសាស្ត្រ ឬ មធ្យោបាយបញ្ជូនអាវុធទាំងនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

២-មធ្យោបាយបញ្ជូនអាវុធ ដែលមានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះ សំដៅដល់កាំជ្រួចមីស៊ីល គ្រាប់ផ្លោង និងប្រព័ន្ធមិនមានមនុស្សដទៃទៀត ដែលអាចបញ្ជូនអាវុធនុយក្លេអ៊ែរ អាវុធគីមី ឬ អាវុធជីវសាស្ត្រ ទៅដល់គោលដៅមួយ និងត្រូវបានធ្វើឡើងជាពិសេសដើម្បីការប្រើប្រាស់នោះ ។

## ផ្នែកទី ៥

## ការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ

### មាត្រា ៤៦.– ការកាន់កាប់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ

បុគ្គលណាកាន់កាប់នូវសារធាតុវិទ្យុសកម្ម ឬ ផលិត ឬ កាន់កាប់គ្រឿងនុយក្លេអ៊ែរ ដោយចេតនាក្នុងគោលបំណងធ្វើឱ្យមានមរណភាព ឬ របួសរូបកាយធ្ងន់ធ្ងរ ឬ មហន្តរាយដល់ទ្រព្យសម្បត្តិ ឬ បរិស្ថាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០(សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

### មាត្រា ៤៧.– អំពើនាំឱ្យខូចខាតដែលពាក់ព័ន្ធនឹងសារធាតុវិទ្យុសកម្ម គ្រឿងនុយក្លេអ៊ែរ បរិក្ខារនុយក្លេអ៊ែរ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ចំពោះបុគ្គលណាដែល :

ក-ដោយចេតនាប្រើសារធាតុវិទ្យុសកម្ម ឬ គ្រឿងនុយក្លេអ៊ែរតាមគ្រប់វិធី ឬ

ប្រើ ឬ ធ្វើឱ្យខូចខាតបរិក្ខារនុយក្លេអ៊ែរ ក្នុងលក្ខណៈមួយដែលបញ្ចេញ ឬ បណ្តាលឱ្យមានហានិភ័យនៃការបញ្ចេញសារធាតុវិទ្យុសកម្ម និង

ខ-មានគោលបំណងធ្វើឱ្យមានមរណភាព ឬ របួសរូបកាយធ្ងន់ធ្ងរ ឬ មហន្តរាយដល់ទ្រព្យសម្បត្តិ ឬ បរិស្ថាន ឬ

គ-មានគោលបំណងបង្ខំ :

គ.១-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ នៅក្នុងរដ្ឋបរទេស ឬ

គ.២-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

គ.៣-បុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយឱ្យធ្វើ ឬ មិនធ្វើនូវសកម្មភាពណាមួយ ។

**មាត្រា ៤៨.- ការគំរាមកំហែង និងការទាមទារ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់) ឆ្នាំ ដល់ ២០(ម្ភៃ)ឆ្នាំ ចំពោះបុគ្គលណាដែល :

ក-គំរាមកំហែងថានឹងប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តក្នុងមាត្រា ៤៧ ខាងលើនេះ ក្នុងស្ថានភាពដែលបង្ហាញថាការគំរាមកំហែងនោះអាចឱ្យជឿបាន ឬ

ខ-ទាមទារសារធាតុវិទ្យុសកម្ម ឬ គ្រឿងនុយក្លេអ៊ែរ ឬ បរិក្ខារនុយក្លេអ៊ែរតាមរយៈការគំរាមកំហែង ក្នុងស្ថានភាពដែលបង្ហាញថាការគំរាមកំហែងនោះ អាចឱ្យជឿបាន ឬ ដោយប្រើហិង្សា ។

## ជំពូកទី ៧

## អំពើប្រឆាំងនឹងសុវត្ថិភាពនាវាចរណ៍ផ្លូវសមុទ្រ

### ផ្នែកទី ១

### ការអនុវត្ត

**មាត្រា ៤៩.- ការមិនអនុវត្តជំពូកនេះ**

ជំពូកនេះមិនអនុវត្តចំពោះ :

ក-នាវាចម្បាំង ឬ

ខ-នាវាដែលជាកម្មសិទ្ធិរបស់រដ្ឋណាមួយ ឬ ដែលត្រូវបានប្រតិបត្តិ ដោយរដ្ឋណាមួយ ឬ ដែលជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា ឬ ដែលត្រូវបានប្រតិបត្តិដោយព្រះរាជាណាចក្រកម្ពុជា នៅពេលដែលនាវានោះត្រូវបានប្រើប្រាស់ជានាវាចម្បាំងជំនួយ ឬ សម្រាប់គោលដៅគយ ឬ នគរបាល ឬ

គ-នាវាដែលត្រូវបានយកចេញពីការធ្វើនាវាចរណ៍ ឬ ត្រូវបានលើកឡើងដើម្បីជួសជុល ឬ ឈប់ប្រើការ ។

## ផ្នែកទី ២

## បទល្មើស

### មាត្រា ៥០.- ការរឹបអូស ឬ ការត្រួតត្រាលើនាវា

បុគ្គលណារឹបអូស ឬ ធ្វើការត្រួតត្រាដោយខុសច្បាប់ ឬដោយប្រើហិង្សា ឬ គំរាមកំហែង ឬ ដោយការបំភិតបំភ័យតាមគ្រប់រូបភាព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំដល់ ៣០ (សាមសិប) ឆ្នាំ ។

### មាត្រា ៥១.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើនាវា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដោយចេតនា ប្រព្រឹត្តអំពើហិង្សាលើមនុស្សនៅលើនាវា ប្រសិនបើអំពើនោះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវានោះ ។

### មាត្រា ៥២.- ការបំផ្លាញ ឬការធ្វើឱ្យខូចខាតនាវា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែល ដោយចេតនាបំផ្លាញ ឬ ធ្វើឱ្យខូចនាវា ឬ ទំនិញលើនាវា ប្រសិនបើការខូចខាតនោះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ។

## មាត្រា ៥៣.- ការដាក់ឧបករណ៍ ឬ សារធាតុលើនាវា

បុគ្គលណា ដោយចេតនាដាក់ ឬ បង្កឱ្យមានការដាក់នូវឧបករណ៍ ឬ សារធាតុដែលអាចបំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាតដល់នាវា ឬ ទំនិញលើនាវា ហើយដែលធ្វើឱ្យមានគ្រោះថ្នាក់ ឬ អាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

## មាត្រា ៥៤.- ការកម្ទេច ឬ ការធ្វើឱ្យខូចខាតដល់ប្រព័ន្ធឧបករណ៍តម្រង់ទិសនាវាចរណ៍

បុគ្គលណាកម្ទេច ឬ ធ្វើឱ្យខូចខាតដល់ប្រព័ន្ធឧបករណ៍តម្រង់ទិសនាវាចរណ៍ ឬ បង្អាក់ដល់ប្រតិបត្តិការនៃប្រព័ន្ធឧបករណ៍តម្រង់ទិសនាវាចរណ៍ ដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនោះ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ។

## មាត្រា ៥៥.- ការផ្តល់ព័ត៌មានមិនពិត ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវា

បុគ្គលណាដែលផ្តល់ដោយចេតនា នូវព័ត៌មានដែលខ្លួនដឹងថាមិនពិត ហើយព័ត៌មាននេះធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ។

## មាត្រា ៥៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ

បុគ្គលណាសម្លាប់បុគ្គលណាផ្សេងទៀតដោយចេតនា ហើយអំពើនេះមានទំនាក់ទំនងទៅនឹងបទល្មើសដែលបានបញ្ញត្តនៅក្នុងមាត្រា ៥០ ដល់មាត្រា ៥៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

## មាត្រា ៥៧.- អំពើបង្ករបួសដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ

បុគ្គលណាដែលបង្កឱ្យមានរបួសដល់បុគ្គលណាផ្សេងទៀតដោយចេតនា ហើយអំពើនេះមានទំនាក់ទំនងទៅនឹងបទល្មើស ដូចមានបញ្ញត្តនៅក្នុងមាត្រា ៥០ ដល់ មាត្រា ៥៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ។

## មាត្រា ៥៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់នាវាចរណ៍ប្រកបដោយ សុវត្ថិភាពរបស់នាវា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ចំពោះបុគ្គលណាដែល :

ក-គំរាមកំហែងថានឹងប្រព្រឹត្តអំពើណាមួយ ដែលជាបទល្មើសដូចមានបញ្ញត្តក្នុងមាត្រា ៥១ មាត្រា ៥២ ឬមាត្រា ៥៤ នៃច្បាប់នេះ ហើយ

ខ-ការគំរាមកំហែងនោះ អាចនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃនាវាចរណ៍របស់នាវា ហើយនិង

គ-ការគំរាមកំហែងនោះមានគោលបំណងបង្ខិតបង្ខំ :

គ.១-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ នៅក្នុងរដ្ឋបរទេសណាមួយ ឬ

គ.២-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

គ.៣-បុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយឱ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ។

# ផ្នែកទី ៣

# សិទ្ធិអំណាចរបស់មេបញ្ជាការនាវា

## មាត្រា ៥៩.- សិទ្ធិអំណាចក្នុងការប្រគល់ ជាអាទិ៍ នូវបុគ្គលណាមួយឱ្យទៅអាជ្ញាធរមានសមត្ថកិច្ច

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើមេបញ្ជាការនាវាមានមូលហេតុសមស្របនឹងជឿថា បុគ្គលណាម្នាក់បានប្រព្រឹត្ត ឬ កំពុងប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តនៅក្នុងផ្នែកទី ២ ជំពូកទី ៧ នៃច្បាប់នេះ ។

២-មេបញ្ជាការនាវាអាចចាប់ខ្លួន ឃាត់ខ្លួនបុគ្គលនោះ ហើយប្រគល់ឱ្យទៅ :

ក-អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋអនុសញ្ញា ឬ

ខ-អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ។

៣-មេបញ្ជាការនាវាដែលមានបំណងប្រគល់ខ្លួនបុគ្គលណាម្នាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋអនុសញ្ញានោះ :

ក-អំពីបំណងប្រគល់ខ្លួនបុគ្គលនោះដល់អាជ្ញាធរមានសមត្ថកិច្ច និង

ខ-អំពីមូលហេតុនៃបំណងប្រគល់ខ្លួនបុគ្គលនោះ ។

៤-មេបញ្ជាការនាវាត្រូវជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើ :

ក-នៅមុនពេលដែលនាវាបានចូលទៅដល់ដែនសមុទ្ររបស់រដ្ឋអនុសញ្ញា ប្រសិនបើអាចធ្វើទៅបាន ឬ

ខ-ឱ្យបានឆាប់ជាបន្ទាន់សមស្របតាមស្ថានភាពជាក់ស្តែង នៅក្នុងករណីដទៃទៀត ។

៥-នៅពេលដែលមេបញ្ជាការនាវា ប្រគល់ខ្លួនបុគ្គលណាម្នាក់ តាមបញ្ញត្តិនៃកថា-ខណ្ឌទី ២ ខាងលើ មេបញ្ជាការនាវានោះ ត្រូវផ្តល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋអនុសញ្ញា នូវរាល់ភស្តុតាងទាំងអស់ដែលខ្លួនមាន ហើយដែលទាក់ទងទៅនឹងបទល្មើសដោយសន្មត ។

៦-ក្នុងមាត្រានេះ រដ្ឋអនុសញ្ញា មានន័យថាគឺជារដ្ឋដែលជាភាគីនៃអនុសញ្ញាសម្រាប់ការបង្ក្រាបសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃនាវាចរណ៍ផ្លូវសមុទ្រ ដែលធ្វើនៅទីក្រុងរ៉ូម នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨ ។

## មាត្រា ៦០.- ពុំមានទោសប្បញ្ញត្តិសម្រាប់ការឃាត់ខ្លួនស្របច្បាប់

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើជនណាម្នាក់លើនាវាត្រូវបានចាប់ ឬ ឃុំខ្លួន ឬ ត្រូវបានបញ្ជូនខ្លួនឱ្យអាជ្ញាធរមានសមត្ថកិច្ច ស្របតាមជំពូកនេះ ។

២-គ្មានជនណាម្នាក់អាចដាក់បណ្តឹងរដ្ឋប្បវេណី ឬ បណ្តឹងព្រហ្មទណ្ឌ ចំពោះការឃុំខ្លួន ឬ ការបញ្ជូនខ្លួនប្រឆាំងនឹង :

ក-ម្ចាស់នាវា ឬ ប្រតិបត្តិករនាវា ឬ

ខ-មេបញ្ជាការនាវា ឬ

គ-សមាជិកក្រុមនាវិកដទៃណាទៀតដែលទទួលបញ្ជាពីមេបញ្ជាការនាវា ឬ

ឃ-អ្នកដំណើរដែលធ្វើដំណើរតាមនាវាណាមួយដែលទទួលបញ្ជាពីមេបញ្ជាការនាវា ឬ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



33/71

ង-ជនដទៃណាទៀតដែលទទួលខុសត្រូវលើដំណើរនាវានោះ ។

## ជំពូកទី ៨
## បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចល័ត ដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រ

### ផ្នែកទី ១
### ការបកស្រាយ

**មាត្រា ៦១.- និយមន័យ**

ទីតាំងអចល័ត មានន័យថាជាកោះសិប្បនិម្មិត ឬ មូលដ្ឋាន ឬ សំណង់ ឬ អគារដែលភ្ជាប់នឹងបាតសមុទ្រជាអចិន្ត្រៃយ៍ សម្រាប់គោលបំណងក្នុងការរុករក ឬ ធ្វើអាជីវកម្មធនធានធម្មជាតិ ឬ សម្រាប់គោលបំណងផ្សេងទៀតខាងសេដ្ឋកិច្ច ។

### ផ្នែកទី ២
### បទល្មើស

**មាត្រា ៦២.- ការដណ្ដើមកាន់កាប់ ការត្រួតត្រាលើទីតាំងអចល័ត**

បុគ្គលណា ដោយចេតនា ដណ្ដើមកាន់កាប់ ឬ ធ្វើការត្រួតត្រាលើទីតាំងអចល័ត ដោយប្រើហិង្សា ឬ ដោយការគំរាមកំហែង ឬ ដោយការបំភិតបំភ័យ តាមគ្រប់រូបភាព ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំដល់ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៦៣.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើទីតាំងអចល័ត**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលបានប្រព្រឹត្តអំពើហិង្សាលើមនុស្សនៅលើទីតាំងអចល័ត ប្រសិនបើអំពើនោះអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័តនោះ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

34/71

**មាត្រា ៦៤.- ការកម្ទេច ការធ្វើឱ្យខូចខាតទីតាំងអចល័ត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលបានកម្ទេច ឬ ធ្វើឱ្យខូចខាតទីតាំងអចល័តដោយចេតនា ប្រសិនបើអំពើនោះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័តនោះ ។

**មាត្រា ៦៥.- ការដាក់ឧបករណ៍ ឬ សារធាតុនៅលើទីតាំងអចល័ត**

បុគ្គលណា ដោយចេតនា ដាក់ ឬ បង្កឱ្យមានការដាក់នូវឧបករណ៍ ឬ សារធាតុដែលអាចបំផ្លាញទីតាំងអចល័ត ឬ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ**

បុគ្គលណាសម្លាប់បុគ្គលណាម្នាក់ផ្សេងទៀត ហើយអំពើនេះមានទំនាក់ទំនងទៅនឹងបទល្មើស ដែលបានបញ្ញត្តនៅក្នុងមាត្រា ៦២ ដល់មាត្រា ៦៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

**មាត្រា ៦៧.- អំពើបង្ករបួសដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ**

បុគ្គលណាដែលបង្កឱ្យមានរបួសដល់បុគ្គលណាម្នាក់ផ្សេងទៀត ហើយអំពើនេះមានទំនាក់ទំនងទៅនឹងបទល្មើស ដូចមានបញ្ញត្តនៅក្នុងមាត្រា ៦២ ដល់ មាត្រា ៦៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ។

**មាត្រា ៦៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័ត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ឬ អស់មួយជីវិត ចំពោះបុគ្គលណាដែល :

១-ការគំរាមកំហែងថានឹងប្រព្រឹត្តអំពើណាមួយ ដែលជាបទល្មើសដូចមានបញ្ញត្តិក្នុងមាត្រា ៦២ ដល់មាត្រា ៦៥ នៃច្បាប់នេះ ហើយ

២-ការគំរាមកំហែងនោះមានគោលបំណងបង្ខិតបង្ខំ :

២-១-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការនៅក្នុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

35/71

ព្រះរាជាណាចក្រកម្ពុជា ឬ នៅក្នុងរដ្ឋបរទេសណាមួយ ឬ

ខ-២-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

ខ-៣-បុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយឱ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ។

## ជំពូកទី ៩

## ការដាក់សញ្ញាសម្គាល់គ្រឿងផ្ទុះផ្លាស្ទិក សម្រាប់គោលបំណងរកឃើញ

## ផ្នែកទី ១

## ការបកស្រាយ

### មាត្រា ៦៩.- និយមន័យ

នៅក្នុងជំពូកនេះ វាក្យស័ព្ទ :

១-សារធាតុរកគ្រឿងផ្ទុះ មានន័យថាគឺជាសារធាតុមួយបែបដូចរៀបរាប់ក្នុងមាត្រា ៧១ ដែលត្រូវបានដាក់ចូលក្នុងគ្រឿងផ្ទុះណាមួយ ដើម្បីធ្វើឱ្យគ្រឿងផ្ទុះនោះ អាចត្រូវបានរកឃើញ ។

២-ឧបករណ៍យោធាមានការអនុញ្ញាតត្រឹមត្រូវ គឺជាឧបករណ៍ដែលត្រូវបានផលិតជាពិសេសដោយឡែកសម្រាប់គោលបំណងផ្នែកយោធា ឬនគរបាល អនុលោមតាមច្បាប់របស់រដ្ឋ ដែលនៅក្នុងនោះឧបករណ៍ទាំងនោះ ត្រូវបានផលិត ដោយមិនកំណត់ត្រឹមតែគ្រាប់កាំភ្លើង គ្រាប់បែក ក្បាលគ្រាប់ គ្រាប់មីន គ្រាប់កាំជ្រួចមីស៊ីល គ្រាប់រ៉ុក្កែតវិសេស គ្រាប់បែកដៃ និងគ្រាប់បុកទម្លុះ ។

៣-គ្រឿងផ្ទុះ មានន័យថាគឺជាផលិតផលគ្រឿងផ្ទុះដែលជាទូទៅត្រូវបានស្គាល់ថាគឺជាគ្រឿងផ្ទុះផ្លាស្ទិក រួមមានគ្រឿងផ្ទុះមានទម្រង់ជាបន្ទះទន់បត់បាន ឬ ទាញយឺតបានដូចមានរៀបរាប់ក្នុងមាត្រា ៧០ នៃច្បាប់នេះ ។

៤-ការផលិត មានន័យថាគឺជាដំណើរការ រួមទាំងការកែច្នៃឡើងវិញ ដែលផលិតឬរៀបចំគ្រឿងផ្ទុះ ។

៥-ការដាក់សញ្ញាសម្គាល់ មានន័យថាជាការដាក់បញ្ចូលសារធាតុរកគ្រឿងផ្ទុះទៅក្នុងគ្រឿងផ្ទុះណាមួយយោងតាមមាត្រា ៧០ នៃច្បាប់នេះ ។

៦-រដ្ឋដែលផលិត មានន័យថាគឺជារដ្ឋមួយដែលនៅក្នុងដែនដីនៃរដ្ឋនោះ ផលិតករផលិតគ្រឿងផ្ទុះ ។

៧-គ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ មានន័យថាជាគ្រឿងផ្ទុះដែលមិនត្រូវបានដាក់សញ្ញាសម្គាល់ដោយសារធាតុរកគ្រឿងផ្ទុះយោងតាមមាត្រា ៧១ នៃច្បាប់នេះ ។

**មាត្រា ៧០.- ការពិពណ៌នាគ្រឿងផ្ទុះ**

១-ជំពូកនេះអនុវត្តចំពោះគ្រឿងផ្ទុះដែល :

ក-ផលិតឡើងដោយរូបមន្តគ្រឿងផ្ទុះខ្លាំងចំនួនមួយ ឬ ច្រើន ដែលតាមទម្រង់សុទ្ធរបស់វាមានសម្ពាធចំហាយតិចជាង ១០$^{-៤}$ ប៉ែអា នៅកម្រិតសីតុណ្ហភាព ២៥ អង្សានិង

ខ-ផលិតឡើងដោយមានសម្ភារៈចងរុំភ្ជាប់ និង

គ-ជាល្បាយមួយដែលទន់ ឬអាចបត់បាននៅកម្រិតសីតុណ្ហភាពក្នុងបន្ទប់ធម្មតា ។

២-សម្រាប់គោលបំណងនៃជំពូកនេះ គ្រឿងផ្ទុះដូចខាងក្រោមមិនត្រូវបានចាត់ទុកថាជាគ្រឿងផ្ទុះឡើយ ប្រសិនបើគ្រឿងផ្ទុះទាំងនោះត្រូវបានបន្តរក្សាទុក ឬ ប្រើប្រាស់សម្រាប់គោលបំណងដែលត្រូវបានបញ្ជាក់ច្បាស់លាស់ ឬ ត្រូវបានដាក់បញ្ចូលតាមការបញ្ជាក់ច្បាស់លាស់ :

ក-គ្រឿងផ្ទុះដែលត្រូវបានផលិតឡើង ឬ ត្រូវបានរក្សាទុកក្នុងបរិមាណមានកំណត់សម្រាប់តែការប្រើប្រាស់នៅក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ ឬ ការសាកល្បងដែលមានការអនុញ្ញាតត្រឹមត្រូវនូវគ្រឿងផ្ទុះថ្មី ឬ គ្រឿងផ្ទុះកែលម្អ ។

ខ-គ្រឿងផ្ទុះ ដែលត្រូវបានផលិតឡើង ឬ ត្រូវបានរក្សាទុកក្នុងបរិមាណមានកំណត់សម្រាប់តែការប្រើប្រាស់នៅក្នុងការហ្វឹកហ្វឺនផ្នែករាវរក គ្រឿងផ្ទុះ និង/ ឬការអភិវឌ្ឍ ឬ ការសាកល្បងដែលមានការអនុញ្ញាតត្រឹមត្រូវនូវឧបករណ៍រាវរកគ្រឿងផ្ទុះ ។

គ-គ្រឿងផ្ទុះដែលត្រូវបានផលិតឡើង ឬ ត្រូវបានរក្សាទុកក្នុងបរិមាណមានកំណត់សម្រាប់តែគោលបំណងនីតិវេជ្ជសាស្ត្រ ដែលមានការអនុញ្ញាតត្រឹមត្រូវ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ-គ្រឿងផ្ទុះដែលត្រូវបានគ្រោងដាក់ ហើយត្រូវដាក់បញ្ចូលជាផ្នែកបន្ថែមមួយនៃឧបករណ៍យោធា ដែលមានការអនុញ្ញាតត្រឹមត្រូវនៅក្នុងដែនដីនៃរដ្ឋផលិតក្នុងពេលរវាង ៣ (បី) ឆ្នាំ បន្ទាប់ពីអនុសញ្ញាស្តីពីការកំណត់សញ្ញាសម្គាល់គ្រឿងផ្ទុះធ្វើពីផ្លាស្ទិកសម្រាប់គោលបំណងរកឃើញ ត្រូវបានចុះហត្ថលេខានៅទីក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៩១ ចូលជាធរមាន ចំពោះរដ្ឋនោះ ។

៣-នៅក្នុងជំពូកនេះ :

មានការអនុញ្ញាតត្រឹមត្រូវ មានន័យថាត្រូវបានអនុញ្ញាតយោងតាមច្បាប់ និងបទបញ្ញត្តិនៃរដ្ឋដែលពាក់ព័ន្ធ ។

គ្រឿងផ្ទុះខ្លាំង រួមមានគ្រឿងផ្ទុះដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ៤ ឬ ជាតិផ្ទុះខ្លាំងដទៃទៀត ។

**មាត្រា ៧១.- សារធាតុរកគ្រឿងផ្ទុះ**

១-សារធាតុដូចមានរាយនៅក្នុងតារាងឧបសម្ព័ន្ធ ៣ នៃច្បាប់នេះ គឺជាសារធាតុរកគ្រឿងផ្ទុះ ហើយមានគោលបំណងប្រើប្រាស់ ដើម្បីធ្វើឱ្យគ្រឿងផ្ទុះងាយនឹងត្រូវបានរកឃើញតាមរយៈការតាមដានរកចំហាយ ។

២-សារធាតុរកគ្រឿងផ្ទុះត្រូវបានដាក់ចូលក្នុងគ្រឿងផ្ទុះ :

ក-តាមរបៀបមួយ ដែលសម្រេចបានការលាយស្មើគ្នានៅក្នុងផលិតផលសម្រេច និង

ខ-តាមកម្រិតកំហាប់អប្បបរិមាដូចមាននៅក្នុងលេខរៀងពាក់ព័ន្ធ ក្នុងតារាងនៅក្នុងឧបសម្ព័ន្ធ ៣ នៅក្នុងផលិតផលសម្រេចនៅពេលផលិត ។

## ផ្នែកទី ២

## បទល្មើស

**មាត្រា ៧២.- ការផលិតគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់**

បុគ្គលណាផលិតគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៧៣.- ការកាន់កាប់ ការដឹកជញ្ជូន ការនាំចេញ ការនាំចូលនូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់**

១-ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុគ្គលណាដែលកាន់កាប់ ឬ ដឹកជញ្ជូននូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ ឬ នាំចេញ ឬ នាំចូលនូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់មកក្នុង ឬ ចេញពីព្រះរាជាណាចក្រកម្ពុជា ។

២-កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះការកាន់កាប់ ដឹកជញ្ជូន នាំចេញ ឬ នាំចូលនូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ ដែលត្រូវបានប្រព្រឹត្ត ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងបំពេញមុខងារយោធា ឬ នគរបាល និងសម្រាប់គោលបំណងដែលសមស្របទៅនឹងគោលបំណងនៃអនុសញ្ញាស្ដីពីការកំណត់សញ្ញាសម្គាល់នៃគ្រឿងផ្ទុះផ្លាស្ទិក សម្រាប់គោលបំណងរកឃើញដែលធ្វើនៅទីក្រុងម៉ុងរ៉េអាល់ ឆ្នាំ ១៩៩១ ។

## ជំពូកទី ១០
## ការដាក់គ្រាប់បែកភេរវកម្ម
### ផ្នែកទី ១
### ការបកស្រាយ

**មាត្រា ៧៤.- និយមន័យ**

វាក្យស័ព្ទក្នុងជំពូកនេះ :

១-គ្រឿងផ្ទុះ ឬ គ្រឿងប្រល័យដទៃទៀត មានន័យថា :

ក-ជាគ្រឿងផ្ទុះ ឬ អាវុធធ្វើឱ្យឆាបឆេះ ឬឧបករណ៍ណាមួយដែលធ្វើឡើង ឬ មានសមត្ថភាព ដើម្បីបណ្ដាលឱ្យមានមរណភាព ឬ របួសធ្ងន់ធ្ងរដល់រាងកាយ ឬ ការខូចខាតធ្ងន់ធ្ងរ ឬ

ខ-ជាអាវុធ ឬ ឧបករណ៍ណាមួយដែលធ្វើឡើង ឬ មានសមត្ថភាពដែល

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

បណ្តាលឱ្យមានមរណភាព ឬ របួសធ្ងន់ធ្ងរដល់រាងកាយ ឬ ការខូចខាតធ្ងន់ធ្ងរ ដោយសារការបញ្ចេញ ការបាចសាចចេញ ឬ ផលប៉ះពាល់ដោយ :

ខ.១-សារធាតុគីមីពុល ឬ

ខ.២-សារធាតុជីវសាស្ត្រ ឬ

ខ.៣-ជាតិពុល ឬសារធាតុដូចគ្នាឬសារធាតុប្រហាក់ប្រហែល ឬ

ខ.៤-ការសាយភាយកាំរស្មី ឬ

ខ.៥-សារធាតុវិទ្យុសកម្ម ។

២-បរិវេណហេដ្ឋារចនាសម្ព័ន្ធ មានន័យថាគឺជាបរិវេណសាធារណៈ ឬ កាន់កាប់ដោយឯកជនដែលផ្តល់ ឬ បែងចែកសេវាកម្ម ដូចជាទឹក ប្រព័ន្ធលូទឹក ថាមពល ប្រេងឥន្ធនៈ ឬ គមនាគមន៍ ដើម្បីផលប្រយោជន៍សាធារណជន ។

៣-ទីកន្លែងសាធារណៈ មានន័យថា :

ក-ផ្នែកមួយនៃអគារ ដី ផ្លូវថ្នល់ ផ្លូវទឹក ឬ ទីកន្លែងដទៃទៀត និង

ខ-ទីកន្លែងពាណិជ្ជកម្ម អាជីវកម្ម វប្បធម៌ ប្រវត្តិសាស្ត្រ អប់រំ សាសនា រដ្ឋាភិបាល ទីកំសាន្ត រមណីយដ្ឋាន ឬ ទីតាំងដូចគ្នានេះ ដែលអាចចេញចូលបាន ឬ បើកឱ្យសាធារណជនគ្រប់ពេលវេលាតាមពេលកំណត់ ឬ ម្តងម្កាល ។

៤-ប្រព័ន្ធដឹកជញ្ជូនសាធារណៈ មានន័យថាជាមធ្យោបាយ និងឧបករណ៍ដឹកនាំគ្រប់ប្រភេទ ទោះបីជាកម្មសិទ្ធិសាធារណៈ ឬ ឯកជនក្តី ដែលត្រូវប្រើប្រាស់នៅក្នុង ឬ សម្រាប់សេវាកម្មសាធារណៈ ដើម្បីដឹកជញ្ជូនមនុស្ស ឬ ទំនិញ ។

## ផ្នែកទី ២

## បទល្មើស

**មាត្រា ៧៥.- ការបញ្ជូន ការដាក់ ការបាញ់ ឬ ការធ្វើឱ្យផ្ទុះគ្រឿងផ្ទុះ ឬ គ្រឿងប្រល័យនៅទីកន្លែងសាធារណៈ ជាអាទិ៍**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ដល់ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ចំពោះបុគ្គលណាដែល ដោយចេតនា បញ្ជូន ដាក់ បាញ់ ឬ ធ្វើឱ្យផ្ទុះគ្រាប់បែក ឬ

គ្រឿងប្រល័យដទៃទៀតនៅក្នុង ឬ ចូលទៅក្នុង ឬ ប្រឆាំងនឹងទីកន្លែងសាធារណៈ ឬ បរិវេណរបស់រដ្ឋ ឬ រដ្ឋាភិបាល ឬ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ឬ បរិវេណហេដ្ឋារចនាសម្ព័ន្ធដោយមានគោលបំណងធ្វើឱ្យ :

ក-មានមរណភាព ឬ របួសធ្ងន់ធ្ងរដល់រាងកាយ ឬ

ខ-អន្តរាយធ្ងន់ធ្ងរដល់ទីកន្លែង បរិវេណ ឬ ប្រព័ន្ធទាំងនោះ ហើយប្រសិនបើមានការអន្តរាយនោះ នឹងបណ្តាលឱ្យមាន ឬ អាចនឹងបណ្តាលឱ្យមានការខាតបង់សេដ្ឋកិច្ចធ្ងន់ធ្ងរ ។

## ជំពូកទី ១១

## ហិរញ្ញប្បទាន និងជំនួយសម្រាប់ភេរវកម្ម

## ផ្នែកទី ១

## បទល្មើស

**មាត្រា ៧៦.- ការផ្តល់ ឬ ការប្រមូលទ្រព្យសម្រាប់ប្រើប្រាស់ក្នុងអំពើភេរវកម្ម ឬ ក្នុងការជួយដល់ភេរវករ**

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែល ដោយចេតនាផ្តល់ ឬ ប្រមូលទ្រព្យដោយមានបំណង ឬ ដោយដឹងថា ទ្រព្យនោះនឹងត្រូវបានប្រើប្រាស់ទាំងមូល ឬ មួយផ្នែកដើម្បីប្រព្រឹត្ត :

ក-អំពើមួយដែលជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់របស់រដ្ឋបរទេសដែលស្ថិតនៅក្នុងរង្វង់នៃអនុសញ្ញា ដែលមានរាយបញ្ជីនៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាអន្តរ-ជាតិស្តីពីការបង្ក្រាបហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានធ្វើនៅទីក្រុងញូវយ៉ក ឆ្នាំ ២០០០ ឬ

ខ-អំពើមួយដែលមានគោលបំណងបង្កឱ្យមានមរណភាព ឬ របួសធ្ងន់ធ្ងរដល់រូបរាងកាយមនុស្សណាម្នាក់ផ្សេងទៀត ក្រៅពីបុគ្គលដែលចូលរួមយ៉ាងសកម្មក្នុងអរិភាព មិនជាប់ពាក់ព័ន្ធ នៅក្នុងស្ថានភាពវិវាទប្រដាប់អាវុធ ប្រសិនបើគោលបំណងនៃអំពើនោះតាមប្រភេទ និងបរិបទរបស់វា គឺដើម្បីបំភិតបំភ័យក្រុមណាមួយនៃប្រជាជន ឬ ដើម្បីបង្ខំ :

ក-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការ នៅក្នុង

ព្រះរាជាណាចក្រកម្ពុជា ឬ

ខ.២-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

ខ.៣-បុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយ ឱ្យធ្វើ ឬ មិនធ្វើនូវសកម្មភាពណាមួយ ។

២-អំពើដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺជាបទល្មើស ទោះបីជាទ្រព្យដែលផ្តល់ ឬ ប្រមូលនោះ មិនត្រូវបានយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសដែលមានបញ្ញត្តក្នុងច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសក៏ដោយ ។

**មាត្រា ៧៧.- ការផ្តល់លទ្ធភាពឱ្យប្រើនូវទ្រព្យសម្បត្តិ ធនធាន ឬ សេវាកម្មដល់ភេរវករ បុគ្គល ឬ អង្គភាពដែលពាក់ព័ន្ធនឹងភេរវករ**

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែល ដោយចេតនាផ្តល់លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ធនធាន ឬ សេវាកម្មដោយផ្ទាល់ ឬ ដោយប្រយោល សម្រាប់ជាអត្ថប្រយោជន៍របស់ :

ក-បុគ្គលណាមួយដែលប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តនៅក្នុងច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ-អង្គភាពដែលជាកម្មសិទ្ធិរបស់ ឬ ដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោលដោយបុគ្គលដែលបានបញ្ញត្តនៅក្នុងចំណុច ក ខាងលើនេះ ឬ

គ-បុគ្គល ឬ អង្គភាពណាមួយដែលធ្វើសកម្មភាពក្នុងនាម ឬ តាមការបញ្ជារបស់បុគ្គលដែលបានបញ្ញត្តក្នុងចំណុច ក ខាងលើនេះ ។

២-អំពើដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ គឺជាបទល្មើស ទោះបីជាទ្រព្យសម្បត្តិ ឬ ធនធាន ឬ សេវាកម្មមិនត្រូវបានយកទៅប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសដែលមានបញ្ញត្តក្នុងច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសក៏ដោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ៧៨.- ការកេណ្ឌ និងការបណ្តុះបណ្តាលភេរវករ**

១-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែល ដោយចេតនាចូលរួមក្នុង :

ក-ការកេណ្ឌមនុស្សឱ្យអង្គការ ដែលត្រូវបានបង្កើត ឬ ដែលនឹងត្រូវបានបង្កើតឡើង ដើម្បីគោលបំណងភេរវកម្ម ឬ

ខ-ការបណ្តុះបណ្តាលមនុស្ស ដើម្បីគោលបំណងភេរវកម្ម ។

២-សម្រាប់ចំណុច ក ឬ ចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ គោលបំណងភេរវកម្ម គឺ :

ក-គោលបំណងប្រព្រឹត្តបទល្មើស ដែលបញ្ញត្តក្នុងច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ-គោលបំណងប្រព្រឹត្តអំពើមួយ ដែលមានបំណងបង្កឱ្យមានមរណភាព ឬ របួសធ្ងន់ធ្ងរ ដល់រូបរាងកាយបុគ្គលណាម្នាក់ផ្សេងទៀត ក្រៅពីបុគ្គលដែលចូលរួមយ៉ាងសកម្មក្នុងអរិភាពប្រដាប់អាវុធ នៅក្នុងស្ថានភាពវិវាទប្រដាប់អាវុធ ប្រសិនបើគោលបំណងនៃអំពើនោះ តាមប្រភេទ និង បរិបទរបស់វា គឺដើម្បីបំភិតបំភ័យក្រុមណាមួយនៃប្រជាជន ឬ ដើម្បីបង្ខំ :

ខ.១-ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ខ.២-អង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ឬ

ខ.៣-បុគ្គលណាម្នាក់ ឬ ក្រុមមនុស្សណាមួយឱ្យធ្វើ ឬ មិនធ្វើនូវសកម្មភាពណាមួយ ។

## ផ្នែកទី ២

## ការបង្កក ការឃាត់ទុក និងការរឹបអូសទ្រព្យភេរវកម្ម

**មាត្រា ៧៩.- ការបង្កកទ្រព្យរបស់បុគ្គល**

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាសាលាដំបូង បង្កកទ្រព្យរបស់បុគ្គលណាមួយប្រសិនបើ :

ក-ឈ្មោះរបស់បុគ្គលនោះ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃបុគ្គលនិងអង្គភាព ដែលត្រូវបានរក្សាទុកដោយគណៈកម្មាធិការដែលត្រូវបានបង្កើតឡើង ក្រោមសេចក្តីសម្រេច លេខ ១២៦៧ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬ

ខ-បុគ្គលនោះគឺជា :

ខ.១-បុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលបញ្ញត្តនៅក្នុងច្បាប់នេះ ឬ បទល្មើសស្របគ្នានៅក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ.២-អង្គភាពដែលជាកម្មសិទ្ធិរបស់ ឬ ដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោល ដោយបុគ្គលនោះ ឬ

ខ.៣-បុគ្គល ឬ អង្គភាពដែលធ្វើសកម្មភាពជំនួសឱ្យ ឬ តាមបញ្ជារបស់បុគ្គលនោះ ។

២-ទ្រព្យរបស់បុគ្គល ដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះ រាប់បញ្ចូលមូលនិធិដែលបានមក ឬ បង្កើតបានពីទ្រព្យដែលជាកម្មសិទ្ធិរបស់ ឬ ដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោល ដោយបុគ្គល ឬ អង្គភាពខាងលើនេះ ។

៣-ប្រសិនបើទ្រព្យរបស់បុគ្គលណាមួយត្រូវបានបង្កកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលនោះអាចស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌តាមរយៈអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាសាលាដំបូង ដើម្បីសុំដកការបង្កកទ្រព្យនោះបានដោយសម្អាងលើមូលហេតុថា :

ក-ឈ្មោះរបស់បុគ្គលនោះ ត្រូវបានដាក់បញ្ចូលដោយកំហុសនៅក្នុងបញ្ជីដែលមានចែងក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះ ឬ

ខ-ទោះបីជាឈ្មោះបុគ្គលនោះដូចគ្នានឹងឈ្មោះនៅក្នុងបញ្ជីនោះក្តី ក៏បុគ្គលនោះមិនមែនជាបុគ្គលដែលមាននៅក្នុងបញ្ជីនោះឡើយ ឬ

គ-បុគ្គលនោះមិនមែនជាប្រភេទជនដែលមានចែងក្នុងចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើ ឬ

ឃ-ឈ្មោះរបស់បុគ្គលនោះ ត្រូវបានលុបចេញពីបញ្ជីនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៨០.- ការបង្កកទ្រព្យកខ្វក់**

១-តុលាការអាចបញ្ជាឱ្យបង្កកទ្រព្យ ប្រសិនបើតុលាការពិនិត្យឃើញថា មានមូល-ហេតុសមហេតុផលនឹងសង្ស័យថាទ្រព្យនោះគឺជាទ្រព្យកខ្វក់ ។

២-តុលាការត្រូវដកបទបញ្ជា ដែលត្រូវបានធ្វើឡើងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើពិនិត្យឃើញថាទ្រព្យនោះមិនមែនជាទ្រព្យកខ្វក់ទេ ។

**មាត្រា ៨១.- ការឃាត់ទុកទ្រព្យ**

អាជ្ញាធរអនុវត្តច្បាប់ ក្រោយពេលដឹងថាមានវត្តមាននៃទ្រព្យកខ្វក់ ត្រូវតែឃាត់ទុកទ្រព្យនោះ និងដោយគ្មានបង្អង់ ហើយយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន សុំបញ្ជាពាក់ព័ន្ធនឹងទ្រព្យនោះ តាមបញ្ញត្តិនៃមាត្រា ៨០ នៃច្បាប់នេះ ។

**មាត្រា ៨២.- ការរឹបអូសទ្រព្យ**

តុលាការអាចបញ្ជាឱ្យរឹបអូសដាក់ជាសម្បត្តិរដ្ឋ នូវទ្រព្យដែលត្រូវបានបង្កកតាមបញ្ញត្តិនៃមាត្រា ៧៩ ឬ មាត្រា ៨០ ខាងលើនេះ ប្រសិនបើតុលាការពិនិត្យឃើញ និងជឿជាក់ថាទ្រព្យនោះជាទ្រព្យកខ្វក់ ជាជាងទ្រព្យដែលមិនមែនជាទ្រព្យកខ្វក់ ។

**មាត្រា ៨៣.- ការចោទប្រកាន់ ឬ ការសម្រេចដាក់ទោសដែលមិនចាំបាច់**

សេចក្តីសម្រេចបង្កកទ្រព្យ តាមបញ្ញត្តិមាត្រា ៧៩ មាត្រា ៨០ ឬ ការឃាត់ទុកតាមបញ្ញត្តិមាត្រា ៨១ ឬ ការរឹបអូសទ្រព្យតាមបញ្ញត្តិមាត្រា ៨២ នៃច្បាប់នេះ អាចត្រូវបានធ្វើឡើងទោះបីជា :

ក-ពុំមានបុគ្គលណាម្នាក់ត្រូវបានចោទប្រកាន់ ឬ សម្រេចឱ្យជាប់ទោសពីបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ-បុគ្គលណាមួយត្រូវបានចោទប្រកាន់ ឬ ត្រូវបានសម្រេចឱ្យរួចទោសពីបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

45/7/...

## មាត្រា ៨៤.- ទ្រព្យបញ្ចូលគ្នា

នៅពេលណាដែលទ្រព្យដែលជា ឬ ត្រូវបានសង្ស័យដោយសមហេតុផលថាជាទ្រព្យកខ្វក់ត្រូវបានដាក់បញ្ចូលជាមួយទ្រព្យដទៃទៀត ដែលមិនមែនជាទ្រព្យកខ្វក់ នោះតម្លៃនៃទ្រព្យកខ្វក់ដែលត្រូវបានបង្កក ឬ ត្រូវបានរឹបអូសតាមបញ្ញត្តិមាត្រា ៨០ និងមាត្រា ៨២នៃច្បាប់នេះ ត្រូវតែមិនលើសពីតម្លៃនៃទ្រព្យដែលជា ឬ ត្រូវបានសង្ស័យ ដោយសមហេតុផលថាជាទ្រព្យកខ្វក់នោះឡើយ ។

## មាត្រា ៨៥.- បន្ទុករបស់ជនប្រឆាំងនឹងសេចក្តីសម្រេច

ជនដែលប្រឆាំងនឹងសេចក្តីសម្រេចតាមបញ្ញត្តិមាត្រា ៨០ និងមាត្រា ៨២ ខាងលើនេះ ដែលសុំដកទ្រព្យ ដែលត្រូវបានសម្រេចឱ្យបង្កក ឬរឹបអូស ឬ ដែលសុំបដិសេធសេចក្តីសម្រេចនេះ ត្រូវតែបង្ហាញតុលាការថាទ្រព្យនេះមិនមែនជាទ្រព្យកខ្វក់ ។

## មាត្រា ៨៦.- ការទុកជាមោឃៈនូវអំពើនានាដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការរឹបអូស ជាអាទិ៍

១-តុលាការអាចទុកជាមោឃៈ ឬ បដិសេធគ្រប់សារលិខិត ឬ ទង្វើទាំងឡាយ ទោះបីជាបង់កម្រៃ ឬ មិនបង់កម្រៃក្តី ដែលធ្វើឡើងក្នុងគោលបំណងបង្វែរទ្រព្យទាំងឡាយឱ្យផុតពីវិធានការបង្កក ឬរឹបអូស ។

២-ប្រសិនបើតុលាការទុកជាមោឃៈ ឬ បដិសេធដូចក្នុងកថាខណ្ឌទី ១ ខាងលើ នោះតុលាការអាចបញ្ជាឱ្យអ្នកម្ចាស់ដើមនៃទ្រព្យសងទៅអ្នកទិញវិញនូវតម្លៃតបស្នង ប្រសិនបើអ្នកទទួលទ្រព្យគឺសុចរិត ហើយបានប្រគល់តម្លៃតបស្នងរួចហើយ ។

## មាត្រា ៨៧.- ការលក់ដោយរដ្ឋនូវទ្រព្យដែលបានរឹបអូស

១-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែលក់ទ្រព្យដែលបានរឹបអូសណា ដែលមិនមែនជាសាច់ប្រាក់ អនុលោមតាមនីតិវិធីសម្រាប់ការលក់ទ្រព្យសម្បត្តិរដ្ឋ ។

២-ប្រាក់ដែលបានមកពីការលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ជាមួយនឹងទ្រព្យរឹបអូសដទៃទៀតដែលជាសាច់ប្រាក់ ត្រូវបង់ចូលទៅក្នុងមូលនិធិជាតិមួយ ដែលនឹងត្រូវបាន

ប្រើប្រាស់

ក-ដើម្បីទូទាត់បំណុល និងចំណាយស្របច្បាប់ទាំងអស់ ដែលកើតឡើងពីការរឹបអូសទ្រព្យកខ្វក់ រាប់បញ្ចូលការចំណាយលើការរឹបអូស ការដឹកជញ្ជូន ការទុកដាក់ និងការថែរក្សា និង

ខ-ដើម្បីសងជម្ងឺចិត្តដល់ជនរងគ្រោះនៃអំពើភេរវកម្ម ឬ

គ-ដើម្បីធ្វើហិរញ្ញប្បទានដល់សកម្មភាព ធ្វើឡើងដើម្បីប្រយុទ្ធនឹងភេរវកម្ម ។

៣-ការគ្រប់គ្រងមូលនិធិជាតិនេះ ត្រូវអនុលោមតាមវិធានដែលកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៨៨.- ការតាមដាន

១-ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរដែលទទួលបាននូវរឿងក្ដី ដែលជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ អាចអនុញ្ញាតឱ្យអ្នកស៊ើបអង្កេត ៖

ក-ពិនិត្យដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលនូវគណនីធនាគារ ឬ គណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ និង

ខ-តម្រូវឱ្យមានការត្រួតពិនិត្យ និងបង្គាប់ឱ្យផ្ដល់ ឬ ថតចម្លងលិខិតយថាភូត ឬ លិខិតឯកជន ឬ ឯកសារធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់ និង

គ-តាមដាន និងដាក់ខ្សែទូរស័ព្ទក្រោមការលបស្ដាប់ និង

ឃ-ចូលទៅពិនិត្យប្រព័ន្ធកុំព្យូទ័រ

ប្រសិនបើមានសញ្ញាធ្ងន់ល្មមសមឱ្យឃើញថាគណនី ខ្សែទូរស័ព្ទ ប្រព័ន្ធកុំព្យូទ័រទាំងនោះ កំពុងត្រូវបានប្រើប្រាស់ ឬ អាចយកទៅប្រើប្រាស់ ដោយបណ្ដាជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្ត ឬ មានផែនការប្រព្រឹត្តបទល្មើសណាមួយ ដែលមានបញ្ញត្តនៅក្នុងច្បាប់ ឬ កាលបើលិខិត ឬ ឯកសារទាំងនោះពាក់ព័ន្ធ ឬ អាចពាក់ព័ន្ធនឹងបទល្មើសណាមួយខាងលើនេះ ។

២-វិធានការខាងលើនេះ មិនត្រូវបានចាត់ទុកថាជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣-ការតាមដាន ការដាក់ខ្សែទូរស័ព្ទក្រោមការលបស្ដាប់ អាចអនុញ្ញាតបានតែក្នុងចិរវេលា ២ ខែ ។ ការបន្តវិធានការ និងចិរវេលានេះ ត្រូវបានអនុញ្ញាតតែដោយចៅក្រមស៊ើបសួរដែលកាន់រឿងនេះ ។

៤-ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ចំពោះបុគ្គលណាដែល :

ក-បានដឹងដោយសារការប្រកបវិជ្ជាជីវៈរបស់ខ្លួន អំពីការចាត់វិធានការណាមួយដែលមានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបាន ប្រាប់ដោយចេតនាដល់បុគ្គលដែលស្ថិតនៅក្រោមការសង្ស័យ អំពីការអនុវត្តសកម្មភាពទាំងនោះ ឬ

ខ-បានផ្ដល់ទៅអាជ្ញាធរមានសមត្ថកិច្ចនូវឯកសារ ឬ លិខិតដែលមានបញ្ញត្តក្នុងចំណុច ខ នៃកថាខណ្ឌទី ១ ខាងលើនេះ ដែលខ្លួនបានដឹងថាជាឯកសារក្លែងក្លាយ ឬ ឯកសារដែលមានការដកចេញខ្លះ ឬ ជាឯកសារភ័ន្តច្រឡំ ប៉ុន្តែមិនបានជម្រាបអាជ្ញាធរទាំងនោះឱ្យបានដឹង ។

**មាត្រា ៨៩.- ការសម្ងាត់វិជ្ជាជីវៈធនាគារ**

ការសម្ងាត់វិជ្ជាជីវៈធនាគារ ពុំមែនជាយុត្តិកម្មសម្រាប់បដិសេធមិនផ្ដល់ភស្តុតាងពាក់ព័ន្ធនឹងបទល្មើស ដែលបានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ ។

**មាត្រា ៩០.- ការបន្ទ្រាបខ្ទបវត្ថុនៃការបង្កក និងការរឹបអូស**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ចំពោះ បុគ្គលណាជាភាគី ឬ ដោយចេតនាសម្រួលការលក់ដូរទ្រព្យដែលត្រូវបានបង្កក ឬរឹបអូស តាមសេចក្ដីសម្រេច ដែលមានបញ្ញត្តនៅក្នុងផ្នែកនេះ លើកលែងតែ ការលក់ដូរដែលធ្វើឡើងតាមលក្ខខណ្ឌនៃផ្នែកនេះ ឬ ត្រូវបានអនុញ្ញាតដោយតុលាការ ។

# ជំពូកទី ១២
# បត្យាប័ន និងជំនួយទៅវិញទៅមក ទាក់ទងនឹងបទល្មើសភេរវកម្ម
## ផ្នែកទី ១
## សេចក្តីផ្តើម

**មាត្រា ៩១.– ការបកស្រាយ**

វាក្យស័ព្ទក្នុងជំពូកនេះ :

១-ជំនួយទៅវិញទៅមក មានន័យថាជាការជួយដែលត្រូវបានស្នើសុំដោយរាជរដ្ឋាភិបាលកម្ពុជា ឬ ដោយរដ្ឋាភិបាលនៃរដ្ឋបរទេសណាមួយទាក់ទងនឹង :

ក-ការស៊ើបអង្កេត ឬ ចំណាត់ការតុលាការចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ បទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

ខ-ការស៊ើបអង្កេត ឬ ចំណាត់ការទាក់ទងនឹងទ្រព្យកខ្វក់ ។

២-រដ្ឋផ្ញើសំណើ មានន័យថាជារដ្ឋមួយដែលស្នើសុំការធ្វើបត្យាប័នបុគ្គលណាម្នាក់ ឬ ស្នើសុំជំនួយទៅវិញទៅមក ។

**មាត្រា ៩២.– នៅពេលដែលបទល្មើសបរទេសស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ**

១-បទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ប្រសិនបើអំពើ ឬ ការគេចវេះខ្លះ ឬ ទាំងអស់ដែលជាបទល្មើសក្រោមច្បាប់របស់បរទេស និងជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ប្រសិនបើត្រូវបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-លក្ខខណ្ឌដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ទាក់ទងនឹងសំណើពីរដ្ឋបរទេសត្រូវបានបំពេញទោះបីជា :

ក-អំពើ ឬ ការគេចវេះ ដែលជាបទល្មើសត្រូវបែងចែកនៅក្នុងប្រភេទបទល្មើសមិនដូចគ្នា ឬ

ខ-ឈ្មោះបទល្មើស ការប្រើបច្ចេកសព្ទ ឬ និយមន័យ ឬ ការកំណត់លក្ខណៈ

បទល្មើសមិនដូចគ្នាក្តី និង

គ-ការកំណត់អំពីធាតុផ្សំនៃបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើខុសគ្នាអំពីធាតុផ្សំនៃបទល្មើស ដែលកំណត់ដោយច្បាប់នេះ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើ ឬ ការគេចវេះ ដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះត្រូវបានប្រព្រឹត្ត ។

### មាត្រា ៩៣.- បទល្មើសនយោបាយ និងសារពើពន្ធ

បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស នឹងពុំត្រូវបានចាត់ទុកថាជាបទល្មើសនយោបាយឡើយ ចំពោះបទល្មើសពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬ បទល្មើសដែលកើតឡើងដោយហេតុផលនយោបាយ ឬជាបទល្មើសសារពើពន្ធឡើយ សម្រាប់គោលបំណងធ្វើបត្យាប័ន និងជំនួយទៅវិញទៅមក ។

## ផ្នែកទី ២

## បត្យាប័ន

### មាត្រា ៩៤.- បត្យាប័នទៅកាន់ ឬ មកពីរដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមានសន្ធិសញ្ញាបត្យាប័នជាមួយ

បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស នឹងត្រូវបានចាត់ទុកជាបទល្មើសបត្យាប័ន ក្រោមសន្ធិសញ្ញាបត្យាប័នណាមួយរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ ។

### មាត្រា ៩៥.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ប៉ុន្តែជាភាគីមួយនៃអនុសញ្ញា ឬ ពិធីសារពាក់ព័ន្ធ

អនុសញ្ញា ឬ ពិធីសារ អាចបង្កើតបានជាមូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័នបុគ្គលណាម្នាក់ចេញពីព្រះរាជាណាចក្រកម្ពុជាទៅកាន់រដ្ឋបរទេស ឬ សម្រាប់ធ្វើសំណើដោយព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋបរទេសនោះ ទាក់ទងនឹងអំពើដែលអនុសញ្ញា ឬពិធីសារនោះ លើកឡើង ក្នុងករណីដែល :

ក-ព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋបរទេស និង

ខ-ទាំងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញា ឬ ពិធីសារដែលភ្ជាប់មកជាឧបសម្ព័ន្ធនៃច្បាប់នេះ និង

គ-អនុសញ្ញា ឬ ពិធីសារនោះ ចែងថាវាអាចផ្តល់មូលដ្ឋានច្បាប់សម្រាប់បត្យាប័ន ។

## មាត្រា ៩៦.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលប្រទេសកម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយ

ប្រទេសកម្ពុជា អនុលោមតាមច្បាប់ទាក់ទិននឹងបត្យាប័ន អាចធ្វើបត្យាប័នបុគ្គលណាមួយទៅឱ្យរដ្ឋធ្វើសំណើក្នុងករណីដែល :

ក-រាជរដ្ឋាភិបាលកម្ពុជា ទទួលសំណើពីរដ្ឋណាមួយសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើដែលបានបង្កជាបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសនោះ ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និង

ខ-ប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋធ្វើសំណើ ហើយ

គ-រដ្ឋធ្វើសំណើផ្តល់ការសន្យាថា ខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះ ពីព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៩៧.- ការបង្ហាញឯកសារសម្រាប់សំណើសុំធ្វើបត្យាប័ន

១-សំណើសុំធ្វើបត្យាប័នបុគ្គលណាមួយទៅកាន់រដ្ឋបរទេស ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរដែលភ្ជាប់ជាមួយ :

ក-ក្នុងគ្រប់ករណីទាំងអស់នូវ :

ក.១-ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ ក្នុងការពិពណ៌នាអត្តសញ្ញាណ និងទីកន្លែងប្រហាក់ប្រហែលនៃបុគ្គលដែលត្រូវបានតាមរក និង

ក.២-របាយការណ៍អំពីអង្គហេតុនៃករណីនេះ និង

ក.៣-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ដែលបង្កើតបទល្មើសនោះនិង

ក.៤-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ដែលកំណត់ទោសប្បញ្ញត្តិនិង

ក.៥-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ ដែលបញ្ជាក់ការកំណត់ពេលវេលាដែលពាក់ព័ន្ធ និង

ក.៦-ព័ត៌មានដទៃណាទៀតដែលចាំបាច់ត្រូវផ្តល់ជូន ក្រោមសន្ធិសញ្ញាដែលនៅក្នុងនោះព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេស គឺជាភាគី និង

ខ-ក្នុងករណីដែលបុគ្គលនោះត្រូវបានស្វែងរក ដើម្បីទទួលការអនុវត្តទោសដោយ :

ខ.១-សាលក្រម ឬ សេចក្តីចម្លងសាលក្រមមួយច្បាប់របស់តុលាការ និង

ខ.២-សេចក្តីថ្លែងការណ៍អំពីកម្រិតទោស ដែលការកាត់ទោសបានត្រូវអនុវត្ត ។

២-ឯកសារទាំងអស់ត្រូវតែត្រូវបានចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ ឬ អង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយនៃភាសាទាំងពីរនេះ ដែលមានសេចក្តីបញ្ជាក់ផង ។

## មាត្រា ៩៨.- មូលហេតុចាំបាច់សម្រាប់បដិសេធសំណើធ្វើបត្យាប័ន

១-រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថា :

ក-សំណើនោះត្រូវបានធ្វើឡើងដើម្បីកាត់ទោស ឬ ផ្តន្ទាទោសបុគ្គលណាម្នាក់ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

ខ-ស្ថានភាពរបស់បុគ្គលនោះ អាចត្រូវរងបុរេនិច្ឆ័យ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

គ-បុគ្គលនោះ ត្រូវបានកាត់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសណាមួយ ចំពោះបទល្មើសនោះ ហើយសាលក្រមបានចូលជាស្ថាពរ និងត្រូវបានអនុវត្តចំពោះបុគ្គលនោះហើយ ឬ

ឃ-បុគ្គលនោះត្រូវបានផ្តន្ទាទោសពីបទល្មើសនោះដោយកំបាំងមុខ និង :

ឃ.១-ដោយពុំមានការជូនព័ត៌មានគ្រប់គ្រាន់អំពីការកាត់ទោសនោះ ឬ ដោយបុគ្គលនោះពុំត្រូវបានផ្តល់ឱកាសឱ្យរៀបចំការការពារខ្លួន និង

ឃ.២-ដោយបុគ្គលនោះពុំមាន ឬ នឹងពុំមានឱកាសសុំឱ្យមានការកាត់ទោសករណីនោះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន ។

២-រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថានៅពេលប្រគល់ឱ្យទៅរដ្ឋបរទេសនោះ បុគ្គលនោះនឹងទទួលរងនូវការធ្វើទារុណកម្ម ។

## មាត្រា ៩៩.- បច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន

ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា ដោយមូលហេតុណាមួយបដិសេធការធ្វើបត្យា-ប័នបុគ្គលណាមួយ ទៅឱ្យរដ្ឋធ្វើសំណើ ក្រោយការពិចារណាសមស្របលើសំណើបត្យាប័ន :

ក-រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ជូនសំណុំរឿងនេះ ទៅឱ្យអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ដើម្បីគោលបំណងនៃការចោទប្រកាន់ និង

ខ-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ត្រូវតែធ្វើសេចក្តីសម្រេចចិត្តលើសំណុំរឿង ដូចគ្នានឹងករណីនៃបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ។

## មាត្រា ១០០.- បត្យាប័នដោយស្ម័គ្រចិត្ត

១-រាជរដ្ឋាភិបាលកម្ពុជា អាចយល់ព្រមដោយពុំចាំបាច់ធ្វើចំណាត់ការបត្យាប័នផ្លូវការឡើយ ចំពោះការធ្វើបត្យាប័នបុគ្គលណាមួយ ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ប្រសិនបើបុគ្គលនោះយល់ព្រមជាលាយល័ក្ខណ៍អក្សរ នៅចំពោះមុខតំណាងទទួលខុសត្រូវនៃអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ថា សុខចិត្តទទួលរងការធ្វើបត្យាប័នទៅកាន់រដ្ឋធ្វើសំណើចំពោះបទល្មើសនោះ ។

២-រាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រមចំពោះបត្យាប័នតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រានេះឡើយ លុះត្រាណាតែ :

ក-រដ្ឋធ្វើសំណើបានធ្វើសំណើផ្លូវការ សុំធ្វើបត្យាប័នបុគ្គលនោះ និង

ខ-មុនពេលដែលការយល់ព្រមត្រូវបានផ្ដល់ ជននោះត្រូវតែបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមលើបត្យាប័ន ។

## មាត្រា ១០១.- ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្ដោះអាសន្ន

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើ :

ក-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ទទួលសំណើពីរដ្ឋបរទេសណាមួយដោយផ្ទាល់ ឬ តាមរយៈការសម្របសម្រួលនៃអង្គការនគរបាល ព្រហ្មទណ្ឌអន្តរជាតិ សុំឱ្យធ្វើការចាប់ខ្លួនបុគ្គលណាម្នាក់បណ្ដោះអាសន្ន ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ហើយមានករណីណាមួយនៃករណីខាងក្រោមនេះ :

ក.១-ព្រះរាជាណាចក្រកម្ពុជា ជាភាគីនៃសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋដែលស្នើសុំជំនួយ ឬ

ក.២-ទាំងព្រះរាជាណាចក្រកម្ពុជា ទាំងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញា ឬ ពិធីសារដែលភ្ជាប់មកជាឧបសម្ព័ន្ធ ១ នៃច្បាប់នេះ និងអនុសញ្ញា ឬ ពិធីសារនោះ ចែងថាវាអាចផ្ដល់មូលដ្ឋានច្បាប់សម្រាប់បត្យាប័ន ឬ

ក.៣-រដ្ឋធ្វើសំណើផ្ដល់ការសន្យាថាខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះពីព្រះរាជាណាចក្រកម្ពុជា និង

ខ-រដ្ឋធ្វើសំណើសន្យានឹងផ្ញើជូនព្រះរាជាណាចក្រកម្ពុជានូវសំណើសុំធ្វើបត្យាប័នបុគ្គលនោះ ។

២-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ អាចចេញដីកាចាប់ខ្លួនបុគ្គលនោះ ប្រសិនបើពិនិត្យឃើញថា :

ក-បុគ្គលនោះ មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយ

ខ-[illegible]ជា :

ខ.១-តុលាការ ឬ អាជ្ញាធរនៅក្នុងរដ្ឋធ្វើសំណើបានចេញដីកា ឬបញ្ជា ដែលមានលក្ខណៈដូចគ្នា ដើម្បីចាប់ខ្លួនបុគ្គលនោះរួចហើយ ចំពោះបទល្មើសទាក់ទងនឹងសំណើចាប់ខ្លួនបណ្ដោះអាសន្ន ដែលត្រូវបានសុំនោះ ឬ

ខ.២-បុគ្គលនោះត្រូវបានសម្រេចឱ្យជាប់ទោសចំពោះបទល្មើសនោះរួចហើយ នៅក្នុងរដ្ឋធ្វើសំណើ ។

៣-ផ្អែកតាមកថាខណ្ឌទី ៤ ខាងក្រោមនេះ បុគ្គលដែលត្រូវចាប់ខ្លួន និងឃុំខ្លួនតាមដីកានឹងត្រូវឃុំខ្លួនតាមច្បាប់រហូតទាល់តែរដ្ឋធ្វើសំណើ ស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើបត្យាប័នបុគ្គលនោះ ។

៤-ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មិនបានទទួលសំណើសុំធ្វើបត្យាប័នពីរដ្ឋធ្វើសំណើក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបុគ្គលនោះត្រូវបានឃុំខ្លួនតាមដីកា អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ត្រូវតែចេញបញ្ជាឱ្យដោះលែងបុគ្គលនោះ ។

៥-បុគ្គល ដែលត្រូវបានដោះលែង យោងតាមកថាខណ្ឌទី ៤ ខាងលើនេះ អាចត្រូវចាប់ខ្លួនសាជាថ្មី ប្រសិនបើរដ្ឋធ្វើសំណើបញ្ជូនសំណើសុំធ្វើបត្យាប័ន បន្ទាប់ពីបុគ្គលនោះត្រូវបានដោះលែង ។

**មាត្រា ១០២.- បត្យាប័នមកពីរដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ**

១-រាជរដ្ឋាភិបាលកម្ពុជា អាចធ្វើសំណើទៅរដ្ឋបរទេសសុំធ្វើបត្យាប័នបុគ្គលណាមួយមកព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែល :

ក-បុគ្គលនោះ បានប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ :

ក.១-នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ក.២-នៅក្រៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែស្ថិតនៅក្នុងយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា តាមបញ្ញត្តិនៃច្បាប់នេះ ហើយ

ខ-ព្រះរាជាណាចក្រកម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋបរទេសដែលបុគ្គលនោះមានវត្តមាន ។

២-សំណើអាចត្រូវបានធ្វើឡើងផ្អែកលើមូលដ្ឋាននៃការផ្តល់ ដោយរាជរដ្ឋាភិបាលកម្ពុជានូវការសន្យាថាខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះពីរដ្ឋបរទេសដែលបុគ្គលនោះមានវត្តមាន ។

## ផ្នែកទី ៣

## ជំនួយទៅវិញទៅមក

### មាត្រា ១០៣.- សំណើរបស់រដ្ឋបរទេស ចំពោះព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា ទទួលសំណើពីរដ្ឋបរទេសណាមួយ សុំជំនួយទាក់ទងនឹង :

ក-ការស៊ើបអង្កេតបទល្មើសនៅក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

ខ-ចំណាត់ការរឿងក្តីតុលាការ ចំពោះបទល្មើសនេះ ឬ

គ-ការស៊ើបអង្កេតទាក់ទិននឹងទ្រព្យកខ្វក់ ឬ

ឃ-ចំណាត់ការសម្រាប់ការបង្កកឬការរឹបអូសទ្រព្យកខ្វក់នៅក្នុងរដ្ឋធ្វើសំណើ ឬ

ង-ការបង្កក ឬ ការរឹបអូសទ្រព្យកខ្វក់នៅក្នុងប្រទេសកម្ពុជា ។

២-តាមរយៈតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតនោះ រាជរដ្ឋាភិបាលកម្ពុជា អាចផ្តល់ជំនួយតាមវិធីណាមួយដូចខាងក្រោម :

ក-ធ្វើកំណត់ហេតុភស្តុតាងជាលាយល័ក្ខណ៍អក្សរ ឬ ដោយសួរផ្ទាល់មាត់ពីបុគ្គលនានា ។

ខ-ជួយឱ្យបុគ្គលទាំងនោះ រួមទាំងបុគ្គលដែលត្រូវបានឃុំខ្លួន ដោយមានការយល់ព្រមរបស់ខ្លួន ឱ្យបានផ្តល់ភស្តុតាង ឬ ឱ្យជួយក្នុងការស៊ើបអង្កេត ។

គ-ផ្តល់ឯកសារតុលាការ ។

ឃ-អនុវត្តការឆែកឆេរ ។

ង-ជួយក្នុងការតាមដានរកទ្រព្យកខ្វក់ ។

ច-ស៊ើបអង្កេតការជួញដូរហិរញ្ញវត្ថុ ។

ឆ-ទទួលព័ត៌មាន ឬ ភស្តុតាងដែលអាចជួយក្នុងការស្តារឡើងវិញនូវទ្រព្យកខ្វក់ដើម្បី [illegible]

ជ-បង្កកទ្រព្យកខ្វក់ដើម្បីទប់ស្កាត់ការលក់ដូរ ឬ ការផ្ទេរ ឬ ការបោះបង់ចោល



56/71/ស

ទ្រព្យដែលរង់ចាំការសម្រេចអំពីការដកហូត ។

ឈ-រឹបអូសទ្រព្យសម្បត្តិកខ្វក់ រួមទាំងឯកសារ ។

ញ-អនុវត្តសេចក្ដីសម្រេចចុងក្រោយរបស់រដ្ឋបរទេសក្នុងការរឹបអូសទ្រព្យកខ្វក់ ។

ដ-កោសល្យវិច័យវត្ថុតាង និងកន្លែងកើតហេតុ ។

ឋ-ផ្ដល់ព័ត៌មាន និងវត្ថុតាងដល់រដ្ឋបរទេស ។

ឌ-ផ្ដល់ឯកសារដើម ឬច្បាប់ចម្លងដែលត្រូវមានបញ្ជាក់នៃឯកសារ ឬកំណត់ហេតុពាក់ព័ន្ធ រួមមានឯកសារធនាគារ ហិរញ្ញវត្ថុ សាជីវកម្ម ឬ អាជីវកម្ម ជាអាទិ៍ដល់រដ្ឋបរទេស ។

៣-ព័ត៌មាន និងវត្ថុតាងដែលអាចត្រូវបានផ្ដល់ឱ្យរដ្ឋបរទេស យោងតាមកថាខណ្ឌទី ២ ចំណុច ឋ ខាងលើនេះ រួមមានព័ត៌មានដែលទទួលបានស្របច្បាប់ទាំងអស់ រួមទាំងព័ត៌មានដែលបានមកដោយការលួចយកពីបណ្ដាញទូរគមនាគមន៍ ឬ ដោយការប្រើឧបករណ៍លបស្ដាប់ ។

៤-ដើម្បីអនុវត្តសំណើសុំជំនួយពីរដ្ឋបរទេស នីតិវិធី និងដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការស៊ើបអង្កេត ឬ ការចោទប្រកាន់ចំពោះបទល្មើស តាមបញ្ញត្តិនៃច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អាចត្រូវបានប្រើប្រាស់ សម្រាប់ការផ្ដល់ជំនួយដល់រដ្ឋបរទេស ។

### មាត្រា ១០៤.- ជំនួយអាចត្រូវបានផ្ដល់ជូនផ្អែកលើលក្ខខណ្ឌ

រាជរដ្ឋាភិបាលកម្ពុជាអាចផ្ដល់ជំនួយដល់រដ្ឋបរទេសនៅក្រោមជំពូកនេះ ផ្អែកលើលក្ខខណ្ឌ ។

### មាត្រា ១០៥.- មូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើសុំជំនួយ

រាជរដ្ឋាភិបាលកម្ពុជានឹងមិនត្រូវយល់ព្រម តាមសំណើសុំជំនួយទាក់ទងនឹងបទល្មើសក្នុងបញ្ញត្តិនៃជំពូកនេះ ប្រសិនបើយល់ឃើញថា :

ក-សំណើនោះត្រូវបានធ្វើឡើង ដើម្បីកាត់ទោស ឬ ផ្តន្ទាទោសបុគ្គលណាម្នាក់ ដោយសារតែពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

ខ-ស្ថានភាពរបស់បុគ្គលនោះអាចត្រូវរងបុរេនិច្ឆ័យ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

គ-ជាសំណើទាក់ទងទៅនឹងការកាត់ទោសបុគ្គលនោះ ចំពោះបទល្មើស ហើយ

គ.១-បុគ្គលនោះ ត្រូវបានសម្រេចឱ្យរួចទោស ឬ លើកលែងទោស ដោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋបរទេស ឬ

គ.២-បុគ្គលនោះបានទទួលទោសតាមបញ្ញត្តិចែងដោយច្បាប់នៃរដ្ឋនោះ ចំពោះបទល្មើសនោះ ឬ ចំពោះបទល្មើសដទៃទៀត ដែលជាអំពើដូចគ្នានឹងបទល្មើសនោះរួចហើយ ។

## មាត្រា ១០៦.- វិធាននៃការសម្ងាត់ធនាគារមិនប៉ះពាល់ដល់ជំនួយទៅវិញទៅមកឡើយ

ការស្នើសុំជំនួយតាមបញ្ញត្តិនៃផ្នែកនេះ មិនត្រូវបានបដិសេធដោយសារហេតុផលនៃវិធាននៃការសម្ងាត់របស់ធនាគារឡើយ ។

## មាត្រា ១០៧.- សំណើសុំផ្តល់ភស្តុតាងនៅក្នុងសវនាការនៅក្នុងរដ្ឋបរទេស

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើ :

ក-សវនាការទាក់ទងនឹង :

ក.១-បទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

ក.២-ការបង្កក ឬ ការរឹបអូសទ្រព្យកខ្វក់ បានចាប់ផ្តើមនៅក្នុងរដ្ឋ

[illegible]

ខ-រដ្ឋបរទេសនោះស្នើសុំឱ្យមានការចូលរួមនៅក្នុងសវនាការ ទាក់ទងនឹងដំណើរការកាត់ក្តី ឬ បុគ្គលណាមួយដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង

គ-មានមូលហេតុសមហេតុផលនឹងជឿថាបុគ្គលនោះមានសមត្ថភាពក្នុងការ

ផ្តល់ភស្តុតាងពាក់ព័ន្ធនឹងដំណើរការកាត់ក្តី ហើយនិង

ឃ-បុគ្គលនោះ បានយល់ព្រមផ្តល់ភស្តុតាងនៅក្នុងរដ្ឋបរទេស ។

២-រដ្ឋបរទេសត្រូវតែផ្តល់ការសន្យាដូចខាងក្រោម :

ក-បុគ្គលនោះ នឹងមិន :

ក.១-ត្រូវបានឃុំខ្លួន កាត់ទោស ឬ ផ្តន្ទាទោស ចំពោះបទល្មើសណាមួយប្រឆាំងនឹងច្បាប់របស់រដ្ឋបរទេស ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្ត ឬ ដែលបានប្រព្រឹត្តមុនពេលបុគ្គលនោះ ចាកចេញពីព្រះរាជាណាចក្រកម្ពុជា ឬ

ក.២-ត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណីណាមួយ ចំពោះអំពើ ឬ ការគេចវេះរបស់បុគ្គលនោះ ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើង ឬ ដែលបានកើតឡើង មុនពេលបុគ្គលនោះចាកចេញពីព្រះរាជាណាចក្រកម្ពុជា ប្រសិនបើបុគ្គលនោះមិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលបុគ្គលនោះ មិនស្ថិតនៅក្នុងរដ្ឋបរទេសនោះទេ ឬ

ក.៣-ត្រូវបានតម្រូវឱ្យផ្តល់ភស្តុតាងក្នុងដំណើរការកាត់ក្តីផ្សេងទៀត ក្នុងរដ្ឋបរទេស ក្រៅពីដំណើរការកាត់ក្តីដែលពាក់ព័ន្ធនឹងសំណើនោះ ។

លើកលែងតែបុគ្គលនោះ បានចាកចេញពីរដ្ឋបរទេស ឬ បុគ្គលនោះមានឱកាសចាកចេញពីរដ្ឋបរទេស ហើយបែរជាស្ថិតនៅក្នុងរដ្ឋបរទេសនោះតទៅទៀត ក្រៅពីគោលបំណងផ្តល់ភស្តុតាងក្នុងដំណើរការកាត់ក្តី ដែលពាក់ព័ន្ធនឹងសំណើនោះ ។

ខ-ភស្តុតាងណាដែលបុគ្គលនោះផ្តល់ឱ្យក្នុងដំណើរការកាត់ក្តីដែលពាក់ព័ន្ធនឹងសំណើនោះ មិនអាចទទួលយកបាន ឬ មិនបានការ សម្រាប់ការកាត់ទោសជនល្មើសប្រឆាំងនឹងច្បាប់នៃរដ្ឋបរទេសនោះ មិនមែនជាបទល្មើសផ្តល់សក្ខីភាពក្លែងក្លាយ ចំពោះការផ្តល់ភស្តុតាងទាំងនោះ ។

គ-បុគ្គលនោះនឹងត្រូវបានបញ្ជូនមកប្រទេសកម្ពុជាវិញ យោងតាមការព្រមព្រៀង ដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា ។

ឃ-ប្រសិនបើបុគ្គលនោះ កំពុងស្ថិតនៅក្នុងការឃុំខ្លួននៅក្នុងប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាស្នើសុំរដ្ឋបរទេសឱ្យធ្វើការចាត់ចែង ដើម្បីរក្សាបុគ្គលនោះឱ្យស្ថិតក្នុងការឃុំខ្លួន នៅពេលដែលបុគ្គលនោះស្ថិតនៅក្នុងរដ្ឋបរទេសនោះ :

ឃ.១-រដ្ឋនោះត្រូវធ្វើការរៀបចំសមស្របសម្រាប់គោលបំណងនេះ ហើយ

ឃ.២-បុគ្គលនោះ នឹងមិនត្រូវបានដោះលែងពីការឃុំខ្លួន ក្នុងរដ្ឋបរទេសឡើយ លុះត្រាណាតែរាជរដ្ឋាភិបាលកម្ពុជាជូនដំណឹងដល់អាជ្ញាធរសមស្របនៃរដ្ឋបរទេសនោះថាបុគ្គលនោះទទួលបានសិទ្ធិត្រូវដោះលែង តាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង

ឃ.៣-ប្រសិនបើបុគ្គលនោះ ត្រូវបានដោះលែងនៅក្នុងរដ្ឋបរទេស ដូចបានចែងនៅក្នុង ឃ-២ នៃចំណុច ឃ ខាងលើនេះ រដ្ឋបរទេសនោះ ត្រូវទទួលបន្ទុកចំណាយលើការស្នាក់នៅ និងចំណាយផ្សេងៗរបស់បុគ្គលនោះរហូតដល់ចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងសំណើនោះត្រូវបានបញ្ចប់ ។

## មាត្រា ១០៤.– សំណើដោយប្រទេសកម្ពុជា ចំពោះរដ្ឋបរទេសមួយដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការ

១-រាជរដ្ឋាភិបាលកម្ពុជាអាចស្នើសុំរដ្ឋបរទេសណាមួយឱ្យផ្តល់ជំនួយទាក់ទងនឹង :

ក-ការស៊ើបអង្កេតបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

ខ-ចំណាត់ការតុលាការ ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

គ-ការស៊ើបអង្កេតទាក់ទងនឹងទ្រព្យកខ្វក់ ឬ

ឃ-ចំណាត់ការដើម្បីបង្កក ឬ ការរឹបអូសទ្រព្យកខ្វក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ង-ការបង្កក ឬ ការរឹបអូសទ្រព្យកខ្វក់នៅក្នុងប្រទេសដែលត្រូវបានស្នើសុំ ។

២-សំណើអាចត្រូវបានធ្វើឡើងដើម្បីសុំជំនួយ នៅក្នុងករណីណាមួយដែលមានចែងក្នុងកថាខណ្ឌទី ២ មាត្រា ១០៣ នៃច្បាប់នេះ ។

៣-ភស្តុតាងដែលទទួលបានដោយស្របច្បាប់នៅក្នុងរដ្ឋបរទេស អាចត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងចំណាត់ការរឿងក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤-ប្រសិនបើបុគ្គលមួយរូបដែលកំពុងត្រូវបានឃុំខ្លួននៅក្នុងរដ្ឋបរទេស ត្រូវបានឱ្យ[illegible]នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយរដ្ឋបរទេសនោះស្នើសុំឱ្យរាជរដ្ឋាភិបាល



60/Hw

កម្ពុជាចាត់ចែងដើម្បីរក្សាបុគ្គលនោះ ក្នុងការឃុំខ្លួននៅពេលដែលបុគ្គលនោះ ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា :

ក-ត្រូវធ្វើការចាត់ចែងសមស្របសម្រាប់គោលបំណងនោះ ឬ

ខ-មិនត្រូវដោះលែងបុគ្គលនោះពីការឃុំខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែរដ្ឋបរទេសជូនដំណឹងដល់អាជ្ញាធរសមស្របនៃរាជរដ្ឋាភិបាលកម្ពុជាថា បុគ្គលនោះទទួលបានសិទ្ធិត្រូវដោះលែង ក្រោមច្បាប់នៃរដ្ឋបរទេសនោះ ហើយ

គ-ប្រសិនបើបុគ្គលនោះត្រូវបានដោះលែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងចំណុច ខ ខាងលើនេះ ត្រូវទូទាត់ចំណាយលើការស្នាក់នៅ និងចំណាយផ្សេងៗរបស់បុគ្គលនោះ រហូតដល់ចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងសំណើនោះ ត្រូវបានបញ្ចប់ ។

៥-បុគ្គលណាដែលត្រូវបានឱ្យផ្តល់ភស្តុតាងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយរដ្ឋបរទេស ត្រូវតែបានបញ្ជូនទៅកាន់រដ្ឋនោះវិញ ដោយពុំចាំបាច់មានចំណាត់ការបត្យាប័នយោងតាមការព្រមព្រៀងដែលត្រូវបានឯកភាពជាមួយរដ្ឋបរទេសនោះ ។

**មាត្រា ១០៩.- សហប្រតិបត្តិការអន្តរជាតិ**

បទប្បញ្ញត្តិដែលមានចែងក្នុងផ្នែកទី ៣ នេះ មិនបានកំណត់ ឬ រាំងចំពោះការផ្តល់ ឬ ការទទួលព័ត៌មាន ឬ សហប្រតិបត្តិការអន្តរជាតិទាក់ទងនឹងបទល្មើសណាមួយ តាមបញ្ញត្តិនៃច្បាប់នេះ ឬ បទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ទោះជាវិធីណាក៏ដោយ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ១១០.- ទំនាក់ទំនងជាមួយច្បាប់ផ្សេងទៀត**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១១១.- ការអនុវត្ត**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២០* ខែ*កក្កដា* ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ព/រល.០៧០៧.៣១១* **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ *៣០៥* ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញថ្ងៃទី ខែ*កក្កដា* ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ចិនកេន**

# ឧបសម្ព័ន្ធ ១

ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការប្រឆាំងនឹងភេរវកម្ម

## បញ្ជីនៃអនុសញ្ញានិងពិធីសារអន្តរជាតិរបស់អង្គការសហប្រជាជាតិ

១-អនុសញ្ញាស្ដីពីបទល្មើសនិងសកម្មភាពផ្សេងៗទៀតដែលបានប្រព្រឹត្តនៅលើយន្តហោះ (ក្រុងតូក្យូ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៦៣) ។

២-អនុសញ្ញាពហុភាគីសម្រាប់ការបង្ក្រាបលើការចាប់ជំរិតយន្តហោះដោយខុសច្បាប់ (ក្រុងឡាអេ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧០) ។

៣-អនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល (ក្រុងម៉ុងរ៉េអាល់ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧១) ។

៤-ពិធីសារស្ដីពីការបង្ក្រាបអំពើហិង្សាខុសច្បាប់នៅតាមអាកាសយានដ្ឋានដែលបម្រើអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ឆ្នាំ ១៩៧១) ។ បន្ថែមលើអនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល (ក្រុងម៉ុងរ៉េអាល់ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧១) ។

៥-អនុសញ្ញាស្ដីពីការទប់ស្កាត់ និងដាក់ទោសទៅលើឧក្រិដ្ឋកម្មទាំងឡាយប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ (ក្រុងញូវយ៉ក ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៣) ។

៦-អនុសញ្ញាអន្តរជាតិប្រឆាំងនឹងអំពើចាប់ជាចំណាប់ខ្មាំង (ក្រុងញូវយ៉ក ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៩) ។

៧-អនុសញ្ញាស្ដីពីការការពាររូបកាយពីសារធាតុនុយក្លេអ៊ែរ (ក្រុងវីយ៉ែន ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៩) ។

៨-អនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃនាវាចរណ៍តាមផ្លូវសមុទ្រ (ក្រុងរ៉ូម ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨) ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៩-ពិធីសារស្តីពីការបង្ក្រាបអំពើខុសច្បាប់នឹងសុវត្ថិភាពនៃទីតាំងអចល័ត នៅតាមខ្ពង់រាបបាតសមុទ្រ (ក្រុងរ៉ូម ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨) ។

១០-អនុសញ្ញាស្តីពីការកំណត់សញ្ញាសម្គាល់នៃគ្រឿងផ្ទុះផ្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក (ក្រុងម៉ុងរ៉េអាល់ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៩១) ។

១១-អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់បំផ្ទុះគ្រាប់បែកភេរវកម្ម (ក្រុងញូវយ៉ក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៨) ។

១២-អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានភេរវកម្ម (ក្រុងញូវយ៉ក ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០) ។

១៣-អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ (ខែ មេសា ឆ្នាំ ២០០៥) ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ឧបសម្ព័ន្ធ ២

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម

## ការកំណត់ប្រភេទវត្ថុធាតុនុយក្លេអ៊ែរ

| ល.រ | សារធាតុ | ទម្រង់ | ប្រភេទី១ | ប្រភេទី២ | ប្រភេទី៣ |
|---|---|---|---|---|---|
| ១ | ភ្លុយតូនីញ៉ូម Plutonium[1] | មិនសាយភាយចំហាយ Unirradiated[2] | ២ គក្រ ឬលើស | តិចជាង ២គក្រ តែលើសពី៥០០ក្រ | ៥០០ ក្រ ឬ តិចជាង តែលើសពី ១៥ក្រ |
| ២ | អ៊ុយរ៉ានីញ៉ូម - ២៣៥ Uranium-235 | មិនសាយភាយចំហាយ-អ៊ុយរ៉ានីញ៉ូមបង្កើនកម្រិតដល់ ២០% ២៣៥ U ឬ លើស Unirradiated[2] - uranium enriched to 20% 235U or more | ៥ គក្រ ឬ លើស | តិចជាង ៥ គក្រ តែលើសពី ១គក្រ | ១ គក្រ ឬ តិចជាង តែលើសពី ១៥ ក្រ |
| | | អ៊ុយរ៉ានីញ៉ូមបង្កើនកម្រិតដល់ ១០% ២៣៥U តែតិចជាង២០% - uranium enriched to 10% 235U but less than 20% | | ១០ គក្រ ឬលើស | តិចជាង ១០ គក្រ តែលើសពី ១ គក្រ |
| | អ៊ុយរ៉ានីញ៉ូម - ២៣៣ Uranium-233 | អ៊ុយរ៉ានីញ៉ូមបង្កើនកម្រិតលើសពីធម្មជាតិតែតិចជាង ១០% ២៣៥U | | | ១០ គក្រ ឬលើស |

05/7/08

| ល.រ | សារធាតុ | ទម្រង់ | ប្រភេទ១ | ប្រភេទ២ | ប្រភេទ៣ |
|---|---|---|---|---|---|
| | | - uranium enriched above natural, but less than 10% 235U | | | |
| | | មិនសាយភាយចំហាយ Unirradiated[2] | ២ គក្រ ឬលើស | តិចជាង ២ គក្រតែលើសពី៥០០ក្រ | ៥០០ ក្រ ឬតិចជាងតែលើសពី ១៥ ក្រ |
| ៤ | ឥន្ធនៈដែលសាយភាយចំហាយ Irradiated fuel | | | ត្រូវបានបន្ថយកម្រិត ឬ អ៊ុយរ៉ានីញ៉ូមធម្មជាតិ -thorium ឬឥន្ធនៈបង្កើនកម្រិតទាប (កម្រិតផ្ទុះតិចជាង ១០%) Depleted or natural uranium, thorium or low-enriched fuel (less than 10% fissile content)[4] | |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

*កំណត់សម្គាល់:*

១-ភ្លុយតូនីញ៉ូមទាំងអស់ ក្រៅពីភ្លុយតូនីញ៉ូម ដែលមានកំហាប់អ៊ីសូតូបលើសពី ៨០% ក្នុងភ្លុយតូនីញ៉ូម-២៣៨

២-វត្ថុធាតុ មិនសាយភាយចំហាយនៅក្នុងរ៉េអាក់ទ័រ (Reactor) ឬ សារធាតុសាយភាយ ចំហាយនៅក្នុងរ៉េអាក់ទ័រ ប៉ុន្តែមានកម្រិត ចំហាយភាយចេញស្មើនឹង ឬ តិចជាង ១០០rads/ ១ ម៉ោង (100 rads/hour) នៅចម្ងាយ ១ ម៉ែត្រ ដោយគ្មានរបាំងការពារ ។

៣-បរិមាណមិនធ្លាក់ចុះដល់ប្រភេទ ៣ ហើយអ៊ុយរ៉ានីញ៉ូមធម្មជាតិ ត្រូវតែត្រូវបានការពារ យោងតាមការគ្រប់គ្រងដោយប្រុងប្រយ័ត្ន ។

៤-ឥន្ធនៈដទៃទៀត ដែលដោយសារតែបរិមាណសារធាតុផ្ទុះដើមរបស់វាត្រូវបានចាត់ថ្នាក់ជាប្រភេទ ១ និងប្រភេទ ២ មុនពេលការសាយភាយចំហាយ អាចត្រូវបានបន្ថយកម្រិតប្រភេទវាមួយកម្រិត នៅពេលដែលកម្រិតសាយភាយពីឥន្ធនៈនោះ លើសពី ១០០ rads/១ ម៉ោង (100 rads/hour) នៅចម្ងាយ ១ ម៉ែត្រ ដោយគ្មានរបាំងការពារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ឧបសម្ព័ន្ធ ៣

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម

## សារធាតុរកគ្រឿងផ្ទុះ

| ល.រ | ឈ្មោះសារធាតុរកគ្រឿងផ្ទុះ | រូបមន្ត ម៉ូលេគុល | ម៉ាស់ ម៉ូលេគុល | កំហាប់ អប្បបរិមា |
|---|---|---|---|---|
| ១ | អេទីឡែន ហ្គលីកុល ឌីនីត្រាត (អ៊ីហ្សេដេអិន)<br>Ethylene glycol dinitrate (EGDN) | $C_2H_4(NO_3)_2$ | ១៥២ | ០,២%គិតតាមម៉ាស់ |
| ២ | ២,៣-ឌីម៉េទីល២,៣ ឌីណីត្រូប៊ុយតាន (ដេអឹមដេបេ)<br>2,3–Dimethyl2,3 dinitro butane (DMDB) | $C_6H_{12}(NO_2)_2$ | ១៧៦ | ១,០%គិតតាមម៉ាស់ |
| ៣ | ប៉ារ៉ា-ម៉ូណូនីត្រូតូលុយអែន (ប៉េ-អឹមអិនតេ)<br>para-Mononitrotoluene (p–MNT) | $C_7H_7NO_2$ | ១៣៧ | ០,៥%គិតតាមម៉ាស់ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# សេចក្តីពន្យល់

# ច្បាប់

# ស្តីពី

# ការប្រឆាំងនឹងភេរវកម្ម

រៀបរៀងដោយ

ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា

និង

ក្រសួងអគ្គរដ្ឋអាជ្ញា នៃប្រទេសអូស្ត្រាលី

ឆ្នាំ ២០០៨

# ឧបសម្ព័ន្ធ ៤

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម

## គ្រឿងផ្ទុះខ្លាំង

**គ្រឿងផ្ទុះខ្លាំង រួមមាន៖**

- ស៊ីក្លូតេត្រាម៉េទីលឡែណេតេត្រានីត្រាមីន (cyclotetramethylenetetranitramine (HMX))
- ប៉ង់ត្រាវីទ្រីតូល តេត្រានីត្រាត (pentraerythritol tetranitrate (PETN))
- ស៊ីក្លូទ្រីមេទីឡែណេទ្រីនីត្រាមីន (cyclotrimethylenetrinitramine (RDX))

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ការអនុវត្តច្បាប់ស្តីពីការប្រឆាំងភេរវកម្ម

ភេរវកម្មគឺជាការគម្រាមកំហែងចំពោះសន្តិភាព ស្ថេរភាព សន្តិសុខ និងវិបុលភាពសេដ្ឋកិច្ច។ វាគឺជាប្រការសំខាន់ដែលប្រទេសទាំងឡាយត្រូវមានក្របខ័ណ្ឌគតិយុត្តិ ដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងស្ថានភាពភេរវកម្ម ដើម្បីការពារប្រជាជន ទ្រព្យសម្បត្តិ និងផលប្រយោជន៍ជាតិ។

អនុសញ្ញា និងពិធីសារចំនួន ១៣ របស់អង្គការសហប្រជាជាតិ និងសេចក្តីសម្រេចបន្ថែមមួយចំនួនទៀតរបស់ក្រុមប្រឹក្សាសន្តិសុខ ផ្តល់នូវក្របខ័ណ្ឌគតិយុត្តិដែលបានឯកភាពគ្នាជាអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្មឱ្យមានប្រសិទ្ធិភាព។ ច្បាប់ស្តីពីការប្រឆាំងភេរវកម្មនេះអនុវត្តអនុសញ្ញា ពិធីសារ និងសេចក្តីសម្រេចទាំងនេះ។ ច្បាប់នេះកំណត់បទល្មើស ចែងពីការបង្កក និងការរឹបអូសទ្រព្យ និងមានយន្តការសម្រាប់កិច្ចសហប្រតិបត្តិការច្បាប់អន្តរជាតិ។ ច្បាប់នេះគឺជាច្បាប់ឯកទេស (ច្បាប់ពិសេស) មួយ ដែលមានអាទិភាពលើច្បាប់ដទៃទៀតក្នុងករណីមានភាពមិនស្របគ្នា។

អំពើដែលគឺជាបទល្មើសតាមបញ្ញត្តិច្បាប់នេះ ក៏អាចគឺជាបទល្មើសផងដែរស្របតាមបញ្ញត្តិច្បាប់កម្ពុជាផ្សេងទៀត។ ជាធម្មតា អំពើត្រូវចាត់ចែងស្របតាមបញ្ញត្តិច្បាប់នេះមុនច្បាប់ផ្សេងទៀតដោយសារលក្ខណៈឯកទេសនៃច្បាប់នេះ។ ប៉ុន្តែ អាចមានករណីដែលនៅក្នុងនោះវាគឺជាប្រការសមស្របជាងដែលត្រូវប្រើច្បាប់ផ្សេងទៀត ឧទាហរណ៍ នៅពេលណាដែលបុគ្គលដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើសនោះ មិនមានចេតនាប្រព្រឹត្តបទល្មើសដើម្បីគោលបំណង "ភេរវកម្ម"។

បច្ចុប្បន្ននេះ គេពុំឃើញមាននិយមន័យឯកភាពគ្នាតែមួយនៃពាក្យ "ភេរវករ" ឬ "ភេរវកម្ម" នៅក្នុងច្បាប់អន្តរជាតិឡើយទេ។ ប៉ុន្តែ អនុសញ្ញា ពិធីសារ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងភេរវកម្ម ផ្តល់នូវការណែនាំមួយចំនួន។ ឧទាហរណ៍ *អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបហិរញ្ញប្បទានភេរវកម្ម* ត្រូវអនុវត្តចំពោះអំពើមួយចំនួនដែលនៅក្នុងនោះ គោលបំណងនៃអំពើនោះយោងតាមប្រភេទឬបរិបទរបស់វា គឺសំដៅ:

> *បំភិតបំភ័យប្រជាជនមួយ ឬ សំដៅបង្ខំរដ្ឋាភិបាលមួយ ឬ អង្គការអន្តរជាតិមួយ ឱ្យធ្វើឬមិនធ្វើសកម្មភាពណាមួយ។*

ការប្រើពាក្យដូចគ្នា ត្រូវបានប្រើនៅក្នុងលិខិតូបករណ៍ប្រឆាំងភេរវកម្មផ្សេងទៀត ដូចជា *សន្ធិសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើភេរវកម្មទុយក្ញៃអ៊េរ* និងសេចក្តីសម្រេចលេខ ១៥៦៦ របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។ ការមានឯកសារយោងដល់លិខិតូបករណ៍ទាំងនេះ និងអនុសញ្ញា ពិធីសារ និងសេចក្តីសម្រេចផ្សេងទៀតរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងភេរវកម្ម នឹងជួយក្នុងការបកស្រាយច្បាប់នេះ និងក្នុងការសម្រេចថាតើគេគប្បីប្រើច្បាប់នេះនៅពេលណា។

# ជំពូកទី ១ ~ បទប្បញ្ញត្តិទូទៅ

## មាត្រា ១.- គោលបំណង

មាត្រានេះចែងពីគោលបំណងនៃច្បាប់នេះ ដែលសំដៅដាក់ទោសព្រហ្មទណ្ឌលើអំពើមួយចំនួនតាមការកំណត់ដោយអនុសញ្ញា និងពិធីសារទាំង ១៣ របស់អង្គការសហប្រជាជាតិ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងភេរវកម្ម។ ច្បាប់នេះក៏អនុវត្តផងដែរនូវទិដ្ឋភាពខ្លះនៃអនុសាសន៍ និងអនុសាសន៍ពិសេសរបស់ក្រុមការងារសកម្មភាពហិរញ្ញវត្ថុស្តីពីការសំអាតប្រាក់ (FATF) ។

បន្ថែមលើការកំណត់ជាបទល្មើសដែលកំណត់ដោយអនុសញ្ញា និងពិធីសារទាំងនោះ ច្បាប់នេះចែងពីកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ ការបង្កកទ្រព្យយោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងការរឹបអូសទ្រព្យ។

ថ្វីបើច្បាប់នេះមានអាទិភាពទៅលើច្បាប់ដទៃទៀតដែលមិនមានសង្គតិភាព (ភាពស្របគ្នា) ជាមួយច្បាប់នេះក្តី (មើលមាត្រា ១១០) ក៏ច្បាប់នេះគប្បីត្រូវបានប្រើរួមជាមួយច្បាប់ដទៃទៀតដែលមានសង្គតិភាពផងដែរ។ មាត្រា ១ ចែងច្បាស់ថាច្បាប់នេះមិនមែនជាច្បាប់ពេញលេញទាំងស្រុងនោះទេ ហើយនឹងត្រូវបំពេញបន្ថែមដោយច្បាប់ដទៃទៀតតាមការចាំបាច់។ ប្រការនេះគឺជាករណីដោយឡែកជាមួយច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលអនុវត្តអនុសាសន៍ស្ទើរតែទាំងអស់របស់ FATF ។ ឧទាហរណ៍ផ្សេងទៀតគឺអំណាចរបស់នគរបាល និងនិតិវិធីព្រហ្មទណ្ឌដែលមិនមានចែងនៅក្នុងច្បាប់នេះ។ ចំពោះការស៊ើបអង្កេត និងការចោទប្រកាន់ទាំងឡាយដែលមិនមានចែងនៅក្នុងច្បាប់នេះ វិធានធម្មតាដែលមានចែងនៅក្នុងច្បាប់ដទៃទៀតត្រូវអនុវត្តលើការស៊ើបអង្កេត និងការចោទប្រកាន់លើបទល្មើសស្របតាមបញ្ញត្តិនៃច្បាប់នេះ។

## មាត្រា ២.- ការបកស្រាយ

ភាពមិនច្បាស់លាស់ក្នុងការបកស្រាយ នឹងត្រូវបានដោះស្រាយដោយឯកសារយោងនៃអនុសញ្ញា ពិធីសារ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិទាំងឡាយស្តីពីភេរវកម្ម

និងអនុសាសន៍របស់ FATF ។

## មាត្រា ៣.- និយមន័យ

និយមន័យនៃពាក្យ "អាជ្ញាធរមានសមត្ថកិច្ច" រាប់បញ្ចូលបុគ្គល ឬ អង្គភាពដែលអាចអនុវត្តមុខងារយ៉ាងស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេស។

និយមន័យនៃពាក្យ "បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស" គឺជាការបង្ហាញនូវការធ្វើតេស្តនៃទ្វិកឧក្រិដ្ឋភាព ពោលគឺលក្ខខណ្ឌសម្រាប់ការធ្វើបត្យាប័ន។ ការធ្វើតេស្តនេះតម្រូវឱ្យអំពើដែលត្រូវបានចោទប្រកាន់ គឺជាបទល្មើសទាំងនៅក្នុងប្រទេសកម្ពុជា និងទាំងនៅរដ្ឋបរទេស។ និយមន័យនេះចាំបាច់ត្រូវយោងទៅមាត្រា ៩២ ។

ការនិយាយយោងដល់ "បុគ្គល" គឺត្រូវរាប់បញ្ចូលទាំងនីតិបុគ្គលផងដែរ ប៉ុន្តែមិនរាប់បញ្ចូលរដ្ឋឡើយ។

"ទ្រព្យ" ត្រូវបានផ្តល់និយមន័យដ៏ទូលាយមួយ។ សម្រាប់គោលបំណងនៃជំពូកទី ១១ វាជាប្រការមិនសមស្របទេដែលថាតើទ្រព្យត្រូវបានទទួលយ៉ាងដូចម្តេច។ ដូច្នេះ សម្រាប់គោលបំណងនៃហិរញ្ញប្បទានភេរវកម្ម ទ្រព្យ អាចត្រូវបានផ្តល់ពីប្រភពស្របច្បាប់ ឧទាហរណ៍ ពីប្រភពមនុស្សធម៌ជាដើម។ វាគឺជា*ការប្រើប្រាស់* (ឬចេតនាប្រើប្រាស់) ទ្រព្យនេះដែលផ្តល់ការផ្សារភ្ជាប់ចំពោះបទល្មើសតាមបញ្ញត្តិនៃជំពូកទី ១១ ។

"នាវា" ត្រូវបានផ្តល់និយមន័យយ៉ាងទូលាយ។ វាមានន័យថាគឺជានាវាគ្រប់ប្រភេទដែលពុំត្រូវបានភ្ជាប់ជាអចិន្ត្រៃយ៍ទៅនឹងបាតសមុទ្រ។

ការនិយាយដល់ "បរិវេណរដ្ឋ ឬ រដ្ឋាភិបាល" រួមមានទីក្នុងបរិវេណ ឬ/និង យានជំនិះទាំងឡាយណាដែលត្រូវបានប្រើប្រាស់ ឬ កាន់កាប់ដោយមន្ត្រី និងបុគ្គលិករដ្ឋាភិបាលផ្សេងៗ ព្រមទាំងអង្គការអន្តររដ្ឋាភិបាលនៅក្នុងការបំពេញកាតព្វកិច្ចផ្លូវការរបស់ខ្លួន។

"ទ្រព្យកខ្វក់" គឺជាទ្រព្យដែលត្រូវបានប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ គឺជាបទល្មើសពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃច្បាប់របស់រដ្ឋបរទេស។ នៅពេលដែលទ្រព្យក្លាយទៅជា "ទ្រព្យកខ្វក់" ទ្រព្យនេះអាចក្លាយទៅជាកម្មវត្ថុនៃបទបញ្ញា

(សេចក្តីសំរេច) របស់តុលាការតាមបញ្ញត្តិនៃផ្នែក ២ នៃជំពូកទី ១១ ពោលគឺទ្រព្យនេះអាចត្រូវបានបង្កក ដកហូត និងរឹបអូស។

## មាត្រា ៤.- ការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

មាត្រានេះអនុវត្តចំពោះបទល្មើសទាំងអស់ស្របតាមបញ្ញត្តិនៃច្បាប់នេះ។ កថាខណ្ឌទី ៤(១) ចែងថាបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ នឹងមានពិរុទ្ធភាពចំពោះបទល្មើសដែលខ្លួនបានប៉ុនប៉ងប្រព្រឹត្ត។ កថាខណ្ឌទី ៤(១) ក៏ចែងផងដែរថា បុគ្គលនោះ នឹងទទួលទោសដូចគ្នានឹងទោសដែលត្រូវបានកំណត់ចំពោះបទល្មើសដែលខ្លួនបានប៉ុនប៉ងប្រព្រឹត្តនោះ។ ឧទាហរណ៍ ប្រសិនបើបុគ្គលនោះប៉ុនប៉ងចាប់ជំរិតប្រមុខរដ្ឋ (ជនដែលត្រូវបានការពារជាអន្តរជាតិ) នោះបុគ្គលនោះនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រា ៣១ ហើយនឹងត្រូវទទួលទោសជាប់ពន្ធនាគារពី ១០ ទៅ ២០ ឆ្នាំ។

កថាខណ្ឌទី ៤(២) កំណត់អំពីពេលវេលាដែលជនណាម្នាក់ត្រូវបានចាត់ទុកថាបានប៉ុនប៉ងប្រព្រឹត្តបទល្មើស។ ស្ថានភាពទាំងនេះគឺនៅពេលណាដែលជននោះចាប់ផ្តើមធ្វើសកម្មភាពជំហានដំបូងដើម្បីប្រព្រឹត្តបទល្មើស ហើយសកម្មភាពនោះត្រូវបានអាក់ខានទៅវិញដោយសារស្ថានភាពដែលនៅក្រៅការគ្រប់គ្រង (ក្រៅឆន្ទៈ) របស់ជននោះ។ ឧទាហរណ៍ ប្រសិនបើជនណាម្នាក់បានដាក់គ្រាប់បែកនៅលើអាកាសយាន ហើយគ្រាប់បែកនោះមិនផ្ទុះដោយសារវាស្អុយ/ខូច។ ក្នុងករណីនេះ ជនដែលមានបំណងបំផ្លាញអាកាសយាននោះនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រា ១៧ ហើយនឹងត្រូវទទួលទោសជាប់ពន្ធនាគារពី ១០ ទៅ ២០ ឆ្នាំ។

កថាខណ្ឌទី ៤(៣) ចែងថាសកម្មភាពដែលត្រៀមរៀបចំសម្រាប់ប្រព្រឹត្តបទល្មើសមិនត្រូវបានចាត់ទុកថាជាជំហានដំបូងនៅក្នុងការប្រព្រឹត្តបទល្មើសនោះឡើយ។ ឧទាហរណ៍ ជនម្នាក់ដែលបានទិញគ្រាប់បែកមួយក្នុងបំណងដាក់លើអាកាសយាន បានធ្វើសកម្មភាពត្រៀម ក៏ប៉ុន្តែមិនទាន់បានប៉ុនប៉ងប្រព្រឹត្តបទល្មើសបំផ្លាញអាកាសយានឡើយ។

## មាត្រា ៥.- អ្នកផ្តើមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

មាត្រានេះអនុវត្តចំពោះបទល្មើសទាំងអស់ដែលប្រឆាំងនឹងច្បាប់នេះ។ ជាឧទាហរណ៍ :

នឹងត្រូវបានចាត់ទុកជាបទល្មើសចំពោះជនណាដែលចាត់ចែង បង្គាប់ ឬ ជំរុញឱ្យជនណាម្នាក់ទៀតធ្វើឱ្យផ្ទុះគ្រឿងផ្ទុះនៅក្នុងទីកន្លែងសាធារណៈ (ដែលគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រា ៧៥)។

ជនណាដែលត្រូវបានរកឃើញថា មានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ នឹងត្រូវទទួលទោសដូចជាបទល្មើសដែលខ្លួនបានចាត់ចែង បង្គាប់ ឬ ជំរុញឱ្យ ជនណាម្នាក់ទៀតប្រព្រឹត្តអញ្ចឹងដែរ។ លើសពីនេះទៀត ជននោះនឹងមានពិរុទ្ធភាព ទោះបីជាបទល្មើសនោះត្រូវបានប្រព្រឹត្តឬប៉ុនប៉ងក្តី។

## មាត្រា ៦.- អ្នកសមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ

មាត្រានេះអនុវត្តចំពោះបទល្មើសទាំងអស់ដែលប្រឆាំងនឹងច្បាប់នេះ។ មាត្រា ៦ ចែងថាជនម្នាក់នឹងត្រូវបានចាត់ទុកជាអ្នកសមគំនិតរបស់ជនម្នាក់ទៀត ប្រសិនបើជននោះបានផ្តល់ការជួយជ្រោមជ្រែងទោះជាក្នុងទម្រង់ណាមួយក្តី ដោយដឹងថាការជួយនោះនឹងសម្រួលដល់ការប្រព្រឹត្តបទល្មើស ឬ ដល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ ជនម្នាក់ដែលបានទទួលកាំភ្លើងមួយដើមដើម្បីប្រគល់ឱ្យដល់ជនម្នាក់ទៀត ដោយដឹងថាជននោះមានបំណងប្រើកាំភ្លើងនោះដើម្បីប្លន់អាកាសយាន នឹងត្រូវបានចាត់ទុកជាអ្នកសមគំនិតជាមួយជននោះ នៅក្នុងបទល្មើសប្លន់អាកាសយាន។ អ្នកសមគំនិតជាមួយជនណាដែលប្រព្រឹត្ត (ឬប៉ុនប៉ងប្រព្រឹត្ត) បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ នឹងមានពិរុទ្ធភាពចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្ត ហើយនឹងត្រូវទទួលការផ្តន្ទាទោសជាធរមានចំពោះបទល្មើសនោះ។ ដោយប្រើឧទាហរណ៍ដូចគ្នានេះ អ្នកសមគំនិតដែលបានទិញ និងផ្តល់កាំភ្លើងដល់ចោរប្លន់អាកាសយាន នឹងមានពិរុទ្ធភាពពីបទល្មើសតាមបញ្ញត្តិនៃមាត្រា ១៥ ហើយនឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១៥ ដល់ ៣០ ឆ្នាំ។

មាត្រានេះក៏រាប់បញ្ចូលផងដែរនូវកលឧបាយទុច្ចរិត។ ដូច្នេះ ការចូលរួមរបស់ជនណាមួយនៅក្នុងការធ្វើផែនការប្រព្រឹត្តបទល្មើស ឬ ការឯកភាពលើផែនការនេះ នឹងគឺជាការផ្តល់ការគាំទ្រដោយចេតនារបស់ខ្លួនតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ៧.- បទល្មើសដែលត្រូវបានប្រព្រឹត្តដោយនីតិបុគ្គល

មាត្រានេះធានាឱ្យបានប្រាកដថា នីតិបុគ្គលទទួលខុសត្រូវចំពោះសកម្មភាពដែលរួមចំណែកដល់បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ដូចគ្នានឹងបុគ្គលរូបវន្តផងដែរ។

នៅពេលដែលការកាត់ទោសដាក់ពន្ធនាគារ ត្រូវបានសម្រេចចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តដោយនីតិបុគ្គលតាមបញ្ញត្តិនៃច្បាប់នេះ តុលាការត្រូវតែដាក់ទោសជាប្រាក់កាស។ ទោសនេះនឹងត្រូវបានគណនាយោងតាមកថាខណ្ឌទី ៧(៦) ។ បន្ថែមលើទោសបញ្ញត្តិជាប្រាក់កាស តុលាការមានសិទ្ធិដាក់ទោសបន្ថែមដូចដែលមានរាយនៅក្នុងកថាខណ្ឌទី ៧(៧) តាមភាពសមស្រប។

តាមបញ្ញតិនៃកថាខណ្ឌទី ៧(៤) ប្រសិនបើនីតិបុគ្គល ដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ផ្តល់សិទ្ធិ ឬ អនុញ្ញាតចំពោះសកម្មភាពដែលជាបទល្មើស នីតិបុគ្គលនោះនឹងត្រូវបានចោទពីបទបានប្រព្រឹត្តបទល្មើសនោះដោយចេតនា និងដោយដឹងខ្លួន ហើយនឹងមានពិរុទ្ធភាពចំពោះបទល្មើសនោះ។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនដឹកជញ្ជូនមួយ ពុំមានប្រព័ន្ធត្រឹមត្រូវដើម្បីការពារកុំឱ្យនាវារបស់ខ្លួន នាំសារធាតុនុយក្លេអ៊ែរចូលក្នុងប្រទេសកម្ពុជា ហើយសារធាតុនុយក្លេអ៊ែរត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជាតាមនាវារបស់ខ្លួន ក្រុមហ៊ុននោះនឹងមានពិរុទ្ធភាពពីបទល្មើសតាមបញ្ញត្តិនៃមាត្រា ៤៥ ។

តាមបញ្ញតិនៃកថាខណ្ឌទី ៧(៣) នីតិបុគ្គលនឹងត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់និយោជិត ភ្នាក់ងារ ឬ បុគ្គលិករបស់ខ្លួនដែលពាក់ព័ន្ធនឹងសកម្មភាពដែលជាបទល្មើសក្រោមច្បាប់នេះ នៅទីណាដែលនិយោជិតទាំងនោះធ្វើសកម្មភាពនៅក្នុងក្របខណ្ឌការងាររបស់គេ ឬ ដោយមានការផ្តល់សិទ្ធិពីនីតិបុគ្គល។ ឧទាហរណ៍ ប្រសិនបើនាយករបស់នីតិបុគ្គលមួយផ្តល់ឱ្យនិយោជិតម្នាក់នូវគ្រឿងផ្ទុះមួយ ដែលនឹងត្រូវធ្វើឱ្យផ្ទុះនៅក្នុងអាគាររដ្ឋាភិបាលមួយ នីតិបុគ្គលនេះនឹងបានប្រព្រឹត្តបទល្មើសតាមបញ្ញតិនៃមាត្រា ៧៥ នៃច្បាប់នេះ។ តាមបញ្ញតិនៃកថាខណ្ឌរងទី ៧(ច) ការទទួលខុសត្រូវរបស់នីតិបុគ្គលនឹង *គ្មានព្យសនកម្ម* ចំពោះការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់និយោជិតដែលបានបំផ្ទុះគ្រាប់បែក។ ប្រការនេះមានន័យថា ទាំងជននោះ និងទាំងនីតិបុគ្គល អាចត្រូវបានចោទប្រកាន់ដោយឡែកពីគ្នាចំពោះបទល្មើសនេះ។

## មាត្រា ៨.- យុត្តិកម្ម

មាត្រានេះចែងច្បាស់ថា ជនម្នាក់នឹងប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ ប្រសិនបើខ្លួនពុំមានការអនុញ្ញាត ឬ ការលើកលែងទោសស្របច្បាប់ចំពោះការធ្វើសកម្មភាពមួយ បើមិនដូច្នោះទេ នឹងគឺជាបទល្មើសក្រោមច្បាប់នេះ។ ឧទាហរណ៍ ជនម្នាក់នៅលើអាកាសយានមួយដែលត្រូវបានប្លន់ អាចប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងអ្នកប្លន់អាកាសយាន (ជាជននៅលើអាកាសយាន ដែលមានគោលបំណងប្រព្រឹត្តបទល្មើសតាមបទប្បញ្ញត្តិនៃមាត្រា ១៦) ប្រសិនបើធ្វើឡើងដើម្បីការពារខ្លួន។

ដូចគ្នានេះដែរ មន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធនៅក្នុងប្រតិបត្តិការសម្ងាត់ដែលត្រូវបានអនុញ្ញាតដោយច្បាប់ នឹងពុំមានពិរុទ្ធភាពចំពោះបទល្មើសឡើយ នៅពេលដែលសកម្មភាពរបស់គេគឺជាបទល្មើសក្រោមច្បាប់នេះ ប្រសិនបើអំពើនោះគឺជាផ្នែកមួយនៃភារកិច្ចរបស់ខ្លួន។

ដូចគ្នានេះដែរ ជនណាដែលមានអាជ្ញាប័ណ្ណសមស្របសម្រាប់ដឹកជញ្ជូនគ្រឿងផ្ទុះ នឹងមិនមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រា ៧៣ ឡើយ។

កថាខណ្ឌទី ៨(២) ធានាឱ្យបានប្រាកដថា បទល្មើសដែលត្រូវបានប្រព្រឹត្តដោយសារមូលហេតុនយោបាយ សាសនា ឬ មូលហេតុដូចគ្នាដទៃទៀត នឹងគឺជាបទល្មើសក្រោមច្បាប់នេះ ពោលគឺមូលហេតុរបស់បុគ្គលមិនអាចធ្វើយុត្តិកម្មលើបទល្មើសឡើយ។

## មាត្រា ៩.- អាជ្ញាយុកាលនៃបទល្មើស

មាត្រានេះចែងច្បាស់ថា បុគ្គលមួយរូបអាចត្រូវបានចោទប្រកាន់ចំពោះបទល្មើសក្រោមច្បាប់នេះ ទោះជាបទល្មើសនេះត្រូវបានប្រព្រឹត្តកន្លងមកអស់រយៈពេលយូរប៉ុណ្ណាក្តី។ ប្រការនេះត្រូវអនុវត្តទោះបីជាច្បាប់ដទៃទៀតមានចែងពីអាជ្ញាយុកាលនៃការចោទប្រកាន់ក្តី។

## ជំពូកទី ២ ‑ យុត្តាធិការ

### មាត្រា ១០.‑ យុត្តាធិការកម្ពុជាតាមបញ្ញត្តិច្បាប់នេះ

មាត្រានេះកំណត់កាលៈទេសៈដែលនៅក្នុងនោះ ប្រទេសកម្ពុជានឹងមានយុត្តាធិការលើជនល្មើសដែលត្រូវបានគេចោទប្រកាន់។ មាត្រានេះកំណត់ដូច្នេះដោយរាយបញ្ជីកាលៈទេសៈទាំងឡាយដែលនៅក្នុងនោះ ជនម្នាក់នឹងត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ។ កាលៈទេសៈទាំងនេះមានភាពទូលាយ និងស្របគ្នាទៅនឹងអនុសញ្ញា និងពិធីសារប្រឆាំងភេរវកម្មរបស់អង្គការសហប្រជាជាតិ ដែលតម្រូវឱ្យរដ្ឋទាំងឡាយធានាឱ្យបានថា ខ្លួនមានយុត្តាធិការក្នុងការចោទប្រកាន់ជនណាមួយដែលត្រូវបានចោទថា បានប្រព្រឹត្តបទល្មើសក្រោមអនុសញ្ញា និងពិធីសារប្រឆាំងភេរវកម្មទាំងនេះ។

កថាខណ្ឌរងទី ១០(ក) រាយបញ្ជីមូលហេតុផ្សេងៗដែលយុត្តាធិការអាចត្រូវបានទាមទារដោយប្រទេសកម្ពុជា ផ្អែកលើទីកន្លែងដែលសកម្មភាពល្មើសកើតឡើង។ ឧទាហរណ៍ កម្ពុជាអាចទាមទារយុត្តាធិការលើជនណាមួយ ដែលធ្វើឱ្យមានការខូចខាតចំពោះនាវាមួយ ដោយសារថា ជននោះបានធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍នៃនាវានោះប្រសិនបើនាវានោះចូលក្នុងដែនទឹកកម្ពុជា។ វាមិនសំខាន់ទេដែលថាតើនាវានោះចុះបញ្ជីនៅក្នុងរដ្ឋមួយទៀត ឬ ជនល្មើសដែលត្រូវបានចោទប្រកាន់ពុំមែនជាជនជាតិកម្ពុជា។ វត្តមានរបស់នាវានៅក្នុងដែនទឹកកម្ពុជាគឺគ្រប់គ្រាន់ហើយ ដើម្បីផ្តល់យុត្តាធិការលើបទល្មើស។[១]

កថាខណ្ឌរងទី ១០(ខ) រាយបញ្ជីមូលហេតុដទៃទៀតសម្រាប់យុត្តាធិការដែលត្រូវបានផ្អែកយ៉ាងទូលាយលើសញ្ជាតិរបស់អ្នកប្រព្រឹត្តបទល្មើស ជនរងគ្រោះ ឬ ទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ឬ ឋានៈរបស់ជនរងគ្រោះ។ ប្រទេសកម្ពុជាក៏អាចទាមទារផងដែរនូវយុត្តាធិការលើជនណាដែលត្រូវគេចោទថា បានប្រព្រឹត្តបទល្មើសដែលសំដៅបង្ខំរាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ។ ឧទាហរណ៍ ប្រទេសកម្ពុជា

---

[១] កំណត់សម្គាល់: ឧទាហរណ៍ ថ្វីបើប្រទេសកម្ពុជានឹងមានយុត្តាធិការក្នុងស្ថានភាពទាំងនេះក្តី ក៏អាចមានប្រទេសដទៃទៀតដែលស្ថិតក្នុងស្ថានភាពប្រសើរជាងក្នុងការចោទប្រកាន់ជននោះ ដោយសារប្រទេសនោះមានភស្តុតាងភាគច្រើន។ ក្នុងករណីនេះ ប្រទេសនោះអាចស្នើសុំឱ្យកម្ពុជាធ្វើបត្យាប័នជនល្មើស ដោយផ្អែកលើអនុសញ្ញាពហុភាគីសមស្របជាមូលដ្ឋានច្បាប់ ឬ សន្ធិសញ្ញាឧបតោភាគីណាមួយដែលអាចមានជាមួយនឹងប្រទេសកម្ពុជា។

អាចទាមទារយុត្តាធិការលើជនដែលនៅក្រៅប្រទេសកម្ពុជា ដែលគំរាមប្រើសារធាតុនុយក្លេអ៊ែរដើម្បីធ្វើឱ្យមានការស្លាប់មនុស្សនៅក្នុងប្រទេសទីបី ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមិនបានដោះលែងទណ្ឌិតដែលនៅក្នុងប្រទេសកម្ពុជា។ ក្នុងស្ថានភាពទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាអាចស្នើសុំបត្យាប័នជនល្មើស និងធ្វើការចោទប្រកាន់ជនល្មើសនោះពេលបញ្ជូនមកដល់។

## មាត្រា ១១.- ការអនុវត្តច្បាប់នេះចំពោះអំពើភេរវកម្មដែលមានអ្នកចូលរួមប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រានេះអនុវត្តគោលការណ៍ "គ្មានកន្លែងជ្រកកោនសុវត្ថិភាព" ដែលមាននៅក្នុងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣៧៣ ។ សេចក្តីសម្រេចនេះ តម្រូវឱ្យរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ធានាឱ្យបានថាខ្លួនមិនផ្តល់ទីកន្លែងជ្រកកោនសុវត្ថិភាពដល់ភេរវករឡើយ ដោយធានាឱ្យបានថា រដ្ឋជាសមាជិកទាំងឡាយត្រូវធ្វើបត្យាប័នជនណាម្នាក់ទៅកាន់រដ្ឋមួយដែលមានយុត្តាធិការ ឬ ធ្វើការចោទប្រកាន់ជននោះក្នុងស្រុក។

តាមបញ្ញត្តិនៃកថាខណ្ឌទី ១១(៣) អំពើដែលបានកើតឡើងនៅក្នុងរដ្ឋបរទេសអាចត្រូវបានចាត់ទុកថាដូចជាត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាដែរ ដើម្បីគោលបំណងធ្វើបត្យាប័ន និងដើម្បីធ្វើការចោទប្រកាន់ជំនួសការធ្វើបត្យាប័ន។ ប្រការនេះពុំមែនមានន័យថាអំពើនោះនឹងត្រូវបានចាត់ទុកថា*ពិតជា*បានកើតឡើងនៅក្នុងប្រទេសកម្ពុជាមែននោះឡើយ។ ឧទាហរណ៍ រដ្ឋមួយអាចស្នើសុំការធ្វើបត្យាប័នជនណាម្នាក់ដែលត្រូវបានចោទថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងមនុស្សជាច្រើន ដែលស្ថិតនៅក្នុងរដ្ឋផ្សេងៗគ្នានៅពេលនោះ។ ដើម្បីគោលបំណងនៃការកំណត់តាមបញ្ញត្តិនៃមាត្រា ៩២ ថាតើបទល្មើសបរទេសគឺដូចគ្នានឹងបទល្មើសក្រោមច្បាប់នេះឬទេ (ពោលគឺ ថាតើអំពើ ឬ ការគេចវេសទាំងនេះនឹងគឺជាបទល្មើសនៅក្នុងប្រទេសកម្ពុជាឬទេ ប្រសិនបើអំពើទាំងនោះខ្លះ ឬ ទាំងអស់បានកើតឡើង*ពិតមែន*នៅក្នុងប្រទេសកម្ពុជា) អំពើ*ទាំងអស់*ដែលគឺជាបទល្មើស គប្បីត្រូវបានចាត់ទុកដូចជាបានកើតឡើងនៅក្នុងប្រទេសកម្ពុជាអញ្ចឹងដែរ។

## ជំពូកទី ៣ ~ បទល្មើសដែលត្រូវបានប្រព្រឹត្តនៅលើអាកាសយាន ឬ នៅក្នុងអាកាសយានដ្ឋាន

### ផ្នែកទី ១ ~ ការបកស្រាយ

### មាត្រា ១២.- ពេលអាកាសយានស្ថិតក្នុងការហោះហើរ

មាត្រានេះកំណត់ពេលវេលាដែលអាកាសយានត្រូវបានចាត់ទុកថា "ស្ថិតក្នុងការហោះហើរ" សម្រាប់គោលបំណងទាំងឡាយនៃបទល្មើសនៅក្នុងជំពូកទី ៣ ដែលមានលក្ខខណ្ឌជាបទល្មើសត្រូវបានប្រព្រឹត្តនៅពេល "ស្ថិតក្នុងការហោះហើរ" ឬ "ស្ថិតក្នុងសេវាកម្ម"។

អាកាសយាននឹងស្ថិតក្នុងការហោះហើរ នៅពេលដែលទ្វារខាងក្រៅចុងក្រោយបង្អស់ត្រូវបានបិទដើម្បីត្រៀមធ្វើចលនា ឬ វាបានចាប់ផ្តើមធ្វើចលនាក្នុងគោលបំណងហោះចេញ (កថាខណ្ឌទី ១២(២), និង ១២(៣))។

អាកាសយាននឹងមិនស្ថិតក្នុងការហោះហើរទៀតឡើយ នៅពេលដែលទ្វារខាងក្រៅដំបូងបង្អស់ត្រូវបានបើកក្រោយពេលអាកាសយានបានធ្វើការចុះចត បន្ទាប់ពីវាបានចាប់ផ្តើមហោះហើររួចមក (កថាខណ្ឌទី ១២(៤))។

កថាខណ្ឌទី ១២(៥) ចែងថា នៅពេលដែលអាកាសយានធ្វើការចុះចតដោយបង្ខំ វានឹងត្រូវបានចាត់ទុកថា នៅតែស្ថិតក្នុងការហោះហើរដដែលរហូតដល់អាជ្ញាធរមានសមត្ថកិច្ចបានកាន់កាប់ការទទួលខុសត្រូវលើអាកាសយាននោះ និងលើមនុស្ស និងទ្រព្យនៅលើអាកាសយាន។ ឧទាហរណ៍ ប្រសិនបើចោរប្លន់អាកាសយានបង្ខំឱ្យអ្នកបើកអាកាសយានចុះចតនៅក្នុងរដ្ឋមួយដែលមិនមែនជាគោលដៅដែលត្រូវចុះចត ហើយអាជ្ញាធរមានសមត្ថកិច្ចមិនទាន់បានកាន់កាប់ការទទួលខុសត្រូវលើអាកាសយានទេនោះ អាកាសយាននោះក៏នៅតែត្រូវបានចាត់ទុកថាស្ថិតនៅក្នុងការហោះហើរ ហើយអំពើហិង្សាដែលត្រូវបានប្រព្រឹត្តនៅលើអាកាសយានគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រា ១៦ នៃច្បាប់នេះ។

កថាខណ្ឌទី ១២(៧) ទាក់ទងនឹងស្ថានភាពដែលក្នុងនោះការហោះហើរត្រូវបានបោះបង់ចោលមុនពេលដែលវាអាចត្រូវបានចាត់ទុកថា បានបញ្ចប់តាមកថាខណ្ឌទី ១២(៤) ឬ ១២(៥)។ ស្ថានភាពបែបនេះនឹងកើតមានឡើងនៅពេលដែលអ្នកបើកអាកាសយានវិល

ត្រឡប់មកកាន់ចំណុចចេញដំណើរវិញ ដោយសារតែអំពើហិង្សាបានកើតឡើងនៅលើអាកាសយាន។

## មាត្រា ១៣.- ពេលអាកាសយានស្ថិតក្នុងសេវាកម្ម

មាត្រានេះកំណត់ពេលវេលាដែលអាកាសយាន "ស្ថិតក្នុងសេវាកម្ម"។ អាកាសយានត្រូវបានចាត់ទុកថាស្ថិតក្នុងសេវាកម្ម ដោយចាប់ផ្ដើមពីពេលដែលបុគ្គលិកលើដី ឬ ក្រុមអាកាសយានិករៀបចំអាកាសយានសម្រាប់ហោះហើរ និងបញ្ចប់រយៈពេល ២៤ ម៉ោង ក្រោយពេលអាកាសយានបានចុះចត។ អាកាសយានក៏នៅតែត្រូវបានចាត់ទុកថាស្ថិតនៅក្នុងសេវាកម្មពេលដែលវាស្ថិតក្នុងការហោះហើរ។

## មាត្រា ១៤.- ករណីលើកលែងចំពោះការអនុវត្តជំពូកនេះ

មាត្រា ១៤ ចែងថាជំពូកទី ៣ មិនអាចអនុវត្តបានទេចំពោះអាកាសយានដែលត្រូវបានប្រើប្រាស់សម្រាប់សេវាយោធា គយ ឬ នគរបាល។ ប៉ុន្តែអាកាសយានយោធាដែលចូលរួមក្នុងការដឹកជនស៊ីវិលសម្រាប់គោលបំណងមិនមែនយោធានោះ គឺអាចស្ថិតនៅក្នុងជំពូកទី ៣។

# ផ្នែកទី ២ - បទល្មើស និងទោសបញ្ញត្តិ

## មាត្រា ១៥.- ការជណ្ដើមកាន់កាប់អាកាសយាន

មាត្រានេះកំណត់ជាបទល្មើសប្លន់អាកាសយាន និងអនុវត្តមាត្រា ១ *នៃអនុសញ្ញាស្ដីពីការរឹបអូសអាកាសយានដោយខុសច្បាប់*។ បទល្មើសនេះអនុវត្តចំពោះជនណាដែលរឹបអូសដោយខុសច្បាប់ ឬ ប៉ុនប៉ងត្រួតត្រាអាកាសយានដោយការប្រើកម្លាំង ការគំរាមកំហែង ឬ រូបភាពណាមួយនៃការគំរាមកំហែងដូចជាការជំរិត។ ការត្រួតត្រាអាកាសយានរួមមានស្ថានភាពដែលនៅក្នុងនោះ អ្នកបើកអាកាសយានត្រូវបានជំនួសដោយចោរប្លន់អាកាសយាន និងនៅពេលដែលអ្នកបើកអាកាសយានត្រូវបានបង្ខិតឱ្យធ្វើតាមបញ្ជារបស់ចោរប្លន់អាកាសយានដោយការគំរាម ការប្រើកម្លាំង ឬ រូបភាពណាមួយនៃការគំរាមកំហែងលើអ្នកបើកអាកាសយាន អ្នកឯទៀតនៅលើអាកាសយាន ឬ គំរាមកំហែងលើអាកាសយានផ្ទាល់។

បទល្មើសនេះត្រូវបានប្រព្រឹត្តដោយជនណាម្នាក់នៅលើអាកាសយាន។ ការគំរាម ឬ ការប្រើកម្លាំងត្រូវតែត្រូវបានធ្វើឡើងដោយជនណាម្នាក់ ដែលស្ថិត*នៅក្នុង*អាកាសយាន។ ឧទាហរណ៍ ជនដែលធ្វើការត្រួតត្រាពីខាងក្រៅអាកាសយានតាមរយៈវិទ្យុទាក់ទងពីលើដីទៅកាន់អាកាសយានស្ថិតក្នុងការហោះហើរ នឹងមិនប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រានេះឡើយ។ ប្រសិនបើជននោះបានដាក់គ្រឿងផ្ទុះលើអាកាសយាន និងបានគំរាមធ្វើឱ្យផ្ទុះគ្រាប់បែកនោះ ហើយប្រសិនបើអ្នកបើកអាកាសយានមិនគោរពតាមបញ្ជា នោះអំពើនេះគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រា ១៨។

ការគំរាមប្រើកម្លាំងអាចធ្វើឡើងប្រឆាំងនឹងមនុស្ស ឬ ទ្រព្យដែល***មិន***នៅលើអាកាសយាន។

## មាត្រា ១៦.- ការប្រព្រឹត្តអំពើហិង្សាលើមនុស្សនៅលើអាកាសយានដែលស្ថិតក្នុងពេលហោះហើរ

មាត្រានេះកំណត់ជាបទល្មើស ចំពោះជនណាដែលប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងជនណាម្នាក់នៅលើអាកាសយានដែលស្ថិតក្នុងការហោះហើរ ដែលក្នុងនោះអំពើហិង្សាអាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយាន។ មាត្រានេះអនុវត្តមាត្រា ១(ក) នៃ*អនុសញ្ញាស្តីពីការបង្ក្រាបសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរស៊ីវិល* (អនុសញ្ញាក្រុងម៉ុងរ៉េអាល់)។ ជនវាយប្រហារមិនចាំបាច់ស្ថិតនៅលើអាកាសយានឡើយ ប៉ុន្តែអំពើហិង្សាត្រូវតែមានគោលដៅលើសុវត្ថិភាពជនទាំងឡាយនៅលើអាកាសយាន។ ឧទាហរណ៍ ជនម្នាក់អាចមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ ប្រសិនបើជននោះបានបាញ់កាំជ្រួចមីស៊ីលទៅកាន់អាកាសយានពីដី។

## មាត្រា ១៧.- ការកម្ទេចអាកាសយានក្នុងសេវាកម្ម ឬការបង្កឱ្យខូចអាកាសយានក្នុងសេវាកម្ម

មាត្រានេះអនុវត្តមាត្រា ១(ខ) នៃអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ មាត្រានេះបង្កើតជាបទល្មើសចំពោះការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតដោយខុសច្បាប់ និងដោយចេតនាដល់អាកាសយានស្ថិតក្នុងសេវាកម្ម ដែលធ្វើឱ្យអាកាសយានមិនអាចហោះហើរបាន ឬ ដែលអាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានដែលស្ថិតក្នុងការហោះហើរ។ ប្រសិនបើអាកាសយាន

មិនស្ថិតក្នុងសេវាកម្មនៅពេលដែលអាកាសយាននោះត្រូវបានបំផ្លាញ ឬ ធ្វើឱ្យខូចខាតទេនោះ ប្រការនេះអាចជាបទល្មើសមួយតាមបញ្ញតិនៃមាត្រា ២២។

ជនដែលបង្កឱ្យខូចខាត ឬ បំផ្លាញអាកាសយានមិនចាំបាច់ត្រូវតែស្ថិតនៅលើអាកាសយានៅក្នុងពេលនោះទេ។ ឧទាហរណ៍ ប្រសិនបើជនណាម្នាក់ប្រព្រឹត្តអំពើវិទ្ធង្សនាទកម្មលើអាកាសយានមុនពេលហោះហើរចាប់ផ្តើម ហើយអំពើវិទ្ធង្សនាទកម្មនេះបំផ្លាញអាកាសយាននៅពេលស្ថិតក្នុងសេវាកម្ម ជននោះនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ១៨.- ការដាក់ ឬ ការបង្កឱ្យមានការដាក់ឧបករណ៍ ឬ សារធាតុនៅលើអាកាសយានក្នុងសេវាកម្ម

មាត្រា ១៨ អនុវត្តមាត្រា ១(គ) នៃអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ មាត្រានេះកំណត់ស្ថានភាពដែលក្នុងនោះគ្រាប់បែកត្រូវបានដាក់នៅលើ (ឬភ្ជាប់ទៅផ្នែកខាងក្រៅ) អាកាសយាន។

## មាត្រា ១៩.- ការកម្ទេច ឬ ការធ្វើឱ្យខូចខាតដល់មធ្យោបាយតម្រង់ទិសហោះហើរ

មាត្រានេះអនុវត្តមាត្រា ១(ឃ) នៃអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ មាត្រានេះកំណត់ជាបទល្មើសចំពោះការបំផ្លាញមធ្យោបាយតម្រង់ទិសហោះហើរ ឬ ការធ្វើឱ្យខូចខាតដល់មធ្យោបាយតម្រង់ទិសហោះហើរ ដែលត្រូវបានប្រើប្រាស់សម្រាប់ការតម្រង់ទិសហោះហើរ ប្រសិនបើ អំពើនោះអាចនឹងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងការហោះហើរ។ មធ្យោបាយតម្រង់ទិសហោះហើរអាចស្ថិតនៅលើដី នៅអាកាសយានដ្ឋាន ឬ នៅកន្លែងដទៃទៀត។

អំពើនោះមិនចាំបាច់បង្កគ្រោះថ្នាក់ជាក់ស្តែងដល់អាកាសយានឡើយ។ វាគឺជាការគ្រប់គ្រាន់នៅពេលដែលអំពើនោះ បង្កើតលទ្ធភាពគ្រោះថ្នាក់ទូទៅដល់សុវត្ថិភាពអាកាសយានដែលស្ថិតក្នុងការហោះហើរ។

## មាត្រា ២០.- ការផ្តល់ព័ត៌មានមិនពិតដែលបណ្តាលអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើរ

មាត្រានេះអនុវត្តមាត្រា ១(ង) នៃអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ ឧទាហរណ៍មួយនៃបទល្មើស

តាមបញ្ញត្តិនៃមាត្រានេះគឺ ជនដែលបញ្ជូនសញ្ញាមិនពិតទៅឱ្យអាកាសយានដោយមានគោលបំណងបង្វែរអាកាសយានចេញពីទិសដៅហោះហើររបស់វា។ ការផ្តល់ព័ត៌មានមិនពិតត្រូវតែបង្កឱ្យមានគ្រោះថ្នាក់ដល់អាកាសយានដើម្បីអាចកំណត់ថា អំពើនោះគឺជាបទល្មើសមួយតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ២១.- ការប្រព្រឹត្តអំពើហិង្សានៅអាកាសយានដ្ឋាន

មាត្រានេះអនុវត្តមាត្រា II(១)(ក) នៃពិធីសារចំពោះអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ មាត្រានេះចែងថា អំពើហិង្សាដែលត្រូវបានប្រព្រឹត្តដោយការប្រើសារធាតុ ឬ វត្ថុ ដូចជាអាវុធនៅក្នុងអាកាសយានដ្ឋានគឺជាបទល្មើស។ មាត្រានេះគឺដូចគ្នានឹងមាត្រា ១៦ ដែលអនុវត្តចំពោះអំពើហិង្សា ដែលត្រូវបានប្រព្រឹត្តលើអាកាសយាន ដែលស្ថិតក្នុងការហោះហើរ។ អំពើហិង្សាត្រូវតែបង្ក ឬ អាចនឹងបង្កឱ្យមានមរណៈភាព ឬ របួសធ្ងន់ធ្ងរ ឬ បង្កឱ្យមានគ្រោះថ្នាក់ដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន។ វាមិនចាំបាច់ថាជនវាយប្រហារមានបំណងសម្លាប់ ឬ ធ្វើឱ្យមានរបួសធ្ងន់ធ្ងរដល់ជនណាម្នាក់ឡើយ។ វាគឺជាការគ្រប់គ្រាន់ហើយប្រសិនបើ ជនវាយប្រហារប្រព្រឹត្តអំពើហិង្សាដោយចេតនាដែលបង្ក ឬ អាចនឹងបង្កឱ្យមានរបួសធ្ងន់ធ្ងរ ឬ មរណៈភាព ហើយអំពើនេះធ្វើឱ្យមានគ្រោះថ្នាក់ ឬ អាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៅអាកាសយានដ្ឋាន។

## មាត្រា ២២.- កាកម្មេច ការធ្វើឱ្យខូចខាតដល់សម្ភារៈបរិក្ខារនៃអាកាសយានដ្ឋាន អាកាសយានមិនស្ថិតក្នុងសេវាកម្ម និងការបង្អាក់សេវាកម្ម

មាត្រានេះអនុវត្តមាត្រា II(១)(ខ) នៃពិធីសារចំពោះអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ មាត្រានេះគឺដូចគ្នានឹងមាត្រា ១៩ ដែលទាក់ទងនឹងការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតដល់មធ្យោបាយតម្រង់ទិសហោះហើរ។ ជាសំខាន់ វាក៏អនុវត្តផងដែរចំពោះអាកាសយាននៅក្នុងអាកាសយានដ្ឋានប្រសិនបើ អាកាសយាននោះ **មិន**ស្ថិតក្នុងសេវាកម្ម។ ប្រការនេះមានន័យថា ប្រសិនបើជនណាម្នាក់ធ្វើសកម្មភាពមុនពេលដែលអាកាសយាននោះស្ថិតក្នុងសេវាកម្ម (មុនពេលដែលវាត្រូវបានរៀបចំសម្រាប់ការហោះហើរ) ហើយអំពើនោះបណ្តាលឱ្យមានការបំផ្លាញ ឬ ការខូចខាតដល់អាកាសយាន ជននោះនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។

គេចាំបាច់ត្រូវកត់សម្គាល់ថា អំពើបំផ្លិចបំផ្លាញ ឬ ការបណ្តាលឱ្យមានការខូចខាត គឺខុសពីអំពើហិង្សាធម្មតា ដោយសារលក្ខខណ្ឌដែលថា អំពើនោះត្រូវតែបង្កគ្រោះថ្នាក់ ឬ អាចនឹងធ្វើឱ្យមានគ្រោះថ្នាក់ ដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃអាកាសយានដ្ឋាន ឬ សុវត្ថិភាពរបស់ជនណាមួយនៅក្នុងអាកាសយានដ្ឋាន។

## មាត្រា ២៣.- បទល្មើសតាមបញ្ញត្តិនៃច្បាប់កម្ពុជាដទៃទៀតដែលត្រូវបានប្រព្រឹត្តលើអាកាសយាន

មាត្រានេះអនុវត្តមាត្រា ១(១)(ក) នៃ*អនុសញ្ញាស្តីពីបទល្មើស និងសកម្មភាពជាក់លាក់ដទៃទៀតដែលត្រូវបានប្រព្រឹត្តលើអាកាសយាន* (អនុសញ្ញាក្រុងតូក្យូ)។ មាត្រានេះអនុញ្ញាតឱ្យច្បាប់ព្រហ្មទណ្ឌធម្មតាត្រូវបានអនុវត្តលើសកម្មភាពលើអាកាសយាន។

## ផ្នែកទី ៣ - សិទ្ធិអំណាចរបស់មេបញ្ជាការអាកាសយាន

## មាត្រា ២៤.- វិធានការដើម្បីការពារសុវត្ថិភាពនៅលើអាកាសយាន

ផ្នែកនេះកំណត់អំពីអំណាចទាំងឡាយ ដែលមេបញ្ជាការអាកាសយានមានចំពោះបទល្មើសទាំងឡាយ ឬ ឥរិយាបទមិនសមស្របដែលមានចែងក្នុងកថាខណ្ឌរងទី ២៤(១)(ខ) ទាក់ទិននឹងអាកាសយានដែលស្ថិតក្រោមបញ្ជាការរបស់ខ្លួន។ អំណាចទាំងនេះអនុវត្តបានតែនៅពេលណាដែលលក្ខខណ្ឌនៃកថាខណ្ឌទី ២៤(១) ត្រូវបានបំពេញ។ មេបញ្ជាការអាកាសយាន ត្រូវតែមានមូលហេតុសមហេតុផលនឹងជឿថា ជនណាមួយបានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តលើអាកាសយាននូវបទល្មើសប្រឆាំងនឹងច្បាប់កម្ពុជា ឬ សកម្មភាពណាដែលអាចធ្វើឱ្យខូចខាតសុវត្ថិភាពរបស់អាកាសយាន មនុស្ស ឬ ទ្រព្យលើអាកាសយាន ឬ សណ្តាប់ធ្នាប់ និងវិន័យទូទៅលើអាកាសយាន។

អំណាចទាំងឡាយរបស់មេបញ្ជាការអាកាសយាន គឺមានលក្ខណៈទូលាយ និងរួមមាន*វិធានការសមហេតុផល*ទាំងឡាយដែលចាំបាច់ដើម្បីការពាសុវត្ថិភាពរបស់អាកាសយាននិងមនុស្ស និងទ្រព្យលើអាកាសយាន ឬ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងវិន័យលើអាកាសយាន។ វិធានការចាំបាច់ទាំងនេះនឹងផ្អែកលើស្ថានភាពដែលមេបញ្ជាការជួបប្រទះ និងប្រភេទនៃបទល្មើស ឬ ឥរិយាបទ ប៉ុន្តែជានិច្ចជាកាល ត្រូវតែមានលក្ខណៈសមហេតុផល។ ប្រការ

នេះមានន័យថា ដោយគ្មានលំអៀង វិធានការទាំងនេះត្រូវតែមានសនិទានភាពនៅក្នុងស្ថានភាព និងសមាមាត្រទៅនឹងបទល្មើស ឬ ឥរិយាបទនោះ។

ប្រសិនបើស្ថានភាពក្នុងកថាខណ្ឌទី ២៤(១) កើតឡើង តាមបញ្ញត្តិនៃកថាខណ្ឌទី ២៤(៣) មេបញ្ជាការអាកាសយានអាចតម្រូវឱ្យមាន ឬ អនុញ្ញាតជំនួយពីសមាជិកអាកាសយានិកដទៃទៀត ឬ អ្នកដំណើរ ដើម្បីបង្ខាំងជននោះ។

កថាខណ្ឌទី ២៤(៤) អនុញ្ញាតឱ្យសមាជិកអាកាសយានិក ឬ អ្នកធ្វើដំណើរ ដោយពុំចាំបាច់មានការអនុញ្ញាតពីមេបញ្ជាការ ឬ សមាជិកអាកាសយានិកដទៃទៀត ចាត់វិធានការសមហេតុផលដែលខ្លួនជឿថាចាំបាច់ ដើម្បីការពារសុវត្ថិភាពរបស់អាកាសយាន មនុស្ស ឬ ទ្រព្យលើអាកាសយាន ដើម្បីរារាំងជនដទៃទៀតមិនឱ្យធ្វើសកម្មភាពណាមួយ។ ប្រការដែលថាតើសកម្មភាពបង្ការទាំងនេះមានលក្ខណៈចាំបាច់ឬទេនៅក្នុងស្ថានភាពទាំងនោះ គឺជាការសម្រេចដោយខ្លួនឯង ប៉ុន្តែវិធានការត្រូវតែមានលក្ខណៈសមហេតុផលដោយគ្មានលំអៀង។

## មាត្រា ២៥.- បុគ្គលដែលត្រូវបានឃាត់ខ្លួន

នៅទីណាដែលជនណាម្នាក់ត្រូវបានបង្ខាំងតាមបញ្ញត្តិនៃមាត្រា ២៤ មេបញ្ជាការមានកាតព្វកិច្ចជូនដំណឹងដល់អាជ្ញាធរនៅទីកន្លែងដែលអាកាសយានចុះចត ថាមានជនម្នាក់ត្រូវបានបង្ខាំងលើអាកាសយាន និងមូលហេតុដែលប្រការនេះត្រូវបានធ្វើឡើង។ កាន់តែល្អនោះ ត្រូវជូនដំណឹងឱ្យបានមុនពេលដែលអាកាសយានចុះចត។

កថាខណ្ឌទី ២៥(៣) កំណត់ស្ថានភាពដែលនៅក្នុងនោះជននោះអាចបន្តស្ថិតនៅក្រោមការបង្ខាំងនៅទីកន្លែងដែលអាកាសយានបានចុះចត។ អត្ថិភាពនៃស្ថានភាពទាំងនេះគឺត្រូវតែមានដើម្បីបន្តការបង្ខាំង។ ស្ថានភាពទាំងនេះរួមមានទីកន្លែងដែលជននោះត្រូវបានបង្ខាំងដើម្បីអាចប្រគល់ខ្លួនជននោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងរដ្ឋដែលអាកាសយានបានចុះចត ហើយដែលអាចរួមមាននគរបាល ឬ មន្ត្រីអន្តោប្រវេសន៍។

## មាត្រា ២៦.- ការដាក់បុគ្គលណាម្នាក់ចុះពីអាកាសយាន

មាត្រានេះផ្តល់អំណាចដល់មេបញ្ជាការអាកាសយានឱ្យដាក់ជនណាមួយ *ចុះពីអាកាសយាន*

(យកចេញពីអាកាសយាន) នៅក្នុងបូរណភាពដែនដីរបស់រដ្ឋមួយដែលអាកាសយានបានចុះចត នៅពេលណាដែលមេបញ្ជាការអាកាសយានមានមូលហេតុសមហេតុផលនឹងជឿថាជននោះបានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តសកម្មភាពមួយ (ដែលមិនចាំបាច់ជាបទល្មើសនៅក្រោមច្បាប់នេះឡើយ) ដែលធ្វើឱ្យខូចខាត ឬ អាចធ្វើឱ្យខូចខាតដល់សុវត្ថិភាពរបស់អាកាសយាន មនុស្ស ឬ ទ្រព្យលើអាកាសយាន ឬ សណ្តាប់ធ្នាប់ និងវិន័យលើអាកាសយាន។

អំណាចដាក់ឱ្យជនណាម្នាក់ចុះពីអាកាសយាន គឺខុសគ្នាពីអំណាចប្រគល់ខ្លួនជនណាម្នាក់ទៅឱ្យរដ្ឋមួយដែលអាកាសយានបានចុះចត (ចែងក្នុងមាត្រា ២៧)។ មាត្រា ២៧ ផ្តល់អំណាចដល់មេបញ្ជាការឱ្យ *បញ្ជូន*ជនណាម្នាក់ នៅពេលណាដែលមេបញ្ជាការមានមូលហេតុសមហេតុផលនឹងជឿថាជននោះបានប្រព្រឹត្តលើអាកាសយាន *នូវបទល្មើសធ្ងន់ធ្ងរ*មួយក្រោមច្បាប់កម្ពុជា។ ផ្ទុយទៅវិញ មាត្រា ២៦ ចែងពីអំពើណាដែលធ្វើឱ្យខូចខាត ឬ អាចធ្វើឱ្យខូចខាតសុវត្ថិភាព។

មាត្រាទាំងនេះក៏ខុសគ្នាផងដែរតាមរបៀបផ្សេងមួយទៀត។ តាមបញ្ញត្តិនៃមាត្រា ២៦ ជនម្នាក់អាចត្រូវបានដាក់ចុះពីអាកាសយាន ដោយមេបញ្ជាការគ្រាន់តែរាយការណ៍ជូនអាជ្ញាធររដ្ឋ ស្របតាមមាត្រា ២៦(៣)។ ជនម្នាក់អាចត្រូវបានដាក់ចុះពីយន្តហោះ នៅក្នុងរដ្ឋណាក៏ដោយដែលយន្តហោះបានចុះចត។ ប៉ុន្តែ តាមបញ្ញត្តិនៃមាត្រា ២៧ ជននោះត្រូវតែប្រគល់ខ្លួនឱ្យ*អាជ្ញាធរមានសមត្ថកិច្ច*របស់រដ្ឋនោះ។ តាមការកំណត់របស់អនុសញ្ញាក្រុងតូក្យូ មាត្រា ២៧ ចែងថា ការបញ្ជូនជនណាម្នាក់ត្រូវតែធ្វើឡើងចំពោះរដ្ឋមួយដែលជាភាគីមួយនៃអនុសញ្ញាក្រុងតូក្យូ (រដ្ឋអនុសញ្ញា)។ ពេលនោះ រដ្ឋអនុសញ្ញាត្រូវតែបំពេញកាតព្វកិច្ចមួយចំនួនតាមការកំណត់នៃជំពូកទី V នៃអនុសញ្ញាក្រុងតូក្យូ។ កាតព្វកិច្ចទាំងនេះរួមមានការធ្វើការស៊ើបអង្កេតបឋមលើការពិត ហើយបន្ទាប់មកធ្វើការឃុំខ្លួនជននោះ ឬ ចាត់វិធានការដទៃទៀត ដើម្បីធានាឱ្យបាននូវវត្តមានរបស់ជននោះ ដើម្បីអនុញ្ញាតឱ្យមានចំណាត់ការព្រហ្មទណ្ឌ ឬ មានចំណាត់ការបត្យាប័នអាចត្រូវបានចាប់ផ្តើម។ ដោយសារមូលហេតុនេះ ជនម្នាក់គប្បីត្រូវបានប្រគល់ខ្លួន (ផ្ទុយពីត្រូវបានដាក់ចុះពីអាកាសយាន) ដោយមេបញ្ជាការអាកាសយានតែប៉ុណ្ណោះចំពោះបទល្មើសធ្ងន់ធ្ងរ ពោលគឺមិនមែនគ្រាន់តែដោយសារសកម្មភាពធម្មតាមួយ ដែលធ្វើឱ្យខូចខាត ឬ អាចធ្វើឱ្យខូចខាតដល់សុវត្ថិភាព

អាកាសយានដែលអាច ឬ មិនអាចមែនជាបទល្មើស។

មេបញ្ជាការអាកាសយាន គឺមានសិទ្ធិសម្រេចនៅក្នុងស្ថានភាពនោះ នូវអ្វីទៅដែលជា "បទល្មើសធ្ងន់ធ្ងរ" ដែលអនុញ្ញាតឱ្យធ្វើការប្រគល់ខ្លួនទៅឱ្យរដ្ឋក្នុងការចុះចត។

## មាត្រា ២៧.- ជនល្មើសលើអាកាសយាន

មាត្រានេះផ្តល់អំណាចដល់មេបញ្ជាការអាកាសយាន ឱ្យប្រគល់ខ្លួនជនណាមួយដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរលើអាកាសយានក្រោមច្បាប់កម្ពុជា ចំពោះរដ្ឋអនុសញ្ញា (រដ្ឋជាភាគីនៃអនុសញ្ញាក្រុងតូក្យូ) ដែលអាកាសយានចុះចត។ មេបញ្ជាការអាកាសយានមានកាតព្វកិច្ចក្នុងការផ្តល់ជូនអាជ្ញាធរទាំងឡាយរបស់រដ្ឋ នូវភស្តុតាង ឬ ព័ត៌មានណាដែលស្ថិតក្នុងកម្មសិទ្ធិស្របច្បាប់របស់ខ្លួន។

## មាត្រា ២៨.- ការមិនទទួលខុសត្រូវចំពោះការឃាត់ខ្លួនស្របច្បាប់ ជាអាទិ៍

មេបញ្ជាការ សមាជិកអាកាសយាន អ្នកធ្វើដំណើរ ម្ចាស់ ឬ ប្រតិបត្តិករនៃអាកាសយាន និងជនដទៃណាទៀតដែលទទួលខុសត្រូវលើការហោះហើរ នឹងពុំត្រូវបានចាប់ឱ្យទទួលខុសត្រូវលើសកម្មភាពដែលបានធ្វើ ដោយអនុលោមតាមជំពូកនេះ នៅក្នុងរឿងក្តីរដ្ឋបវេណី ឬ ព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងការបង្ខាំង ការឃុំខ្លួន ឬ ការដាក់ចុះពីអាកាសយាននូវជនណាមួយនោះឡើយ។ ប៉ុន្តែ ដោយសារមេបញ្ជាការអាកាសយាន ជានិច្ចកាលត្រូវតែប្រើអំណាចរបស់ខ្លួនតែនៅពេលណាដែលមានមូលហេតុសមហេតុផលនឹងជឿថា ការប្រើអំណាចរបស់ខ្លួនមានលក្ខណៈចាំបាច់នោះ ជននោះអាចតវ៉ាលើបញ្ហានេះបាននៅក្នុងតុលាការ។

## ជំពូកទី ៤ ~ បទឧក្រិដ្ឋលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

### ផ្នែកទី ១ ~ ការបកស្រាយ

**មាត្រា ២៩.- និយមន័យ**

មាត្រានេះកំណត់និយមន័យ បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ សម្រាប់គោលបំណងនៃជំពូកនេះ។ សូមកត់សម្គាល់ថា កថាខណ្ឌរងទី ២៩(ង) និង ២៩(ច) គឺត្រូវអនុវត្តចំពោះតែតំណាង ឬ មន្ត្រីនៃរដ្ឋនានា ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនទាំងនោះ *នៅពេលដែល និងនៅទីកន្លែងដែល* ជនទាំងនោះមានសិទ្ធិទទួលកិច្ចការពារជាពិសេសនៅក្រោមច្បាប់អន្តរជាតិ។ អ្នកការទូត និងជនឯទៀតដែលទទួលបានសិទ្ធិការពារជាពិសេសនេះ មានបុព្វសិទ្ធិតែពេលណាដែលគេស្ថិតនៅក្នុងរដ្ឋដែលត្រូវបានគេតែងតាំង ឬ នៅពេលដែលគេបំពេញមុខងារជាផ្លូវការតែប៉ុណ្ណោះ។ ប្រមុខរដ្ឋមានឋានៈជាពិសេស ទោះជានៅទីកន្លែងណាក្តី។

### ផ្នែកទី ២ ~ បទល្មើស

**មាត្រា ៣០.- ឃាតកម្មលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ឬ ការវាយប្រហារដទៃទៀតលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ**

មាត្រានេះអនុវត្តមាត្រា ២(១)(ក) *នៃអនុសញ្ញាស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ដែលរួមមានភ្នាក់ងារការទូត* (អនុសញ្ញាស្តីពីបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ)។ ចំពោះបទល្មើសដែលប្រព្រឹត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ៣០(១) គឺមិនចាំបាច់តម្រូវថាជននោះត្រូវដឹងជាមុនថាខ្លួនប្រព្រឹត្តអំពើមួយចំពោះជនរងគ្រោះ ដែលជាបុគ្គលត្រូវបានការពារជាអន្តរជាតិឡើយ។ វាគ្រាន់តែកំណត់ថាជននោះមានបំណងធ្វើឱ្យបុគ្គលនោះស្លាប់។

កថាខណ្ឌទី ៣០(២) កំណត់បទល្មើសស្តីពីការវាយប្រហារដោយចេតនាលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ។

## មាត្រា ៣១.- ការចាប់ពង្រត់ ការបង្ខាំង ឬ ការបំពារបំពានលើសេរីភាពរបស់ បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

មាត្រានេះអនុវត្តមាត្រា ២(១)(ក) នៃអនុសញ្ញាស្តីពីបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ។ ចាត់ទុកជាបទល្មើសតាមបញ្ញតិនៃមាត្រានេះ ចំពោះការចាប់ពង្រត់ ឬ ការវាយប្រហារតាមវិធីណាមួយ លើសេរីភាពរបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ដូចជាការបង្ខាំងខ្លួនដោយខុសច្បាប់លើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ។

## មាត្រា ៣២.- ការវាយប្រហារលើអាគារផ្លូវការ កន្លែងស្នាក់នៅឯកជន ឬ មធ្យោបាយធ្វើដំណើររបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

មាត្រានេះអនុវត្តមាត្រា ២(១)(ខ) នៃអនុសញ្ញាស្តីពីបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ។ ប្រសិនបើជនណាម្នាក់វាយប្រហារលើអាគារផ្លូវការ កន្លែងស្នាក់នៅឯកជន ឬ មធ្យោបាយធ្វើដំណើររបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ហើយដែលការវាយប្រហារនេះអាចនឹងបង្កគ្រោះថ្នាក់ដល់អាយុជីវិត ឬ សេរីភាពរបស់ពួកគេ ជននោះគឺប្រព្រឹត្តបទល្មើសមួយ តាមបញ្ញតិនៃមាត្រានេះ។ ឧទាហរណ៍ ប្រសិនបើជនណាម្នាក់នៅក្នុងប្រទេសកម្ពុជា បានដាក់គ្រឿងផ្ទុះនៅក្នុងរថយន្តដែលដឹកមន្ត្រីកុងស៊ុលបរទេស (ដែលជាបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ នៅក្រោមកថាខណ្ឌរង ២៩(ង) ដោយសារជនទាំងនោះមាន សិទ្ធិទទួលការការពារនៅក្រោម*អនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ១៩៦៣*) ហើយសកម្មភាពនោះបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរដល់ជីវិត ជននោះនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញតិនៃមាត្រានេះ។

តាមបញ្ញតិនៃមាត្រានេះ ការវាយប្រហារលើបរិវេណលំនៅដ្ឋាន ឬ ទ្រព្យផ្សេងៗ នៅទីណាដែលបុគ្គលដែលត្រូវបានការពារជាអន្តរជាតិមានវត្តមាន ហើយដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ជីវិតរបស់ជនដែលត្រូវបានការពារជាអន្តរជាតិនោះ ក៏គឺជាបទល្មើសផងដែរ។

### មាត្រា ៣៣.- ការគំរាមកំហែងប្រព្រឹត្តបទល្មើសលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ

មាត្រានេះអនុវត្តមាត្រា ២(១)(គ) នៃអនុសញ្ញាស្តីពីបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ។ តាមបញ្ញត្តិនៃមាត្រានេះ ជនណាដែលគំរាមកំហែងថានឹងប្រព្រឹត្តបទល្មើសណាមួយនៅក្នុងមាត្រា ៣០ ៣១ ឬ ៣២ នឹងមានពិរុទ្ធភាពចំពោះបទល្មើសនោះ។

## ជំពូកទី ៥ ‿ ការចាប់ចំណាប់ខ្មាំង

### មាត្រា ៣៤.- ការចាប់ចំណាប់ខ្មាំង

មាត្រានេះកំណត់បទល្មើសនៃការចាប់ចំណាប់ខ្មាំង និងអនុវត្តមាត្រា ១ នៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង។ បទល្មើសនេះមានធាតុផ្សំ ចំនួន ៣។ ទី១ ការចាប់ ឬ ការឃុំខ្លួនជនណាម្នាក់។ ធាតុផ្សំ ទី២ គឺការគំរាមកំហែងថានឹងសម្លាប់ ធ្វើឱ្យមានរបួស ឬ បន្តឃុំខ្លួន។ សមាសធាតុទី ៣· គឺអ្នកចាប់ចំណាប់ខ្មាំងនោះ មានបំណងបង្ខំឱ្យជនម្នាក់ទៀត (រួមមានអង្គភាព ឬ ស្ថាប័នរដ្ឋាភិបាល) ធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ សម្រាប់ជាលក្ខខណ្ឌនៃការដោះលែងចំណាប់ខ្មាំង។ លក្ខខណ្ឌនៃការដោះលែងអាចស្តែង ឬ មិនស្តែង។ ប្រការនេះមានន័យថា អ្នកចាប់ចំណាប់ខ្មាំងមិនចាំបាច់និយាយផ្ទាល់ទេថា ខ្លួននឹងដោះលែងជននោះ ប្រសិនបើការទាមទារអាចត្រូវបានបំពេញ។ លក្ខខណ្ឌនេះអាចត្រូវបានសន្និដ្ឋានដោយផ្អែកលើស្ថានភាព។

គេពុំចាំបាច់មានលក្ខខណ្ឌថា ការចាប់ចំណាប់ខ្មាំងត្រូវបានធ្វើដោយកម្លាំងឡើយ។ ជនរងគ្រោះអាចត្រូវបានគេប្រើល្បិចឱ្យទៅជាមួយអ្នកចាប់ចំណាប់ខ្មាំង។

## ជំពូកទី ៦ ~ ការការពារជារូបវន្តលើសារធាតុនុយក្លេអ៊ែរ និងការបង្ក្រាបលើអំពើភេរវកម្មនុយក្លេអ៊ែរ

### ផ្នែកទី ១: សេចក្តីផ្តើម

#### មាត្រា ៣៥.- និយមន័យ

មាត្រានេះកំណត់និយមន័យនៃពាក្យដែលត្រូវបានប្រើនៅក្នុងជំពូកទី ៦ ដែលរួមមានការដឹកជញ្ជូននុយក្លេអ៊ែជាអន្តរជាតិ។

#### មាត្រា ៣៦.- ការអនុវត្តផ្នែកទី ២ និងផ្នែកទី ៣ នៃជំពូកនេះ

មាត្រានេះធានាឱ្យបានថា ផ្នែកទី ២ និងផ្នែកទី ៣ អនុវត្តលើតែសារធាតុនុយក្លេអ៊ែរ ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសន្តិភាព ដែលស្ថិតនៅក្នុងការដឹកជញ្ជូននុយក្លេអ៊ែរអន្តរជាតិ និងខណៈដែលវាស្ថិតនៅក្នុងការប្រើប្រាស់ក្នុងស្រុក ការទុកដាក់ និង ការដឹកជញ្ជូន។

### ផ្នែកទី ២: ការការពារជារូបវន្តដែលចាំបាច់សម្រាប់សារធាតុនុយក្លេអ៊ែរ

ផ្នែកទី ២ មានបំណងធានាឱ្យបាននូវការរកឃើញ និងការទប់ស្កាត់លទ្ធភាពទទួលដោយគ្មានការអនុញ្ញាត ឬ ការយកចេញដោយគ្មានការអនុញ្ញាតនូវសារធាតុនុយក្លេអ៊ែរ។

#### មាត្រា ៣៧.- ការកំណត់ប្រភេទសារធាតុនុយក្លេអ៊ែរ

មាត្រានេះចែងពីតារាងមួយដែលភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ដែលធ្វើចំណាត់ថ្នាក់សារធាតុនុយក្លេអ៊ែរ និងអនុវត្តឧបសម្ព័ន្ធ II នៃ*អនុសញ្ញាស្តីពីការការពារជារូបវន្តលើសារធាតុនុយក្លេអ៊ែរ* (CPPNM)។ កម្រិតកំណត់នៃការការពារ នឹងមានភាពខុសៗគ្នាអាស្រ័យលើចំណាត់ថ្នាក់នៃសារធាតុនុយក្លេអ៊ែរពាក់ព័ន្ធ។ សារធាតុដែលត្រូវបានរាយបញ្ជីទាំងនេះគឺជាសារធាតុដែលអាចប្រើបានសម្រាប់អាវុធ។

## មាត្រា ៣៨.- កម្រិតនៃការការពារជារូបវន្តដែលត្រូវអនុវត្តក្នុងការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរជាអន្តរជាតិ

មាត្រានេះអនុវត្តឧបសម្ព័ន្ធ I នៃអនុសញ្ញា CPPNM។ មាត្រានេះកំណត់កម្រិតនៃការការពារជារូបវន្តសម្រាប់សារធាតុនុយក្លេអ៊ែរក្នុងឃ្លាំង ដែលកើតឡើងដោយចៃដន្យចំពោះការដឹកជញ្ជូននុយក្លេអ៊ែរជាអន្តរជាតិ។ សារធាតុប្រភេទ III តម្រូវឱ្យមានកម្រិតការពារទាបបំផុត ឡើងទៅដល់ប្រភេទ I ដែលតម្រូវឱ្យមានកម្រិតការពារខ្ពស់បំផុត។

កថាខណ្ឌទី ៣៨(៣) ចែងលំអិតនូវកម្រិតនៃការការពារជារូបវន្តដែលត្រូវមានសម្រាប់សារធាតុនុយក្លេអ៊ែរក្នុងពេលដឹកជញ្ជូនជាអន្តរជាតិ។

## ផ្នែកទី ៣: បទល្មើសពាក់ព័ន្ធនឹងការការពារជារូបវន្តនូវសារធាតុនុយក្លេអ៊ែរ

## មាត្រា ៣៩.- កិច្ចការពារជារូបវន្តសារធាតុនុយក្លេអ៊ែរក្នុងអំឡុងពេលដឹកជញ្ជូននុយក្លេអ៊ែរជាអន្តរជាតិ

មាត្រានេះហាមឃាត់មិនឱ្យជនណាម្នាក់ដឹកជញ្ជូន នាំចូល ឬ នាំចេញនូវសារធាតុនុយក្លេអ៊ែរ ប្រសិនបើវាមិនត្រូវបានការពារក្នុងពេលដឹកជញ្ជូនជាអន្តរជាតិតាមកម្រិតដែលបានកំណត់តាមបញ្ញត្តិនៃមាត្រា ៣៨។ មាត្រានេះអនុវត្តមាត្រា ៤ នៃអនុសញ្ញា CPPNM។

## មាត្រា ៤០.- ការទទួល ការកាន់កាប់ ការប្រើប្រាស់ ការផ្ទេរ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ

មាត្រានេះអនុវត្តមាត្រា ៧(១)(ក) នៃអនុសញ្ញា CPPNM។ ដើម្បីជាភស្តុតាងនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ សកម្មភាពនៃការទទួល ការកាន់កាប់ ការប្រើប្រាស់ ការផ្ទេរ ការកែប្រែ ការបោះចោល ឬ ការធ្វើឱ្យរាយប៉ាយសារធាតុនុយក្លេអ៊ែរ ត្រូវតែអាចនឹងបណ្តាលឱ្យមានការស្លាប់ និងរបួសធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យ។ ឧទាហរណ៍ ជនម្នាក់នឹងមានទោសចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ ប្រសិនបើខ្លួនកាន់កាប់សារធាតុនុយក្លេអ៊ែរចំនួនច្រើន ដោយគ្មានការការពារជារូបវន្តគ្រប់គ្រាន់ដែលអាចបណ្តាលឱ្យមានការស្លាប់ របួសធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យ។

## មាត្រា ៤១.- ចោរកម្មសារធាតុនុយក្លេអ៊ែរ

មាត្រានេះអនុវត្តមាត្រា ៧(១)(ខ) នៃអនុសញ្ញា CPPNM។ មាត្រានេះកំណត់ជាបទល្មើសចំពោះចោរកម្មសារធាតុនុយក្លេអ៊ែរ។ កថាខណ្ឌទី ៤១(២) ចែងពីទោសបញ្ញត្តិផ្សេងៗ ផ្អែកលើស្ថានភាពដែលនៅក្នុងនោះ ចោរកម្មបានកើតឡើង។

## មាត្រា ៤២.- កាបន្លំយកសារធាតុនុយក្លេអ៊ែរ

មាត្រានេះអនុវត្តមាត្រា ៧(១)(គ) នៃអនុសញ្ញា CPPNM។ មាត្រានេះកំណត់ជាបទល្មើសចំពោះការទទួលបាននូវសារធាតុនុយក្លេអ៊ែរដោយការបោកបញ្ឆោត ឬ ការកេងបន្លំ។ ឧទាហរណ៍ ជនណាម្នាក់ដែលប្រើឈ្មោះក្លែងក្លាយ ដើម្បីបញ្ចុះបញ្ចូលជនម្នាក់ទៀតក្នុងនាមជាអាជ្ញាធរក្លែងក្លាយ ហើយដោយសារមធ្យោបាយនេះ គេទទួលបាននូវសារធាតុនុយក្លេអ៊ែរ នឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញតិនៃមាត្រានេះ។

## មាត្រា ៤៣.- ការកំហែងយកសារធាតុនុយក្លេអ៊ែរ

មាត្រានេះកំណត់ជាបទល្មើសចំពោះការទាមទារសារធាតុនុយក្លេអ៊ែរ ដោយការប្រើកម្លាំង ការគំរាមកំហែង ឬ ការបំភិតបំភ័យ ឬ ការបង្ខិតបង្ខំក្នុងរូបភាពដទៃណាផ្សេងទៀត។ មាត្រានេះអនុវត្តមាត្រា ៧(១)(ឃ) នៃអនុសញ្ញា CPPNM។

## មាត្រា ៤៤.- ការគំរាមកំហែងប្រើប្រាស់សារធាតុនុយក្លេអ៊ែរ

មាត្រានេះអនុវត្តមាត្រា ៧(១)(ង) នៃអនុសញ្ញា CPPNM។ មាត្រានេះកំណត់ជាបទល្មើសពីរ។ បទល្មើសទីមួយគឺការគំរាមកំហែងថានឹងប្រើសារធាតុនុយក្លេអ៊ែរ ដើម្បីបណ្តាលឱ្យមានការស្លាប់ របួសធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរចំពោះទ្រព្យ ឬ ចំពោះបរិស្ថាន (កថាខណ្ឌទី ៤៤(១)។

បទល្មើសទីពីរត្រូវបានកំណត់ដោយកថាខណ្ឌទី ៤៤(២)។ បទល្មើសនេះខុសពីបទល្មើសដទៃទៀតនៅក្នុងជំពូកទី ៦ ដោយសារវារួមមានធាតុផ្សំមួយបន្ថែមទៀត។ ដើម្បីឱ្យជនណាម្នាក់មានពិរុទ្ធភាពចំពោះបទល្មើសក្រោមកថាខណ្ឌទី ៤៤(២) ជននោះត្រូវតែបានគំរាមកំហែងដោយចេតនាថានឹងប្រព្រឹត្តចោរកម្ម ឬ ប្លន់សារធាតុនុយក្លេអ៊ែរ (បទល្មើសចែង

ក្នុងមាត្រា ៤១) *ដោយមានបំណង* បង្ខិតបង្ខំរូបវន្តបុគ្គល ឬ នីតិបុគ្គល អង្គការអន្តរជាតិ ឬ រដ្ឋ ឱ្យធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ។ ឧទាហរណ៍មួយនៃបទល្មើសក្រោមកថាខណ្ឌទី ៤៤(២) គឺថា ប្រសិនបើជនណាម្នាក់នៅក្នុងប្រទេសកម្ពុជា បានគំរាមកំហែងថានឹងធ្វើចោរកម្មលើសារធាតុនុយក្លេអ៊ែរ ដើម្បីបង្ខំឱ្យដកកងទ័ពពីរដ្ឋដទៃណាមួយទៀត ឬ ដើម្បីឱ្យមានការដោះលែងអ្នកជាប់ពន្ធនាគារនៅក្នុងរដ្ឋមួយទៀត។

### ផ្នែកទី ៤: ការគ្រប់គ្រងអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ

### មាត្រា ៤៥.- ការផលិត ការប្រើប្រាស់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ

មាត្រានេះអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៤០។ មាត្រានេះកំណត់ជាបទល្មើសចំពោះការផលិត ការលក់ ការកាន់កាប់ ការអភិវឌ្ឍន៍ ការដឹកជញ្ជូន ការផ្ទេរ ឬ ការប្រើអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ ឬ មធ្យោបាយដឹកជញ្ជូនអាវុធទាំងនេះ។ "មធ្យោបាយដឹកជញ្ជូន" ត្រូវបានផ្តល់និយមន័យដ៏ទូលាយមួយដោយកថាខណ្ឌទី ៤៥(២)។

### ផ្នែកទី ៥: ការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ

ផ្នែកនេះអនុវត្ត*អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ*។

### មាត្រា ៤៦.- ការកាន់កាប់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ

មាត្រានេះកំណត់ជាបទល្មើសចំពោះការកាន់កាប់ដោយចេតនានូវសារធាតុវិទ្យុសកម្ម ឬ គ្រឿងនុយក្លេអ៊ែរ (តាមការកំណត់នៃមាត្រា ៣៥) ឬ ការធ្វើគ្រឿងនុយក្លេអ៊ែរក្នុងគោលបំណងបណ្តាលឱ្យមានការស្លាប់ របួសរូបរាង្គកាយធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរចំពោះទ្រព្យ ឬ បរិស្ថាន។ ក្នុងន័យនេះ មាត្រានេះគឺត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់ការវាយប្រហារភេរវកម្មកុំឱ្យកើតឡើង តែមិនមែនគ្រាន់តែដាក់ទោសឧក្រិដ្ឋលើការវាយប្រហារតែប៉ុណ្ណោះទេ។

### មាត្រា ៤៧.- អំពើទាំងឡាយដែលពាក់ព័ន្ធនឹងសារធាតុវិទ្យុសកម្ម គ្រឿងនុយក្លេអ៊ែរ បរិក្ខារនុយក្លេអ៊ែរ

មាត្រានេះបង្កើតបទល្មើសចំពោះការប្រើប្រាស់សារធាតុវិទ្យុសកម្ម ឬ គ្រឿងនុយក្លេអ៊ែរ ទោះជាតាមវិធីណាក្តី ក្នុងគោលបំណងបណ្តាលឱ្យមានការស្លាប់ របួសរូបរាង្គកាយធ្ងន់ធ្ងរ ឬ ការខូចខាតធ្ងន់ធ្ងរចំពោះទ្រព្យ ឬ បរិស្ថាន ឬ ក្នុងគោលបំណងបង្ខំភាគីទីបីណាមួយឱ្យធ្វើ ឬ មិនធ្វើអំពើណាមួយក្តី។ បុគ្គលដែលមានគោលបំណងដូច្នេះ ដែលប្រើ ឬ ធ្វើឱ្យខូចខាតដល់បរិក្ខារនុយក្លេអ៊ែរ ក្នុងលក្ខណៈមួយដែលបង្កើតហានិភ័យ ឬ ការសាយភាយសារធាតុនុយក្លេអ៊ែរជាក់ស្តែង ក៏នឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះផងដែរ។ បុគ្គលណាមួយដែលគំរាមកំហែងថានឹងប្រព្រឹត្តអំពើទាំងនេះណាមួយ នឹងមានពុរុទ្ធភាពចំពោះបទល្មើសតាមបញ្ញតិនៃមាត្រា ៤៨។

### មាត្រា ៤៨.- ការគំរាមកំហែង និងការទាមទារ

កថាខណ្ឌរងទី ៤៨(ក) នៃមាត្រានេះចែងថា បុគ្គលណាមួយដែលគំរាមកំហែងថានឹងប្រព្រឹត្តអំពើណាមួយដែលមានចែងក្នុងមាត្រា ៤៧ នឹងមានពិរុទ្ធភាពចំពោះបទល្មើស។

បុគ្គលណាដែលទាមទារសារធាតុវិទ្យុសកម្ម គ្រឿងនុយក្លេអ៊ែរ ឬ បរិក្ខារនុយក្លេអ៊ែរ ក៏នឹងប្រព្រឹត្តបទល្មើសផងដែរ។ ការទាមទារអាច ឬ មិនអាចរួមមានការប្រើកម្លាំងដើម្បីឱ្យក្លាយទៅជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។ ប៉ុន្តែ ការទាមទារត្រូវតែអាចយកជាការបាន ឬ គួរឱ្យជឿបាន នៅក្នុងស្ថានភាពនោះ។

## ជំពូកទី ៧ ៊ អំពើប្រឆាំងនឹងសុវត្ថិភាពនាវាចរណ៍ផ្លូវសមុទ្រ

### ផ្នែកទី ១: ការអនុវត្ត

### មាត្រា ៤៩.- ការមិនអនុវត្តជំពូកនេះ

មាត្រានេះកំណត់ថា ជំពូកទី ៧ នឹងមិនអនុវត្តចំពោះនាវាដោយឡែកណាមួយដែលត្រូវបានប្រើប្រាស់ដើម្បីគោលបំណងជាក់លាក់ណាមួយឡើយ។ នាវាទាំងនេះគឺនាវាចំបាំងដែលជាកម្មសិទ្ធិ ឬ ធ្វើប្រតិបត្តិការដើម្បីគោលបំណងយោធាជើងទឹក យោធា គយ ឬ

នគបាល ឬ សំរាប់អនុវត្តច្បាប់ និងនាវាដែលត្រូវបានដកចេញពីសេវាកម្ម ឬ "ដែលប្រើការលែងកើត"។ នាវាចំបាំងមិនចាំបាច់ជាកម្មសិទ្ធិរបស់កម្ពុជាឡើយ ដែលនឹងត្រូវលើកលែងពីជំពូកទី ៧។ នាវាបំបែកទឹកកក និងនាវាស្រាវជ្រាវមិនត្រូវបានរាប់បញ្ចូលក្នុងករណីលើកលែងឡើយ ប្រសិនបើត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទាំងនោះ។

## ផ្នែកទី ២: បទល្មើស

### មាត្រា ៥០.- ការរឹបអូស ឬ ការត្រួតត្រាលើនាវា

មាត្រានេះគឺមានលក្ខណៈដូចគ្នាណាស់ជាមួយនឹងមាត្រា ១៥ ដែលអនុវត្តចំពោះចោរប្លន់អាកាសយាន។ វាអនុវត្ត មាត្រា ៣(១)(ក) នៃ*អនុសញ្ញាសម្រាប់ការបង្ក្រាបសកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនាវាចរណ៍ផ្លូវសមុទ្រ* (អនុសញ្ញាក្រុងរ៉ូម)។

ការរឹបអូសនាវាត្រូវតែមានលក្ខណៈខុសច្បាប់។ មានករណីខ្លះដែលនៅក្នុងនោះ កម្លាំង ឬ ការគំរាមប្រើកម្លាំង អាចមានលក្ខណៈចាំបាច់ដើម្បីអនុវត្តសកម្មភាពស្របច្បាប់មួយ។ ឧទាហរណ៍មួយនៃករណីនេះ គឺការដណ្តើមយកការគ្រប់គ្រងនាវាដែលត្រូវបានរឹបអូសដោយភេរវករ ដែលគឺជាយុត្តិកម្មតាមបញ្ញត្តិនៃមាត្រា ៨។

### មាត្រា ៥១.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើនាវា

មាត្រានេះគឺមានលក្ខណៈដូចគ្នានឹងមាត្រា ១៦ ដែលអនុវត្តក្នុងបរិបទប្លន់អាកាសយាន។ វាអនុវត្តមាត្រា ៣(១)(ខ) នៃអនុសញ្ញាក្រុងរ៉ូម។ ចំណុចមួយនៃបទល្មើសគឺថា អំពើហិង្សាត្រូវតែអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍របស់នាវា។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញតិនៃមាត្រានេះគឺថា ប្រសិនបើជនណាម្នាក់ហៀបនឹងវាយប្រហារយ៉ាងខ្លាំងក្លាលើមេបញ្ជាការនាវា ដើម្បីកុំឱ្យគាត់អាចបើកបរនាវាបាន ប្រកបដោយសុវត្ថិភាព។

### មាត្រា ៥២.- ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតនាវា

មាត្រានេះគឺមានលក្ខណៈស្របគ្នាជាមួយនឹងមាត្រា ១៧ ដែលពាក់ព័ន្ធការធ្វើឱ្យខូចខាត ឬការបំផ្លាញអាកាសយានមួយ។ វាអនុវត្តមាត្រា ៣(១)(គ) នៃអនុសញ្ញាក្រុងរ៉ូម។

ឧទាហរណ៍ តាមបញ្ញត្តិនៃមាត្រានេះ ជនម្នាក់នឹងមានពិរុទ្ធភាពចំពោះបទល្មើស ប្រសិនបើខ្លួនបំផ្លាញនាវាដោយធ្វើឱ្យផ្ទុះគ្រាប់បែកលើនាវា។

វាក៏នឹងជាបទល្មើសផងដែរ ប្រសិនបើជនណាម្នាក់ធ្វើឱ្យខូចខាតដល់នាវា ឬ ទំនិញរបស់វា ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនាវាចរណ៍របស់នាវា។ ឧទាហរណ៍ ប្រសិនបើនាវាមួយដឹកទំនិញគីមី ហើយត្រូវបានធ្វើឱ្យខូចខាតដោយវិធីណាមួយ ដែលនាំឱ្យមានអសុវត្ថិភាពដល់នាយនាវា និងនាវិកក្នុងការបន្តស្ថិតនៅលើនាវា និងបើកបរនាវានោះ ប្រការនេះនឹងគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ៥៣.- ការដាក់ឧបករណ៍ ឬ សារធាតុលើនាវា

មាត្រានេះគឺមានលក្ខណៈដូចគ្នាជាមួយនឹងមាត្រា ១៨។ វាអនុវត្តមាត្រា ៣(១)(ឃ) នៃអនុសញ្ញាក្រុងរ៉ូម។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះគឺថា ប្រសិនបើជនណាម្នាក់ធ្វើឱ្យផ្ទុះគ្រឿងផ្ទុះមួយលើនាវា ដែលបំផ្លាញនាវានោះ ឬ ធ្វើឱ្យខូចខាតខ្លាំងដែលនាវាមិនអាចបើកបរយ៉ាងសមស្របដោយសុវត្ថិភាពបាន។ ឧទាហរណ៍មួយទៀតគឺប្រសិនបើជនណាម្នាក់បញ្ចេញជាតិគីមីប្រល័យ ដែលបណ្តាលឱ្យមានជម្ងឺធ្ងន់ធ្ងរដល់នាវិក ដែលក្រោយពេលនោះមិនអាចបំពេញមុខងារខ្លួនយ៉ាងពេញលេញ និងបើកបរនាវាប្រកបដោយសុវត្ថិភាព។

## មាត្រា ៥៤.- ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតដល់ប្រព័ន្ធឧបករណ៍តម្រង់ទិសនាវាចរណ៍

មាត្រានេះគឺមានលក្ខណៈដូចគ្នាជាមួយនឹងមាត្រា ១៩។ វាអនុវត្តមាត្រា ៣(១)(ង) នៃអនុសញ្ញាក្រុងរ៉ូម។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ គឺរួមមានប្រការដែលថាប្រសិនបើជនណាម្នាក់បំផ្លាញប្រព័ន្ធបង្ហាញទីកន្លែងភូមិសាស្ត្រ (GPS) និងបរិក្ខារវិទ្យុលើនាវា ដែលធ្វើអោយសុវត្ថិភាពនៃនាវាចរណ៍ត្រូវបានបំផ្លាញ។ ដូចគ្នានេះដែរប្រសិនបើជនណាម្នាក់បំផ្លាញបរិក្ខារនាវាចរណ៍លើដី ដូចជាអង់តែនគ្រប់គ្រងវិទ្យុដែលត្រូវបានប្រតិបត្តិការដោយអាជ្ញាធរកំពង់ផែ ជននោះនឹងប្រព្រឹត្ត បទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។ បរិក្ខារនាវាចរណ៍ផ្លូវសមុទ្រពុំចាំបាច់សុទ្ធតែនៅលើនាវាទេ។

## មាត្រា ៥៥.- ការផ្តល់ព័ត៌មានមិនពិតដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវា

មាត្រានេះអនុវត្តមាត្រា ៣(១)(ច) នៃអនុសញ្ញាក្រុងរ៉ូម។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះគឺរួមមានប្រការដែលថា ប្រសិនបើជនណាម្នាក់បានជូនព័ត៌មានមិនពិតអំពីទីកន្លែងនាវាដោយចេតនា ដែលជាហេតុបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពធ្វើដំណើររបស់នាវានោះ។

## មាត្រា ៥៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសនៅក្នុងជំពូកនេះ

មាត្រានេះអនុវត្តមាត្រា ៣(១)(ឆ) នៃអនុសញ្ញាក្រុងរ៉ូម។ តាមបញ្ញត្តិនៃមាត្រានេះ វាគឺជាបទល្មើសចំពោះការបង្កឱ្យមានការស្លាប់របស់ជនដទៃម្នាក់ទៀត នៅពេលដែលប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រា ៥០ ដល់មាត្រា ៥៥។ ជននោះមិនចាំបាច់ត្រូវបានចោទប្រកាន់ ឬ ត្រូវបានដាក់ទោសអំពីការប្រព្រឹត្តបទល្មើស តាមបញ្ញត្តិនៃមាត្រា ៥១ ដល់មាត្រា ៥៥ ឡើយ សម្រាប់ការដាក់ទោសតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ៥៧.- អំពើបង្ករបួសដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ

មាត្រានេះអនុវត្តមាត្រា ៣(១)(ឆ) នៃអនុសញ្ញាក្រុងរ៉ូម។ មាត្រានេះកំណត់ថា ជាបទល្មើសចំពោះការបណ្តាលឱ្យមានរបួសដល់ជនដទៃម្នាក់ទៀត ខណៈប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រា ៥០ ដល់មាត្រា ៥៥។ ជាថ្មីម្តងទៀត ជនជាប់ចោទមិនចាំបាច់ត្រូវបានចោទប្រកាន់ ឬ ត្រូវបានដាក់ទោសអំពីការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រា ៥០ ដល់មាត្រា ៥៥ ឡើយ ដើម្បីដាក់ទោសលើបទល្មើស តាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ៥៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់នាវាចរណ៍ប្រកបដោយសុវត្ថិភាពរបស់នាវា

មាត្រានេះអនុវត្តមាត្រា ៣(២)(គ) នៃអនុសញ្ញាក្រុងរ៉ូម។ វានឹងគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះចំពោះការគំរាមកំហែងថា នឹងប្រព្រឹត្តអំពើមួយដែលជាបទល្មើសតាមបញ្ញត្តិ

នៃមាត្រា ៥១, ៥២ និងមាត្រា ៥៤ ដែលរួមមានការធ្វើអំពើហិង្សាលើជនណាម្នាក់លើនាវា ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតដល់បរិក្ខារតម្រង់ទិសនាវាចរណ៍។ វាក៏គឺជាលក្ខខណ្ឌនៃមាត្រានេះផងដែរដែលថា ជនដែលធ្វើការគំរាមកំហែងនោះ ធ្វើដូច្នេះដោយមានបំណងបង្ខំ ឬ លួងលោមឱ្យជនណាម្នាក់ ឬ អង្គភាពមួយ (ដូចមានរាយបញ្ជីក្នុងកថាខណ្ឌរងទី ៥៨(គ)) ឱ្យធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ។

## ផ្នែកទី ៣: សិទ្ធិអំណាចរបស់មេបញ្ជាការនាវា

### មាត្រា ៥៩.- សិទ្ធិអំណាចក្នុងការប្រគល់ ជាអាទិ៍ នូវបុគ្គលណាមួយទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច

មាត្រានេះគឺដូចមាត្រា ២៨ ដែលអនុវត្តក្នុងបរិបទនៃបទល្មើសទាំងឡាយលើអាកាសយាន។ វាអនុវត្តមាត្រា ៨ នៃអនុសញ្ញាក្រុងរ៉ូម។ តាមបញ្ញត្តិនៃមាត្រានេះ មេបញ្ជាការនាវាអាចឃុំខ្លួនជនណាម្នាក់ ហើយប្រគល់ខ្លួនជននោះទៅឱ្យអាជ្ញាធរទាំងឡាយរបស់រដ្ឋដែលគឺជាភាគីនៃអនុសញ្ញាក្រុងរ៉ូម (រដ្ឋអនុសញ្ញា) ប្រសិនបើមេបញ្ជាការនាវានោះមានមូលហេតុសមហេតុផលនឹងជឿថា ជននោះបានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃផ្នែកទី ២ នៃជំពូកនេះ។ ដូចគ្នានឹងករណីមេបញ្ជាការអាកាសយានដែរ មេបញ្ជាការនាវាត្រូវតែផ្តល់ដំណឹងដល់អាជ្ញាធររដ្ឋ ពាក់ព័ន្ធអំពីបំណងរបស់ខ្លួនក្នុងការប្រគល់ខ្លួនជននោះ និងមូលហេតុនៃការធ្វើដូច្នេះ។ មេបញ្ជាការនាវាត្រូវតែផ្តល់ជូនអាជ្ញាធរទាំងឡាយនៃរដ្ឋដែលទទួលផងដែរនូវ ភស្តុតាងទាំងអស់ដែលជាកម្មសិទ្ធិរបស់មេបញ្ជាការនាវានោះ ដែលពាក់ព័ន្ធនឹងបទល្មើសដែលត្រូវបានចោទប្រកាន់។

### មាត្រា ៦០.- ពុំមានទោសបញ្ញត្តិចំពោះការឃាត់ខ្លួនស្របច្បាប់

មាត្រានេះចែងថាមេបញ្ជាការនាវា ម្ចាស់ ឬ ប្រតិបត្តិករនាវា ឬ ជនដទៃណាទៀតដែលទទួលបន្ទុកលើការធ្វើដំណើររបស់នាវា នឹងមិនត្រូវទទួលខុសត្រូវលើសកម្មភាពដែលបានធ្វើស្របតាមជំពូកនេះ នៅក្នុងចំណាត់ការរដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌឡើយចំពោះការឃាត់ខ្លួន ការឃុំខ្លួន ឬ ការបញ្ជូនជនណាមួយ។ ប៉ុន្តែ ដោយសារតែមេបញ្ជាការនាវា ជានិច្ចកាលត្រូវតែប្រើអំណាចរបស់ខ្លួន តែនៅពេលណាដែលមានមូល

ហេតុសមហេតុសមផលនឹងជឿថា ការប្រើអំណាចរបស់ខ្លួនគឺចាំបាច់ ដើម្បីឱ្យជននោះអាចតវ៉ាប្រឆាំងនឹងបញ្ហានេះបាននៅតុលាការ។

នាវិក និងអ្នកធ្វើដំណើរក៏ត្រូវបានការពារផងដែរពីការទទួលខុសត្រូវលើអំពើនានាដែលបានធ្វើក្រោមសមត្ថកិច្ចរបស់មេបញ្ជាការនាវា នៅទីណាដែលមេបញ្ជាការនាវាមានមូលហេតុសមហេតុសមផលនឹងជឿថា ជនម្នាក់បានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តបទល្មើសមួយតាមបញ្ញត្តិនៃផ្នែកទី ២ នៃជំពូកនេះ។

## ជំពូកទី ៨ ~ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចល័តដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រ

### ផ្នែកទី ១: ការបកស្រាយ

#### មាត្រា ៦១.- និយមន័យ

មាត្រានេះកំណត់និយមន័យនៃពាក្យ "ទីតាំងអចល័ត"។ និយមន័យនេះគឺដូចគ្នានឹងនិយមន័យដែលត្រូវបានប្រើនៅក្នុងមាត្រា ១(៣) នៃ*ពិធីសារស្តីពីការបង្ក្រាបសកម្មភាពខុសច្បាប់ប្រឆាំងនឹង សុវត្ថិភាពនៃទីតាំងអចល័តដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រឆ្នាំ ១៩៨៨* (ពិធីសារស្តីពីទីតាំងអចល័ត)។

ទីតាំងខ្វងចល័តក្នុងសមុទ្រដែលត្រូវបានភ្ជាប់ជាបណ្តោះអាសន្នទៅនឹងបាតសមុទ្រ ហើយដែលត្រូវបានតភ្ជាប់ទៅកាន់ និងមកពីគោលដៅរបស់វា គឺពុំមែនជាទីតាំងអចល័តឡើយ ប៉ុន្តែត្រូវបានរាប់បញ្ចូលនៅក្នុងជំពូកទី ៧ ដោយសារវាស្ថិតនៅក្នុងនិយមន័យនៃ "នាវា" ដែលជានាវាមិនត្រូវបានភ្ជាប់ជាអចិន្ត្រៃយ៍ទៅនឹងបាតសមុទ្រ។

### ផ្នែកទី ២: បទល្មើស

#### មាត្រា ៦២.- ការផ្តើមកាន់កាប់ការត្រួតត្រាលើទីតាំងអចល័ត

មាត្រានេះកំណត់ជាបទល្មើសចំពោះការផ្តើមកាន់កាប់ ការត្រួតត្រាលើទីតាំងអចល័តដែលដូចគ្នានឹងការប្លន់អាកាសយានមួយដែរ។ មាត្រានេះអនុវត្តមាត្រា ២(១) នៃពិធីសារ

ស្ដីពីទីតាំងអចល័ត។

## មាត្រា ៦៣.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើទីតាំងអចល័ត

មាត្រានេះ កំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើហិង្សាដែលត្រូវបានប្រព្រឹត្តលើទីតាំងអចល័ត។ មាត្រានេះអនុវត្តមាត្រា ២(១)(ខ) នៃពិធីសារស្ដីពីទីតាំងអចល័ត។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះគឺថា ប្រសិនបើជនណាម្នាក់បាញ់អាវុធដោយមានបំណងសម្លាប់ជនណាម្នាក់នៅលើទីតាំងអចល័ត ប៉ុន្ដែបែរជាបាញ់ត្រូវធុងដាក់គីមី ដែលបណ្ដាលឱ្យមានការឆាបឆេះទៅវិញ។ ដូចគ្នានេះដែរ ប្រសិនបើជនណាម្នាក់វាយប្រហារ ឬ សម្លាប់ជនណាម្នាក់ដែលមានតួនាទីសំខាន់នៅលើទីតាំងអចល័ត ដែលនាំឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់ទីតាំងអចល័ត សកម្មភាពនេះគឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។

## មាត្រា ៦៤.- ការកម្ទេច ការធ្វើឱ្យខូចខាតទីតាំងអចល័ត

មាត្រានេះអនុវត្តមាត្រា ២(១)(គ) នៃពិធីសារស្ដីពីទីតាំងអចល័ត។ ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះគឺថា ប្រសិនបើទូកនេសាទមួយដែលដឹកគ្រឿងផ្ទុះ ត្រូវបានបើកទៅកាន់ទីតាំងអចល័តមួយ ហើយធ្វើឱ្យផ្ទុះ កម្ទេច ឬ បណ្ដាលឱ្យមានការខូចខាតដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័តនោះ។

## មាត្រា ៦៥.- ការដាក់ឧបករណ៍ ឬ សារធាតុនៅលើទីតាំងអចល័ត

មាត្រានេះ អនុវត្តមាត្រា ២(១)(ឃ) នៃពិធីសារស្ដីពីទីតាំងអចល័ត។ ដើម្បីក្លាយជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ ឧបករណ៍ ឬ សារធាតុត្រូវតែត្រូវបានដាក់លើទីតាំងអចល័តមួយ និងត្រូវតែអាចបំផ្លាញទីតាំង ឬ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័តនោះ។

## មាត្រា ៦៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ

មាត្រានេះអនុវត្តមាត្រា ២(១)(ង) នៃពិធីសារស្ដីពីទីតាំងអចល័ត។ ជនណាដែលបណ្ដាលឱ្យជនដទៃស្លាប់ ខណៈដែលប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៦២ ដល់មាត្រា ៦៥ នឹងមានពិរុទ្ធភាពចំពោះបទល្មើស។ ឧទាហរណ៍ ប្រសិនបើជនណា

ម្នាក់ដណ្ដើមការគ្រប់គ្រងលើទីតាំងអចល័តមួយ ដែលជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រា ៦២ ហើយនៅក្នុងព្រឹត្តិការណ៍នោះ បានសម្លាប់អ្នកណាម្នាក់ ជននោះអាចត្រូវបានចោទប្រកាន់ពីបទល្មើសមួយតាមបញ្ញត្តិនៃមាត្រា ៦២ និង មាត្រា ៦៦។ ប៉ុន្តែករណីនេះមិនចាំបាច់សុទ្ធតែអញ្ចឹងនោះទេ។ ជនម្នាក់អាចត្រូវបានចោទប្រកាន់តាមបញ្ញត្តិនៃមាត្រា ៦៦ ដោយមិនចាំបាច់ត្រូវបានចោទប្រកាន់ និងដាក់ទោសចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រា ៦២ ដល់មាត្រា ៦៥ ឡើយ។

## មាត្រា ៦៧.- អំពើបង្ករបួសពាក់ព័ន្ធនឹងបទល្មើសក្នុងជំពូកនេះ

មាត្រានេះអនុវត្តមាត្រា ២(១)(ង) នៃពិធីសារស្តីពីទីតាំងអចល័ត។ មាត្រានេះគឺដូចមាត្រា ៦៦ ប៉ុន្តែជំនួសលក្ខខណ្ឌធ្វើឱ្យស្លាប់ដល់ជនដទៃ ជននោះត្រូវតែបណ្ដាលឱ្យមានរបួសដល់ជនដទៃ ពាក់ព័ន្ធនឹងការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃមាត្រា ៦២ ដល់មាត្រា ៦៥។

## មាត្រា ៦៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងអចល័ត

មាត្រានេះចាត់ទុកជាបទល្មើសចំពោះការគំរាមកំហែងថា នឹងប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងជនណាម្នាក់នៅលើទីតាំងអចល័ត ដែលអាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំងនោះ បំផ្លាញទីតាំងអចល័ត ឬ បង្កឱ្យខូចខាតទីតាំងអចល័ត តាមរបៀបមួយដែលអាចបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំង។ មាត្រានេះអនុវត្តមាត្រា ២(២)(គ) នៃពិធីសារស្តីពីទីតាំងអចល័ត។

ដូចករណីបទល្មើសតាមបញ្ញត្តិនៃមាត្រា ៥៨ ដែរ ការគំរាមកំហែងត្រូវតែធ្វើឡើងដោយមានបំណងបង្ខំបុគ្គល ឬ ស្ថាប័នមួយ (ដែលមានរាយបញ្ជីនៅក្នុងកថាខណ្ឌទីរង ៦៨(ខ)) ឱ្យធ្វើ ឬ មិនឱ្យធ្វើអំពើណាមួយ។

ឧទាហរណ៍មួយនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះគឺថា ប្រសិនបើជនជាតិខ្មែរម្នាក់គំរាមកំហែងថា នឹងធ្វើឱ្យផ្ទុះជាតិផ្ទុះដែលខ្លួនបានដាក់លើទីតាំងអចល័តមួយដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រនៃរដ្ឋបរទេសមួយ លុះត្រាណាតែរដ្ឋាភិបាលបរទេសនោះ ធ្វើអំពើណាមួយ (ដូចជាការដោះលែងជនជាប់ពន្ធនាគារណាមួយពីការឃុំឃាំង)។

# ជំពូកទី ៩ ~ ការដាក់សញ្ញាសម្គាល់គ្រឿងផ្ទុះផ្លាស្ទិកសម្រាប់គោលបំណងរកឃើញ

## ផ្នែកទី ១: ការបកស្រាយ

### មាត្រា ៦៩.- និយមន័យ

មាត្រានេះកំណត់និយមន័យនៃពាក្យមួយចំនួនដែលប្រើក្នុងជំពូកទី ៩។

ការលើកឡើងពី "គ្រឿងផ្ទុះ" គឺជាគ្រឿងផ្ទុះផ្លាស្ទិក។ គ្រឿងផ្ទុះផ្លាស្ទិកទាំងនេះគឺទន់ និងស្រួលបត់បែន។ វាមានស្ថេរភាពណាស់រហូតដល់ពេលធ្វើឱ្យផ្ទុះ ហើយអាចធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរ សូម្បីតែក្នុងបរិមាណតិចតួចក្តី។ គ្រឿងផ្ទុះទាំងនេះពិតជាមានគោលបំណងស្របច្បាប់។ វាត្រូវបានប្រើជារឿយៗដោយវិស្វករ ប៉ុន្តែវាត្រូវបានប្រើដោយភេរវករក្នុងពេលកន្លងមកនេះ។

### មាត្រា ៧០.- ការពិពណ៌នាគ្រឿងផ្ទុះ

មាត្រានេះផ្តល់ការពិពណ៌នាខាងវិទ្យាសាស្ត្របន្ថែមទៀត លើគ្រឿងផ្ទុះដែលជំពូកទី ៩ អនុវត្ត។ ការពិពណ៌នាទាំងនេះត្រូវបានដកស្រង់ពីឧបសម្ព័ន្ធបច្ចេកទេសនៃ *អនុសញ្ញាស្តីពីការដាក់សញ្ញាគ្រឿងផ្ទុះផ្លាស្ទិកសម្រាប់គោលបំណងរកឃើញ* (MARPLEX)។ កថាខណ្ឌទី ៧០(២) រាយបញ្ជីគ្រឿងផ្ទុះដែលត្រូវបានប្រើសម្រាប់គោលបំណងជាក់លាក់ ដែល*ពុំ*ត្រូវបានចាត់ទុកថាជាគ្រឿងផ្ទុះសម្រាប់គោលបំណងនៃជំពូកទី ៩។ គ្រឿងផ្ទុះទាំងនេះ គឺជាគ្រឿងផ្ទុះដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងស្របច្បាប់ ដូចជាការស្រាវជ្រាវ និងការបណ្តុះបណ្តាលក្នុងការស្វែងរកគ្រឿងផ្ទុះ។

### មាត្រា ៧១.- សារធាតុរកគ្រឿងផ្ទុះ

មាត្រានេះយោងដល់ឧបសម្ព័ន្ធ ៣ នៃច្បាប់នេះ ដែលរាយបញ្ជី "សារធាតុរកគ្រឿងផ្ទុះ"។ សារធាតុទាំងនេះគឺជាសារធាតុគីមីដែលត្រូវបានដាក់ចូលក្នុងគ្រឿងផ្ទុះដែលធ្វើឱ្យគ្រឿងផ្ទុះអាចត្រូវបានរកឃើញដោយវិធីមើលចំហាយ។ គ្រឿងផ្ទុះត្រូវបានកំណត់ថា "ត្រូវបានដាក់សញ្ញា" ជាមួយសារធាតុរកគ្រឿងផ្ទុះ។ ហេតុនេះ គ្រឿងផ្ទុះទាំងឡាយណាដែលមានដាក់សញ្ញាសារធាតុរកគ្រឿងផ្ទុះណាមួយ នឹងពុំត្រូវស្ថិតក្នុងបទល្មើសក្នុងផ្នែកទី ២ ឡើយ។

## ផ្នែកទី ២: បទល្មើស

### មាត្រា ៧២.- ការផលិតគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់

មាត្រានេះចាត់ទុកជាបទល្មើស ចំពោះការផលិតគ្រឿងផ្ទុះផ្លាស្ទិកនៅប្រទេសកម្ពុជាដែលពុំដាក់បញ្ចូលសារធាតុរកគ្រឿងផ្ទុះនៅក្នុងកំហាប់តាមការកំណត់។ មាត្រានេះអនុវត្តមាត្រា II នៃអនុសញ្ញា MARPLEX។

### មាត្រា ៧៣.- ការកាន់កាប់ ការដឹកជញ្ជូន ការនាំចេញ ការនាំចូលនូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់

មាត្រានេះអនុវត្តមាត្រា III នៃអនុសញ្ញា MARPLEX។ មាត្រានេះចាត់ទុកជាបទល្មើសចំពោះការនាំចូលមក ឬ ការនាំចេញពីប្រទេសកម្ពុជានូវគ្រឿងផ្ទុះគ្មានសញ្ញា។ វាក៏កំណត់ផងដែរនូវបទល្មើសចំពោះការកាន់កាប់ ឬ ការដឹកជញ្ជូនគ្រឿងផ្ទុះគ្មានសញ្ញា។ ហេតុនេះ ការដឹកជញ្ជូនគ្រឿងផ្ទុះគ្មានសញ្ញានៅក្នុងដែនដីកម្ពុជា គឺជាបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ។ បទល្មើសទាំងនេះគឺដើម្បីទទួលស្គាល់ នូវសក្តានុពលគ្រោះថ្នាក់បណ្តាលមកពីអត្ថិភាពនៃគ្រឿងផ្ទុះគ្មានសញ្ញា ដែលអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងមិនសមស្រប។

កថាខណ្ឌទី ៧៣(២) បង្កើតករណីលើកលែងមួយចំពោះការហាមឃាត់ទូទៅនៅក្នុងកថាខណ្ឌទី ៧៣(១)។ ករណីលើកលែងនេះអនុញ្ញាតិការនាំចូល និងនាំចេញគ្រឿងផ្ទុះគ្មានសញ្ញា នៅពេលណាការនាំចេញនាំចូលនេះត្រូវបានធ្វើដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់គោលបំណងបំពេញមុខងារយោធា ឬ នគរបាល ហើយមុខងារ ឬ គោលបំណងនេះ មានសង្គតិភាពជាមួយនឹងកម្មវត្ថុនៃអនុសញ្ញា MARPLEX។ កម្មវត្ថុនៃអនុសញ្ញា MARPLEX គឺដើម្បីធានាឱ្យបានថា ប្រទេសទាំងឡាយអនុវត្តការគ្រប់គ្រងដ៏ហ្មត់ចត់ និងប្រកបដោយប្រសិទ្ធិភាពលើការកាន់កាប់ និងការផ្លាស់ទីនៃគ្រឿងផ្ទុះផ្លាស្ទិក (ពោលគឺ គ្រឿងផ្ទុះគ្មានសញ្ញាដែលមាននៅក្នុងបូរណភាពដែនដីរបស់ខ្លួន មុនពេលចូលជាធរមាននៃអនុសញ្ញានេះ ឬ ដែលត្រូវបានផលិតចាប់តាំងពីពេលនោះមកតាមបញ្ញត្តិនៃកថាខណ្ឌទី ៧៣(២)) ដើម្បីទប់ស្កាត់ការបង្វែងសម្រាប់ការប្រើប្រាស់មិនសមស្រប។

## ជំពូកទី ១០ ៖ ការដាក់គ្រាប់បែកភេរវកម្ម

### ផ្នែកទី ១៖ ការបកស្រាយ

### មាត្រា ៧៤.- និយមន័យ

មាត្រានេះ កំណត់និយមន័យនៃពាក្យទាំងឡាយដែលត្រូវបានប្រើក្នុងនិងដើម្បីគោលបំណងនៃជំពូកទី ១០។ សូមកត់សម្គាល់ថា និយមន័យនៃ "ជាតិផ្ទុះ ឬ គ្រឿងប្រល័យដទៃទៀត គឺរាប់បញ្ចូលគ្រឿងណាដែលមានលទ្ធភាពបណ្តាលឱ្យស្លាប់ របួសរាង្គកាយធ្ងន់ធ្ងរ ឬ ការខូចខាតសម្ភារៈច្រើន ទោះបីជាវាមិនត្រូវបានធ្វើឡើងសម្រាប់គោលបំណងនេះក្តី។

### ផ្នែកទី ២៖ បទល្មើស

### មាត្រា ៧៥.- ការបញ្ជូន ការដាក់ ការបាញ់ឬការធ្វើឱ្យផ្ទុះគ្រឿងផ្ទុះ ឬ គ្រឿងប្រល័យនៅទីកន្លែងសាធារណៈ ជាអាទិ៍

មាត្រានេះអនុវត្តមាត្រា ២(១) នៃ*អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់គ្រាប់បែកភេរវកម្ម* ។ បទល្មើសតាមបញ្ញតិនៃមាត្រានេះមានពីរចំណុច។ ចំណុចទីមួយគឺថា ជនណាម្នាក់ធ្វើសកម្មភាពណាមួយ ដូចជា ការធ្វើឱ្យផ្ទុះគ្រឿងផ្ទុះ ឬ គ្រឿងប្រល័យនៅក្នុងទីកន្លែងសាធារណៈ បរិវេណរដ្ឋ ឬ រដ្ឋាភិបាល ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ឬ បរិក្ខារហេដ្ឋារចនាសម្ព័ន្ធ។ ទីកន្លែងទាំងអស់នេះត្រូវបានផ្តល់និយមន័យដ៏ទូលាយនៅក្នុងមាត្រា ៣ និងមាត្រា ៧៤ និងរាប់បញ្ចូលស្ថានទូតបរទេសដែលស្ថិតនៅក្នុងប្រទេសកម្ពុជា អាគារក្រសួងរដ្ឋាភិបាលកម្ពុជា ប្រព័ន្ធផ្លូវដែក ស្ពាន ទីកន្លែងគោរពសក្ការៈ ស្ថានីយអគ្គិសនី ឬ រោងចក្រសំអាតទឹកល្អ។

ចំណុចទីពីរនៃបទល្មើសតាមបញ្ញតិនៃមាត្រានេះគឺថា ជនណាម្នាក់ប្រព្រឹត្តអំពើដោយមានគោលបំណងបណ្តាលឱ្យស្លាប់ របួសរាង្គកាយធ្ងន់ធ្ងរ ឬ ការបំផ្លាញធ្ងន់ធ្ងរដែលនាំឱ្យមាន ឬ ដែលអាចនាំឱ្យមានការខាតបង់ខាងផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរ។

## ជំពូកទី ១១ - ហិរញ្ញប្បទាន និងជំនួយសម្រាប់ភេរវកម្ម

### ផ្នែកទី ១: បទល្មើស

### មាត្រា ៧៦.- ការផ្តល់ឬការប្រមូលទ្រព្យសម្រាប់ប្រើប្រាស់ក្នុងអំពើភេរវកម្ម ឬ ក្នុងការជួយដល់ភេរវករ

មាត្រានេះអនុវត្តមាត្រា ២ នៃ*អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបហិរញ្ញប្បទានភេរវកម្ម* (អនុសញ្ញាហិរញ្ញប្បទាន) និងមាត្រា ១(ខ) នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣៧៣។ មាត្រានេះកំណត់ជាបទល្មើសចំពោះការផ្តល់ ឬ ការប្រមូលទ្រព្យដែលនឹងត្រូវបានប្រើដើម្បីប្រព្រឹត្តអំពើដែលជាបទល្មើសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ដូចគ្នារបស់រដ្ឋបរទេស ឬ អំពើមួយដែលមានបំណងបណ្តាលឱ្យស្លាប់ ឬ របួសរាង្គកាយធ្ងន់ធ្ងរ ប្រសិនបើគោលបំណងនៃអំពើនោះគឺដើម្បីបំភិតបំភ័យប្រជាជន ឬ ដើម្បីបង្ខំរដ្ឋាភិបាលមួយឱ្យធ្វើ ឬ មិនឱ្យធ្វើសកម្មភាពណាមួយ។

ការផ្តល់ ឬ ការប្រមូលទ្រព្យ រាប់បញ្ចូលទ្រព្យ (ដូចមានកំណត់និយមន័យក្នុងមាត្រា ៣) ដែលបានមកដោយមធ្យោបាយស្របច្បាប់ ពោលគឺ ការប្រមូល ឬ ការផ្តល់ទ្រព្យត្រូវតែបានធ្វើដោយជនណាម្នាក់ដែលមានបំណង ឬ ដឹងថាទ្រព្យនេះនឹងត្រូវបានប្រើប្រាស់ទាំងមូល ឬ មួយចំណែកសម្រាប់គោលបំណងទាំងឡាយដែលមានចែងក្នុងមាត្រា ៧៦។ តាមវិធីនេះ ការហាមឃាត់ហិរញ្ញប្បទានភេរវកម្ម គឺខុសគ្នាច្រើនពីច្បាប់ទាំងឡាយដែលហាមឃាត់ការសំអាតប្រាក់ ដែលចែងពីផលដែលបានមកពីឧក្រិដ្ឋកម្ម។

ប្រការដែលថាតើទ្រព្យត្រូវបានផ្តល់*យ៉ាងដូចម្តេច* គឺនឹងមិនមានលក្ខណៈចាំបាច់ឡើយ។ ឧទាហរណ៍ បុគ្គលមួយរូបដែលធ្វើសកម្មភាពជាអន្តរការី នឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញតិនៃមាត្រានេះ ប្រសិនបើខ្លួនមានបំណង ឬ ដឹងថាទ្រព្យនោះ នឹងត្រូវបានប្រើទាំងមូល ឬ មួយចំណែកសម្រាប់អំពើដែលមានចែងនៅក្នុងកថាខណ្ឌរង ៧៦(១)(ក) និង ៧៦(១)(ខ)។

ដូចគ្នានឹងបទល្មើសទាំងអស់ក្រោមច្បាប់នេះដែរ ការផ្តល់ ឬ ការប្រមូលទ្រព្យសម្រាប់ប្រើប្រាស់ក្នុងគោលបំណងដែលត្រូវបានហាមឃាត់ ត្រូវតែមានលក្ខណៈខុសច្បាប់។

ឧទាហរណ៍ ការងាររបស់នគរបាលបង្កប់ដែលពាក់ព័ន្ធនឹងការផ្ដល់ឱ្យជនសង្ស័យភេរវករម្នាក់នូវប្រាក់មួយចំនួន ដែលជាផ្នែកមួយនៃប្រតិបត្តិការដើម្បីជ្រៀតចូលក្នុងអង្គការភេរវកម្មមួយ នឹងមិនមានលក្ខណៈ "ខុសច្បាប់" ឡើយ ដោយសារប្រតិបត្តិការបែបនេះត្រូវបានអនុញ្ញាតិដោយច្បាប់ និងត្រូវបានអនុញ្ញាតជាពិសេស (សូមមើលមាត្រា ៨)។

## មាត្រា ៧៧.- ការផ្ដល់លទ្ធភាពឱ្យប្រើនូវទ្រព្យសម្បត្តិ ធនធាន ឬ សេវាកម្មដល់ភេរវករ បុគ្គល ឬ អង្គភាពដែលពាក់ព័ន្ធនឹងភេរវករ

មាត្រានេះចាត់ទុកជាបទល្មើសចំពោះការផ្ដល់លទ្ធភាពប្រើប្រាស់ទ្រព្យ ធនធាន ឬ សេវាកម្មសម្រាប់ជាអត្ថប្រយោជន៍របស់បុគ្គល ឬ អង្គភាពទាំងឡាយ ដូចមានរាយបញ្ជីនៅក្នុងកថាខណ្ឌរងទី ៧៧(១)(ក)-(គ)។

ឧទាហរណ៍នៃទ្រព្យ ឬ សេវាកម្មដែលអាចផ្ដល់អត្ថប្រយោជន៍រួមមាន ការផ្ដល់និវាទឯកទេស ផែនទី ឬ ផែនការ, ការផ្ដល់ជំរកសុវត្ថិភាព អាវុធ និងការដឹកជញ្ជូន។ ប្រការនេះអនុវត្តមាត្រា ១(ឃ) នៃ SCR 1373។

កថាខណ្ឌទី ៧៧(២) ចែងច្បាស់ថា វាជាប្រការមិនចាំបាច់ទេចំពោះការបង្ហាញភស្តុតាងនៃបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ ដែលថាតើទ្រព្យ ធនធាន ឬ សេវាកម្មដែលត្រូវបានផ្ដល់ ពិតជាត្រូវបានប្រើដើម្បីប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស។

## មាត្រា ៧៨.- ការកេណ្ឌ និងការបណ្ដុះបណ្ដាលភេរវករ

មាត្រានេះចាត់ទុកជាបទល្មើសចំពោះការចូលរួម ទោះជាតាមវិធីណាក្ដី នៅក្នុងការកេណ្ឌមនុស្សចូលក្នុងអង្គការដែលត្រូវបានបង្កើតរួចហើយ ឬ ដែលនឹងត្រូវបានបង្កើតនៅក្នុងពេលអនាគត ដើម្បីគោលបំណងភេរវកម្ម ដូចជាដើម្បីប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះជាដើម។ មាត្រានេះក៏កំណត់ជាបទល្មើសផងដែរចំពោះការបណ្ដុះបណ្ដាលមនុស្សដើម្បីគោលបំណងភេរវកម្ម។ ប្រការនេះអនុវត្តមាត្រា ២(ក) និង ៥ នៃ SCR 1373។

"គោលបំណងភេរវកម្ម" ត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៧៧(២)។ វារាប់

បញ្ចូលគោលបំណងនៃការប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ និងបទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស (ដែលត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា ៣)។

"គោលបំណងភេរវកម្ម" ក៏រាប់បញ្ចូលផងដែរនូវអំពើមួយដែលមានបំណងបណ្តាលឱ្យស្លាប់ ឬ មានរបួសរាងកាយធ្ងន់ធ្ងរ ដែលនៅក្នុងនោះគោលបំណងនៃសកម្មភាពនោះគឺដើម្បីគំរាមកំហែងប្រជាជនមួយក្រុម ឬ បង្ខំភាគីទីបីឱ្យធ្វើ ឬ មិនឱ្យធ្វើអំពើណាមួយ។ ប្រការដែលថាតើជននេះបណ្តាលឱ្យស្លាប់ ឬ មានរបួសធ្ងន់ធ្ងរ មានគោលបំណងនេះឬទេ (នៃការគំរាមកំហែង ឬ ការបង្ខំភាគីទីបី) គប្បីត្រូវបានកំណត់ដោយគ្មានលំអៀងយោងតាមស្ថានភាពជុំវិញអំពើនោះ។

## ផ្នែកទី ២: ការបង្កក ការឃាត់ទុក និងការរឹបអូសទ្រព្យភេរវកម្ម

### មាត្រា ៧៩.- ការបង្កកទ្រព្យរបស់បុគ្គល

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១២៦៧ (SCR 1267) បង្កើតគណៈកម្មាធិការមួយ (គណៈកម្មាធិការ ១២៦៧) ដែលមានភារកិច្ចមួយក្នុងចំណោមភារកិច្ចដទៃទៀត គឺត្រូវកំណត់បុគ្គល ឬ អង្គភាពដែលជាកម្មសិទ្ធិរបស់ ឬ ដែលជាប់ពាក់ព័ន្ធនឹងក្រុមភេរវកម្ម។ ក្រោម SCR 1267 រដ្ឋទាំងឡាយត្រូវបានតម្រូវឱ្យបង្កកទ្រព្យរបស់បុគ្គល ឬ អង្គភាពណាដែលត្រូវបានរាយឈ្មោះក្នុងបញ្ជីដោយគណៈកម្មាធិការ ១២៦៧។

កថាខណ្ឌទី ៧៩(១) កំណត់ស្ថានភាពពីរដែលនៅក្នុងនោះ រដ្ឋមន្ត្រីយុត្តិធម៌អាចបញ្ជាឱ្យអគ្គព្រះរាជអាជ្ញាបង្កកទ្រព្យរបស់បុគ្គលមួយចំនួន។ កថាខណ្ឌទី ៧៩(១)(ក) ផ្តល់អំណាចឱ្យរដ្ឋមន្ត្រីយុត្តិធម៌ចេញបញ្ជាបង្កកទ្រព្យរបស់បុគ្គល ឬ អង្គភាពទាំងឡាយណាដែលត្រូវបានកំណត់ដោយគណៈកម្មាធិការ ១២៦៧។ ភ្លាមៗក្រោយពេលដែលទ្រព្យនេះត្រូវបានបង្កក វានឹងក្លាយជាបទល្មើសដែលត្រូវដោះស្រាយតាមបញ្ញត្តិនៃមាត្រា ៩០ លុះត្រាណាតែការដោះស្រាយគឺដើម្បីគោលបំណងនៃផ្នែកនេះ ឬ ត្រូវបានអនុញ្ញាតដោយតុលាការ។ ទ្រព្យដែលត្រូវបានបង្កក នឹងត្រូវស្ថិតនៅកករហូតដល់វាត្រូវបានរឹបអូសជាទ្រព្យ"កខ្វក់" (តាមបញ្ញត្តិនៃមាត្រា ៨២) ឬ ត្រូវបានបញ្ឈប់បង្កក ដោយសារ

គណៈកម្មាធិការ ១២៦៧ បានកែឡើងវិញនូវបញ្ជីបុគ្គល និងអង្គភាពដែលត្រូវបានកំណត់។

កថាខណ្ឌ ៧៩(១)(ខ) ផ្តល់អំណាចជូនរដ្ឋមន្ត្រីយុត្តិធម៌ក្នុងការបញ្ជាឱ្យបង្កកទ្រព្យរបស់ជនណាមួយដែលបានប្រព្រឹត្តបទល្មើសភេរវកម្មក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ក៏ដូចជាទ្រព្យរបស់អង្គភាពមួយដែលត្រូវបានគ្រប់គ្រងដោយជនបែបនេះ ដូចជាទ្រព្យរបស់ក្រុមហ៊ុនមួយដែលជននោះមានការគ្រប់គ្រងដោយប្រយោល ឬ ជានាយក។ ប្រការនេះមានន័យថា ទ្រព្យប្រភេទនេះមិនមែនស្ថិតនៅក្រៅជំពូកនេះដោយសារតែវាជាកម្មសិទ្ធិរបស់អង្គភាពដែលជាកម្មសិទ្ធិរបស់ជននោះ ឬ ដែលជននេះគ្រប់គ្រងឡើយ។

ទ្រព្យដែលជាកម្មសិទ្ធិរបស់ជន ឬ អង្គភាពណាមួយ ដែលធ្វើសកម្មភាពក្នុងនាម ឬ ក្រោមការបញ្ជារបស់ជនដែលប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ក៏អាចត្រូវបានបង្កកផងដែរ។

កថាខណ្ឌទី ៧៩(២) ក៏អនុញ្ញាតផងដែរឱ្យបង្កកមូលនិធិដែលបានមកពីទ្រព្យ ឧទាហរណ៍ដូចជាប្រាក់ថ្លៃឈ្នួល ឬ ប្រាក់កម្ចីដែលជាកម្មសិទ្ធិ ឬ គ្រប់គ្រងដោយជន ឬ អង្គភាពដែលមានចែងក្នុងកថាខណ្ឌទី ៧៩(១)។ ទ្រព្យនេះពុំចាំបាច់ត្រូវបានប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសភេរវកម្ម ឬ បានមកពីការប្រព្រឹត្តបទល្មើសនេះឡើយ ដើម្បីត្រូវបានបង្កក។ វាអាចគឺជាទ្រព្យណាក៏ដោយរបស់ជន ឬ អង្គភាពមួយដែលមានចែងក្នុងកថាខណ្ឌទី ៧៩(១) ដើម្បីរារាំងកុំឱ្យវាត្រូវបានប្រើប្រាស់ក្នុងសកម្មភាពភេរវកម្មបន្ថែមទៀត។

ហេតុដូច្នេះ ទ្រព្យដែលអាចត្រូវបានបង្កកតាមបញ្ញត្តិនៃមាត្រានេះ អាចជាទ្រព្យ*ណាក៏ដោយ* ពោលគឺ វាពុំចាំបាច់ជាទ្រព្យកខ្វក់ឡើយ។ ប៉ុន្តែ ទ្រព្យអាចត្រូវបានរឹបអូសជូនរដ្ឋបាន លុះត្រាណាតែតុលាការចាត់ទុកថា ទ្រព្យនេះទំនងខ្លាំងជាទ្រព្យកខ្វក់ ជាជាងទ្រព្យមិនកខ្វក់ (មាត្រា ៨២)។

កថាខណ្ឌទី ៧៩(៣) ផ្តល់សិទ្ធិសុំពិនិត្យឡើងវិញជូនដល់ជនដែលទ្រព្យរបស់ខ្លួនត្រូវបានបង្កកតាមបញ្ញតិនៃកថាខណ្ឌទី ៧៩(១) ប្រសិនបើគេអាចបង្ហាញជូនរដ្ឋមន្ត្រីយុត្តិធម៌ នូវមូលហេតុមួយនៃមូលហេតុទាំងឡាយក្នុងកថាខណ្ឌរងទី ៧៩(៣)(ក)-(ឃ)។

មូលហេតុក្រោមកថាខណ្ឌរងទី ៧៩(៣)(ក) និង ៧៩(៣)(ឃ) មានលក្ខណៈសមស្របតែនៅពេលដែលគណៈកម្មាធិការ ១២៦៧ កែប្រែបញ្ជីកំណត់បុគ្គល និងអង្គការដែលទ្រព្យរបស់បុគ្គល និងអង្គការទាំងនោះគប្បីត្រូវបានបង្កកតែប៉ុណ្ណោះ។

មូលហេតុក្រោមកថាខណ្ឌរងទី ៧៩(៣)(ខ) អាចកើតឡើងនៅពេលណាដែលជន ឬអង្គការណាមួយជួនជាចៃដន្យមានឈ្មោះដូចគ្នានឹងបុគ្គល និងអង្គការដែលត្រូវបានកំណត់ដោយគណៈកម្មាធិការ ១២៦៧ ប៉ុន្តែពុំមានការពាក់ព័ន្ធអ្វីឡើយជាមួយនឹងភេរវកម្ម។

## មាត្រា ៨០.- ការបង្កកទ្រព្យកខ្វក់

តាមបញ្ញត្តិនៃមាត្រានេះ ទ្រព្យអាចត្រូវបានបង្កកនៅពេលណាដែលតុលាការចាត់ទុកថាមានមូលហេតុសមហេតុផលនឹងសង្ស័យថា ទ្រព្យជាប់សង្ស័យនោះគឺជាទ្រព្យកខ្វក់ ឧទាហរណ៍ រថយន្តដែលត្រូវបានប្រើដើម្បីប្រព្រឹត្តបទល្មើសភេរវកម្ម។ ប្រការនេះអនុវត្តមាត្រា ៨ នៃអនុសញ្ញាហិរញ្ញប្បទាន និងមាត្រា ១(គ) នៃ SCR 1373។

មាត្រានេះ ខុសពីការបង្កកទ្រព្យដែលអាចត្រូវបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ៧៩(១)(ខ)។ មាត្រា ៧៩ ចែងពីការបង្កកទ្រព្យដែលជាប់ពាក់ព័ន្ធនឹងជន (ឬអង្គភាពដែលជាកម្មសិទ្ធិ ឬ គ្រប់គ្រងដោយជនទាំងនោះ) ដែលបានប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស។ ទ្រព្យនោះពុំចាំបាច់មានលក្ខណៈកខ្វក់ទេមុនពេលវាអាចត្រូវបានបង្កក។ ផ្ទុយទៅវិញ តាមបញ្ញត្តិនៃមាត្រានេះ គឺមានតែទ្រព្យដែលតុលាការមានមូលហេតុសមហេតុផលនឹងសង្ស័យថា ជាទ្រព្យកខ្វក់តែប៉ុណ្ណោះដែលអាចត្រូវបានបង្កក។ ប្រការនេះមានន័យថា ទ្រព្យនេះត្រូវតែជាប់ពាក់ព័ន្ធនឹងបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស។

តាមបញ្ញត្តិនៃកថាខណ្ឌ ៨០(២) តុលាការត្រូវតែលុបចោលបញ្ជាបង្កកប្រសិនបើខ្លួនចាត់ទុកថា ទ្រព្យនោះមិនមែនជាទ្រព្យកខ្វក់ទេ។ មាត្រា ៨៥ ចែងថា ជនដែលប្រឆាំងនឹងបញ្ជាបង្កកត្រូវតែបង្ហាញថាទ្រព្យនេះមិនមែនជាទ្រព្យកខ្វក់ទេ។

### មាត្រា ៨១.- ការឃាត់ទុកទ្រព្យ

តាមបញ្ញត្តិនៃមាត្រានេះ អាជ្ញាធរអនុវត្តច្បាប់ទាំងឡាយត្រូវតែដកហូតទ្រព្យកខ្វក់ភ្លាមៗ នៅពេលណាដែលខ្លួនដឹងអំពីវត្តមាននៃទ្រព្យនេះ។ បន្ទាប់មក អាជ្ញាធរទាំងនេះ ចាំបាច់ត្រូវសុំបញ្ជាដើម្បីបង្កកទ្រព្យនេះតាមបញ្ញត្តិនៃមាត្រា ៨០ ឱ្យបានឆាប់តាមដែលអាចធ្វើបាន។ ឧទាហរណ៍ ប្រសិនបើមានការសង្ស័យថាទ្រព្យនោះត្រូវបានប្រើក្នុងការប្រព្រឹត្តិបទល្មើសក្រោមច្បាប់បរទេស ដែលគឺជាអំពើ ឬ ការគេចវេសខ្លះ ឬ ទាំងអស់ ដែលប្រសិនបើកើតឡើងនៅក្នុងប្រទេសកម្ពុជា នឹងគឺជាបទល្មើសក្រោមច្បាប់នេះ នគរបាលគប្បីដកហូតទ្រព្យ ហើយបន្ទាប់មកសុំបង្កកទ្រព្យនោះ។ ប្រសិនបើតុលាការបដិសេធការបង្កកទ្រព្យនោះ ទ្រព្យនោះគប្បីត្រូវបានប្រគល់ជូនជនដែលទ្រព្យនោះត្រូវបានដកហូត។

### មាត្រា ៨២.- ការរឹបអូសទ្រព្យ

ភ្លាមៗនៅពេលដែលទ្រព្យត្រូវបានបង្កក (តាមបញ្ញត្តិនៃមាត្រា ៧៩ និងមាត្រា ៨០) ឬ ដកហូត (តាមបញ្ញត្តិនៃមាត្រា ៨១) បន្ទាប់មកបង្កក តុលាការអាចបញ្ជាឱ្យធ្វើការរឹបអូសទ្រព្យជូនរដ្ឋ ប្រសិនបើតុលាការពិនិត្យឃើញថា ទ្រព្យនោះទំនងខ្លាំងជាទ្រព្យកខ្វក់ ជាជាងទ្រព្យមិនមែនកខ្វក់។

គេគប្បីកត់សម្គាល់ថា ចំពោះទ្រព្យដែលត្រូវបានបង្កកតាមបញ្ញត្តិនៃមាត្រា ៧៩ តុលាការអាចបញ្ជាឱ្យធ្វើការរឹបអូសទ្រព្យនេះបាន លុះត្រាណាតែគេអាចបង្ហាញថា ទ្រព្យនោះគឺជាទ្រព្យកខ្វក់ បើពុំដូច្នោះទេ ទ្រព្យនោះនឹងនៅតែត្រូវបានបង្កករហូតដល់ពេលដែលមូលហេតុមួយនៃមូលហេតុនានាដែលមានចែងនៅក្នុងកថាខណ្ឌទី ៧៩(៣) អាចត្រូវបានបង្ហាញ ឬ ក្នុងករណីនៃទ្រព្យដែលត្រូវបានបង្កកតាមបញ្ញត្តិនៃកថាខណ្ឌទី ៧៩(១)(ខ) តុលាការបញ្ជាឱ្យបញ្ឈប់ការបង្កកទ្រព្យនោះ ដោយសារតុលាការយល់ឃើញថា ទ្រព្យនោះមិនមែនជាទ្រព្យកខ្វក់។

### មាត្រា ៨៣.- ការចោទប្រកាន់ ឬ ការសម្រេចដាក់ទោសដែលមិនចាំបាច់

ទ្រព្យអាចត្រូវបានដកហូត និង/ឬ រឹបអូស ទោះបីជាគ្មានជនណាមួយត្រូវបានចោទប្រកាន់ចំពោះបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស

ក្ដី ឬ មួយជនណាមួយត្រូវបានចោទប្រកាន់ ក៏ប៉ុន្តែក្រោយមកត្រូវបានសម្រេចឱ្យរួចខ្លួន។ ប្រការដែលថាទ្រព្យនេះគឺជាទ្រព្យកខ្វក់ គឺគ្រប់គ្រាន់ហើយសម្រាប់អនុញ្ញាតឱ្យដកហូត និងរឹបអូសទ្រព្យនេះ។ ប្រការនេះគឺដើម្បីធានាឱ្យបានថាប្រសិនបើជនណាមួយគេចវេស រួចពីវង្វង់ច្បាប់ ឬ ការចោទប្រកាន់ទទួលបរាជ័យដោយសារមូលហេតុបច្ចេកទេស ទ្រព្យនេះនឹងពុំអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងភេរវកម្មឡើយ។

## មាត្រា ៨៤.- ទ្រព្យបញ្ចូលគ្នា

មាត្រានេះចែងច្បាស់ថា ទ្រព្យកខ្វក់ដែលត្រូវបានដាក់បញ្ចូល ឬ លាយគ្នាជាមួយទ្រព្យដទៃទៀតដែលបានមកដោយស្របច្បាប់ (ដែលមិនមែនកខ្វក់) ក៏នៅតែត្រូវទទួលបញ្ជាតាមបញ្ញតិនៃមាត្រា ៨០ និងមាត្រា ៨២ ប៉ុន្តែបទបញ្ជាបែបនេះអាចអនុវត្តតែលើតម្លៃនៃទ្រព្យកខ្វក់ប៉ុណ្ណោះ គឺពុំលើសទេ។ ឧទាហរណ៍ ប្រសិនបើគណនីធនាគារមួយមានប្រាក់ ១០០.០០០ រៀល ហើយប្រាក់ចំនួន ៥០.០០០ រៀល ត្រូវបានប្រើក្នុងការប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ បទបញ្ជាសម្រាប់ការបង្កកទ្រព្យអាចអនុវត្តបានលើប្រាក់ចំនួន ៥០.០០០ រៀលតែប៉ុណ្ណោះ។

## មាត្រា ៨៥.- បន្ទុករបស់ជនប្រឆាំងនឹងសេចក្ដីសម្រេច

ជនដែលប្រឆាំងបទបញ្ជាបង្កក ឬ រឹបអូសទ្រព្យ (ដែលត្រូវបានធ្វើតាមបញ្ញតិនៃមាត្រា ៨០ ឬ មាត្រា ៨២) ត្រូវតែបង្ហាញតុលាការថា ទ្រព្យនោះមិនមែនជាទ្រព្យកខ្វក់ឡើយ ដើម្បីប្រឆាំងនឹងបទបញ្ជាប្រកបដោយជោគជ័យ។

## មាត្រា ៨៦.- ការទុកជាមោឃៈនូវអំពើទាំងអស់ដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការរឹបអូស ជាអាទិ៍

កថាខណ្ឌទី ៨៦(១) ធានាឱ្យបានថា ការលក់ដូរទ្រព្យដែលមានគោលបំណងគេចវេសកុំឱ្យទ្រព្យត្រូវបានបង្កក ឬ រឹបអូសអាចត្រូវបាន “ទុកជាមោឃៈ” ឬ លុបចោលដោយតុលាការ។ ឧទាហរណ៍ ប្រសិនបើរថយន្តមួយដែលត្រូវបានប្រើក្នុងការប្រព្រឹត្តបទល្មើសភេរវកម្មត្រូវបានលក់ឱ្យអ្នកទិញទៀងត្រង់ម្នាក់ ដើម្បីកុំឱ្យរថយន្តនោះត្រូវបានបង្កក តុលាការអាចទុកជាមោឃៈនូវការលក់នោះ និងបញ្ជាឱ្យសងតម្លៃទិញទៅឱ្យអ្នកទិញវិញ។

ដូចគ្នាដែរ ប្រសិនបើផ្ទះមួយដែលត្រូវបានប្រើជា "ផ្ទះសុវត្ថិភាព" នៅក្នុងការប្រព្រឹត្តបទល្មើសភេរវកម្ម ត្រូវបានផ្ទេរទៅឱ្យឈ្មោះមនុស្សម្នាក់ផ្សេងទៀត ជាការប៉ុនប៉ងគេចវេសពីបញ្ហាបង្កក ពេលនោះ តុលាការអាចទុកជាមោឃៈនូវប្រតិបត្តិការនោះ។ ប្រសិនបើបុគ្គលដែលនៅក្នុងឈ្មោះរបស់ខ្លួនត្រូវបានគេផ្ទេរផ្ទះឱ្យ គឺជាភាគីទៀងត្រង់ តុលាការអាចបញ្ជាឱ្យសងប្រាក់ដែលអ្នកទិញបានទូទាត់វិញ។

## មាត្រា ៨៧.- ការលក់ដោយរដ្ឋនូវទ្រព្យដែលបានរឹបអូស

ទ្រព្យណាដែលមិនមែនជាប្រាក់ (ឧទាហរណ៍ ផ្ទះ) ដែលត្រូវបានរឹបអូសជូនរដ្ឋតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ត្រូវតែត្រូវបានលក់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផលដែលបានមកពីការលក់នេះ បន្ថែមលើប្រាក់ដែលត្រូវបានរឹបអូស ត្រូវតែបង់ចូលក្នុងមូលនិធិអាណត្តិព្យាបាលជាតិមួយ សម្រាប់ប្រើដើម្បីគោលបំណងទាំងបីរបស់មូលនិធិ (កថាខណ្ឌ ៨៧(ក)-(គ))។ គោលបំណងទាំងនេះមានរាយតាមលំដាប់លំដោយ ដែលនៅក្នុងនោះប្រាក់នឹងត្រូវបានប្រើ ឬ បែងចែក។

## មាត្រា ៨៨.- ការតាមដាន

កថាខណ្ឌទី ៨៨(១) ផ្តល់នូវឧបករណ៍ស៊ើបអង្កេតចាំបាច់ជូនដល់អ្នកស៊ើបអង្កេត ដើម្បីគេអាចស៊ើបអង្កេតឱ្យបានសមស្របនូវបទល្មើសដែលបានកើតឡើង ក៏ដូចជាដើម្បីបញ្ឈប់សក្តានុពលបទល្មើសកុំឱ្យកើតឡើងបាន។ មាត្រានេះអនុញ្ញាតឱ្យព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរដែលត្រូវបានតែងតាំងឱ្យស៊ើបអង្កេតបទល្មើស ដែលត្រូវបានចោទប្រកាន់ក្រោមច្បាប់នេះ ដើម្បីអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតមានលទ្ធភាពចូលក្នុងប្រព័ន្ធកុំព្យូទ័រ តាមដានខ្សែទូរស័ព្ទ (ក្នុងរយៈពេលមួយមិនលើសពីពីរខែ) ពិនិត្យ និងថតចម្លងឯកសារពាក់ព័ន្ធនឹងគណនីធនាគារ និងត្រួតពិនិត្យឯកសារ ឬ សំបុត្រស្នាមតាមផ្លូវច្បាប់ដទៃទៀតដែលមានចែងក្នុងកថាខណ្ឌរង ៨៨(១)(ខ)។

មុនពេលព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរអាចផ្តល់ការអនុញ្ញាតរបស់ខ្លួនដល់អ្នកស៊ើបអង្កេត គេត្រូវតែមានមូលហេតុសមហេតុផលនឹងសង្ស័យថាគណនី ខ្សែទូរស័ព្ទ ឬ ប្រព័ន្ធកុំព្យូទ័រកំពុងត្រូវបានប្រើប្រាស់ ឬ អាចត្រូវបានប្រើប្រាស់ក្នុងពេលអនាគតដោយ

ជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្ត ឬ មានផែនការប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ។

សម្រាប់ការត្រួតពិនិត្យឯកសារ ឬ សំបុត្រស្នាម គេចាំបាច់ត្រូវមានមូលហេតុសមហេតុផលថា ឯកសារ ឬ សំបុត្រស្នាមទាំងនេះពាក់ព័ន្ធ ឬ អាចពាក់ព័ន្ធនឹងបទល្មើស ឬ ការរៀបចំផែនការបទល្មើសនៅក្នុងអនាគតក្រោមច្បាប់នេះ។

កថាខណ្ឌទី ៨៨(៤) ចាត់ទុកជាបទល្មើសចំពោះជនណាដែលដឹងដោយសារវិជ្ជាជីវៈរបស់ខ្លួនអំពីសកម្មភាពដែលកំពុងធ្វើ តាមបញ្ញត្តិនៃកថាខណ្ឌទី ៨៨(១) ហើយបន្ទាប់មកជូនដំណឹងដល់ជនដែលជាកម្មវត្ថុនៃការតាមដានថា សកម្មភាពនេះកំពុងត្រូវបានធ្វើ។ ឧទាហរណ៍ អ្នកស៊ើបអង្កេតនឹងមានពិរុទ្ធភាពចំពោះបទល្មើសតាមបញ្ញត្តិនៃមាត្រានេះ ប្រសិនបើខ្លួនបានជូនព័ត៌មាន ដល់ជនណាមួយដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះថា ខ្សែទូរស័ព្ទរបស់គេត្រូវបានតាមដាន។

## មាត្រា ៨៩.- ការសម្ងាត់វិជ្ជាជីវៈធនាគារ

មាត្រានេះធានាឱ្យបានប្រាកដថា ការសម្ងាត់វិជ្ជាជីវៈធនាគារមិនអាចត្រូវបានប្រើប្រាស់ដោយធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត ជាមូលហេតុមួយដើម្បីបដិសេធមិនផ្តល់ភស្តុតាងដែលពាក់ព័ន្ធនឹងបទល្មើសក្រោមច្បាប់នេះ។

## មាត្រា ៩០.- ការបង្ក្រាបឧបសគ្គនៃការបង្អាក់ និងការរឹបអូស

មាត្រានេះបង្កើតបទល្មើសចំពោះការលក់ដូរទ្រព្យដែលត្រូវបានបង្អាក់ ឬ ដកហូតក្រោមជំពូកនេះ។ ករណីលើកលែងគឺការលក់ដូរណាដែលត្រូវបានធ្វើឡើងដើម្បីគោលបំណងអនុវត្តលក្ខខណ្ឌក្រោមផ្នែកនេះ ឬ ដែលត្រូវបានអនុញ្ញាតដោយតុលាការ។

ហេតុដូច្នេះ ជនណាមួយដែលមានរថយន្តដែលត្រូវបានដកហូតក្រោមជំពូកនេះ គឺមានពិរុទ្ធភាពចំពោះបទល្មើស ប្រសិនបើខ្លួនលក់រថយន្តនោះទៅឱ្យជនណាមួយទៀត។ ប្រសិនបើជននោះគឺជាអ្នកទិញទៀងត្រង់ និងបានទូទាត់ថ្លៃរថយន្ត តុលាការអាចទុកជាមោឃៈនូវការលក់ដូរនោះ តាមបញ្ញត្តិនៃមាត្រា ៨៦ ហើយបញ្ជាឱ្យសងប្រាក់តាមថ្លៃទិញជូនអ្នកទិញវិញ។

ដូចគ្នានឹងបទល្មើសទាំងអស់ក្រោមច្បាប់នេះដែរ ការប្រគល់ឱ្យ ឬ ការប្រមូលទ្រព្យដើម្បីប្រើនៅក្នុងគោលបំណងហាមឃាត់មួយ ត្រូវតែខុសច្បាប់។ ឧទាហរណ៍ ការងាររបស់នគបាលក្លែងខ្លួនមួយរូបដែលពាក់ព័ន្ធនឹងការផ្តល់ឱ្យជនសង្ស័យថាជាភេរវករនូវប្រាក់មួយចំនួន ជាផ្នែកមួយនៃប្រតិបត្តិការដើម្បីជ្រៀតចូលក្នុងអង្គការភេរវកម្មមួយ មិនមែន "ខុសច្បាប់" ទេ ដែលប្រតិបត្តិការបែបនេះត្រូវបានអនុញ្ញាតដោយច្បាប់ និងត្រូវបានអនុញ្ញាតជាពិសេស (សូមមើលមាត្រា ៨)។

## ជំពូកទី ១២ ៖ បត្យាប័ន និងការជួយទៅវិញទៅមកទាក់ទងនឹងបទល្មើសភេរវកម្ម

## ផ្នែកទី ១: សេចក្តីផ្តើម

### មាត្រា ៩១.- ការបកស្រាយ

មាត្រានេះកំណត់និយមន័យ ឃ្លា និងពាក្យដែលត្រូវបានប្រើនៅក្នុងជំពូកទី ១២។

### មាត្រា ៩២ .- ពេលដែលបទល្មើសបរទេសស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ

កថាខណ្ឌទី ៩២(១) កំណត់ពេលណាដែលបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសនឹងដូចគ្នាជាមួយនឹងបទល្មើសក្រោមច្បាប់នេះ។ ភាពដូចគ្នានឹងកើតឡើងនៅពេលណាដែលអំពើ ឬ ការគេចវេសខ្លះ ឬ ទាំងអស់ដែលជាបទល្មើសបរទេស នឹងគឺជាបទល្មើសក្រោមច្បាប់នេះ ប្រសិនបើត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា។

កថាខណ្ឌរងទី ៩២(២)(ក) ចែងថាមិនជាបញ្ហាអ្វីនោះឡើយចំពោះអត្ថិភាពនៃទ្វេឧក្រិដ្ឋភាពដែលអំពើ និងការគេចវេសដែលជាបទល្មើសក្រោមច្បាប់របស់រដ្ឋផ្ញើសំណើ គឺស្ថិតនៅក្នុងប្រភេទបទល្មើសផ្សេងគ្នា ទៅនឹងបទល្មើសដូចគ្នាក្រោមច្បាប់កម្ពុជា។ វានឹងមិនថ្វីទេប្រសិនបើច្បាប់របស់រដ្ឋបរទេសកំណត់បទល្មើសដោយប្រើបច្ចេកស័ព្ទផ្សេង (កថាខណ្ឌរងទី ៩១(២)(ខ))។ ឧទាហរណ៍ រដ្ឋមួយអាចសុំការធ្វើបត្យាប័នជនណាម្នាក់ ចំពោះបទល្មើសនៃ "ការធ្វើឃាត"។ ការពិពណ៌នាអំពីអំពើរបស់ជនជាប់ចោទ (ដែលត្រូវតែភ្ជាប់មកជាមួយនឹងសំណើបត្យាប័នតាមបញ្ញត្តិនៃមាត្រា ៩៧) អាចបង្ហាញថា ជនដែល

ត្រូវបានធ្វើឃាតគឺជាជនដែលត្រូវបានការពារជាអន្តរជាតិ។ ប្រសិនបើអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា វានឹងគឺជាបទល្មើសមួយតាមបញ្ញត្តិនៃមាត្រា ៣០ នៃច្បាប់នេះ។ ដើម្បីកំណត់ថាតើបទល្មើសបរទេសដែលការធ្វើបត្យាប័នជនល្មើសត្រូវបានស្នើសុំ គឺដូចគ្នានឹងបទល្មើសក្រោមច្បាប់នេះឬទេនោះ វាមិនមែនជាបញ្ហាទេដែលថាសំណើបត្យាប័នគឺសម្រាប់បទល្មើសនៃឃាតកម្ម ជាជាងការធ្វើឃាតលើជនដែលត្រូវបានការពារជាអន្តរជាតិ។ ប្រការដែលថាបទល្មើសដូចគ្នាក្រោមច្បាប់កម្ពុជាមានចំណុចបន្ថែមលើបទល្មើបរទេសនោះ គឺមិនថ្វីទេ។

## មាត្រា ៩៣.- បទល្មើសនយោបាយ និងសារពើពន្ធ

ប្រទេសខ្លះនឹងមិនធ្វើបត្យាប័នជនណាម្នាក់ឡើយសម្រាប់បទល្មើសនយោបាយ។ អនុលោមតាម*អនុសញ្ញា និងពិធីសារនានារបស់អង្គការសហប្រជាជាតិស្តីពីភេរវកម្ម* បទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ពុំគប្បីត្រូវបានចាត់ទុកជាបទល្មើសនយោបាយឡើយសម្រាប់គោលបំណងនៃការធ្វើបត្យាប័ន និងជំនួយទៅវិញទៅមក។ ហេតុផលខាងនយោបាយរបស់ចារីគឺពុំសមស្របឡើយ។

បទល្មើសក្រោមច្បាប់នេះក៏ពុំត្រូវបានចាត់ទុកថាជាបទល្មើសសារពើពន្ធផងទេ សម្រាប់គោលបំណងនៃការធ្វើបត្យាប័ន និងជំនួយទៅវិញទៅមក។

# ផ្នែកទី ២: បត្យាប័ន

## មាត្រា ៩៤.- បត្យាប័នទៅកាន់ ឬ មកពីរដ្ឋបរទេសដែលប្រទេសកម្ពុជាមានសន្ធិសញ្ញាបត្យាប័នជាមួយ

នៅពេលដែលប្រទេសកម្ពុជាបានចុះសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋមួយទៀត បទល្មើសទាំងឡាយក្រោមច្បាប់នេះ និងបទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេសនោះ នឹងត្រូវបានចាត់ទុកជាបទល្មើសដែលបត្យាប័នអាចធ្វើទៅបានក្រោមសន្ធិសញ្ញា។

**មាត្រា ៩៥.- បញ្ជូនទៅកាន់រដ្ឋដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបញ្ជូនជាមួយ ប៉ុន្តែគឺជាភាគីមួយនៃអនុសញ្ញា ឬ ពិធីសារពាក់ព័ន្ធ**

មាត្រានេះត្រូវអនុវត្តនៅពេលណាដែលប្រទេសកម្ពុជាទទួលសំណើបញ្ជូនពីរដ្ឋមួយដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបញ្ជូនជាមួយ សំរាប់អំពើដែលកើតឡើងនៅក្នុងរដ្ឋបរទេសដែលជាបទល្មើសក្រោមច្បាប់នេះ។

ប្រសិនបើប្រទេសកម្ពុជា និងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញាឬពិធីសារណាមួយ (ដែលមានរាយបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១ នៃច្បាប់នេះ) ដែលពាក់ព័ន្ធនឹងអំពើនេះ និងដែលចែងថាអនុសញ្ញា ឬ ពិធីសារនោះអាចបង្កើតមូលដ្ឋានច្បាប់សម្រាប់បញ្ជូននោះ អនុសញ្ញា ឬ ពិធីសារនោះអាចបង្កើតមូលដ្ឋានច្បាប់សម្រាប់បញ្ជូន។ បញ្ជូននឹងមានដំណើរការអនុលោមតាមច្បាប់កម្ពុជា។

នៅពេលដែលប្រទេសកម្ពុជាមានបំណងធ្វើសំណើបញ្ជូនជូនដល់ប្រទេសមួយ ដែលប្រទេសកម្ពុជាពុំមានសន្ធិសញ្ញាបញ្ជូនជាមួយ ប៉ុន្តែដែលនៅក្នុងនោះប្រទេសទាំងពីគឺជាភាគីនៃអនុសញ្ញា ឬ ពិធីសារណាមួយ (ដែលមានរាយបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១ នៃច្បាប់នេះ) ដែលចែងថាអនុសញ្ញា ឬ ពិធីសារនោះអាចបង្កើតមូលដ្ឋានច្បាប់សម្រាប់បញ្ជូនរវាងរដ្ឋភាគីទាំងឡាយ ប្រទេសកម្ពុជាអាចផ្អែកលើអនុសញ្ញា ឬ ពិធីសារនេះដើម្បីធ្វើសំណើ។

**មាត្រា ៩៦.- បញ្ជូនទៅកាន់រដ្ឋដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបញ្ជូនជាមួយ**

តាមបញ្ញត្តិក្រោមមាត្រានេះ ប្រទេសកម្ពុជាអាចធ្វើបញ្ជូនជនណាម្នាក់ទៅកាន់រដ្ឋបរទេសមួយ ដែលខ្លួនមិនមានសន្ធិសញ្ញាបញ្ជូនជាមួយ នៅពេលដែលខ្លួនទទួលសំណើបញ្ជូនចំពោះបទល្មើសប្រឆាំងនឹងច្បាប់របស់រដ្ឋបរទេសមួយដែលស្របគ្នានឹង បទល្មើសក្រោមច្បាប់នេះ ហើយរដ្ឋដែលធ្វើសំណើនោះផ្តល់ការសន្យាថានឹងធ្វើបដិការ។

**មាត្រា ៩៧.- ការបង្ហាញឯកសារសម្រាប់សំណើសុំធ្វើបញ្ជូន**

មាត្រានេះ ចែងពីឯកសារដែលចាំបាច់ត្រូវផ្តល់ជូនដោយរដ្ឋបរទេសនៅពេលសុំធ្វើបញ្ជូន

ជនណាមួយពីប្រទេសកម្ពុជា។ សំណើនេះត្រូវតែជាលាយល័ក្ខណ៍អក្សរ និងអមមកជាមួយនូវឯកសារគ្រប់គ្រាន់ដែលពិពណ៌នាអំពីអត្តសញ្ញាណ និងទីកន្លែងប្រហាក់ប្រហែលរបស់ជនល្មើជាប់ចោទនោះ របាយការណ៍អំពីការពិត អត្ថបទច្បាប់ដែលបង្កើតបទល្មើសទោសបញ្ញត្តិ រយៈពេលកំណត់ពាក់ព័ន្ធណាមួយ និងព័ត៌មានដទៃទៀតដែលកំណត់ដោយសន្ធិសញ្ញាណាមួយដែលកម្ពុជាគឺជាភាគី។

នៅពេលណាដែលជននោះត្រូវបានតាមរកដើម្បីគោលបំណងធ្វើការចោទប្រកាន់ សំណើនោះត្រូវតែអមមកជាមួយនូវដីកាចាប់ខ្លួនមួយច្បាប់ផងដែរ។

នៅពេលណាដែលជននោះត្រូវបានតាមរកដើម្បីទទួលទោស ដែលបានកំណត់នៅក្នុងរដ្ឋបរទេស គេត្រូវផ្តល់សាលក្រមមួយច្បាប់ និងកម្រិតនៃការផ្តន្ទាទោសដែលត្រូវបានអនុវត្តរួចហើយ។

ឯកសារទាំងអស់ត្រូវតែមានចុះហត្ថលេខា និងបិទត្រាសោមជិត និងត្រូវបានបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស។

## មាត្រា ៩៨.- មូលហេតុចាំបាច់សម្រាប់បដិសេធសំណើធ្វើបត្យាប័ន

មាត្រានេះចែងអំពីមូលហេតុដែលរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបដិសេធសំណើធ្វើបត្យាប័នចំពោះបទល្មើសក្រោមច្បាប់របស់ប្រទេសធ្វើសំណើ ដែលដូចគ្នានឹងបទល្មើសក្រោមច្បាប់នេះ។ កថាខណ្ឌ ៩៨(១)(ក) និង ៩៨(១)(ខ) អនុវត្តមាត្រា "គ្មានការរើសអើង" ដែលមានចែងនៅក្នុងអនុសញ្ញា និងពិធីសារមួយចំនួនរបស់អង្គការសហប្រជាជាតិ។ ឧទាហរណ៍ រាជរដ្ឋាភិបាលកម្ពុជាអាចមានការបារម្ភថា ជននោះនឹងត្រូវបានរើសអើងនៅក្នុងការកាត់ទោស ដោយសារពូជសាសន៍ ឬ ជំនឿសាសនារបស់ខ្លួន។ មូលហេតុរបស់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ត្រូវតែមានលក្ខណៈសមស្រប និងពុំមានលក្ខណៈនយោបាយ។

កថាខណ្ឌ ៩៨(១)(គ) អនុវត្តវិធានប្រឆាំងនឹងវិធានដាក់ទោសទ្វេរដង ពោលគឺវិធានប្រឆាំងនឹងការចោទប្រកាន់ជនណាម្នាក់ដែលបានទទួលការកាត់ទោស និងផ្តន្ទាទោស ឬត្រូវបានដោះលែងរួចហើយនៅក្នុងប្រទេសកម្ពុជា ឬ នៅទីកន្លែងដទៃទៀតចំពោះបទល្មើស

តែមួយនេះ។ ជនដែលបានទទួលការផ្តន្ទាទោស អាចត្រូវបានផ្ទេរបញ្ជូនដើម្បីទទួលទោសបញ្ញត្តិនោះ។

កថាខណ្ឌទី ៩៨(២) ផ្តល់នូវមូលហេតុចាំបាច់មួយទៀតនៃការបដិសេធ នៅពេលណាដែលរាជរដ្ឋាភិបាលមានការបារម្ភថា ជននោះនឹងត្រូវគេធ្វើទារុណកម្មក្រោយពីត្រូវបានប្រគល់ខ្លួនទៅឱ្យរដ្ឋដែលធ្វើសំណើ។ ប្រការនេះគឺមានសង្គតិភាពជាមួយកាតព្វកិច្ចរបស់កម្ពុជាក្រោមមាត្រា ៣ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬ ដែលធ្វើឱ្យបាត់បង់តម្លៃជាមនុស្សរបស់អង្គការសហប្រជាជាតិ។

## មាត្រា ៩៩.- បច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន

មាត្រានេះកំណត់ឱ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើការចោទប្រកាន់ជំនួសឱ្យការធ្វើបត្យាប័នប្រសិនបើមានសេចក្តីសម្រេច ដោយមូលហេតុណាក៏ដោយថា មិនធ្វើបត្យាប័នជននោះ។ បន្ទាប់មក ជននោះត្រូវបានចោទប្រកាន់នៅក្នុងប្រទេសកម្ពុជាចំពោះបទល្មើសក្រោមច្បាប់នេះ ហាក់បីដូចជាបទល្មើសនេះបានកើតឡើងនៅក្នុងប្រទេសកម្ពុជាអញ្ចឹងដែរ។ ប្រការនេះគឺអនុលោមទៅតាមវិធាន "បត្យាប័ន ឬ ចោទប្រកាន់" ដែលមានចែងនៅក្នុងអនុសញ្ញា និងពិធីសារអង្គការសហប្រជាជាតិនានាដែលពាក់ព័ន្ធនឹងភេរវកម្ម និងគោលការណ៍ "គ្មានកន្លែងជ្រកកោនសុវត្ថិភាព" នៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣៧៣។

## មាត្រា ១០០.- បត្យាប័នដោយស្ម័គ្រចិត្ត

មាត្រានេះផ្តល់ជូនជនល្មើសដែលត្រូវចោទ នូវជម្រើសក្នុងការព្រមព្រៀង ចំពោះការធ្វើបត្យាប័នរបស់ខ្លួន ដោយពុំចាំបាច់មាននីតិវិធីបត្យាប័នផ្លូវការឡើយ។ នីតិវិធីលឿននេះមានន័យថា ជនល្មើសដែលត្រូវចោទនឹងមិនចំណាយពេលវេលាច្រើនពេកក្នុងការឃុំខ្លួននៅក្នុងប្រទេសកម្ពុជាឡើយ។

ដើម្បីឯកភាពជាផ្លូវការ ជនល្មើសដែលត្រូវចោទ ត្រូវតែផ្តល់ការយល់ព្រមជាលាយល័ក្ខណ៍អក្សរ នៅចំពោះមុខតំណាងទទួលខុសត្រូវនៃអាជ្ញាធរចោទប្រកាន់។ ជនល្មើសដែលត្រូវ

ចោទ អាចផ្តល់ការយល់ព្រមឱ្យធ្វើបត្យាប័នទៅកាន់តែរដ្ឋធ្វើសំណើប៉ុណ្ណោះចំពោះបទល្មើសដែលត្រូវបានកំណត់នៅក្នុងសំណើ។ ប៉ុន្តែ មុនពេលដែលរាជរដ្ឋាភិបាលកម្ពុជាអាចឯកភាពលើបត្យាប័នតាមបញ្ញត្តិនៃកថាខណ្ឌទី ១០០(១) រដ្ឋធ្វើសំណើត្រូវតែបានដាក់សំណើផ្លូវការសុំធ្វើបត្យាប័នជននោះ ស្របតាមផ្នែក ២ នៃជំពូកនេះ ហើយជននោះត្រូវតែត្រូវបានជូនព័ត៌មានពេញលេញអំពី ផលវិបាកនៃការផ្តល់ការយល់ព្រមរបស់ខ្លួនមុនពេលធ្វើសេចក្តីសម្រេចចិត្ត។

## មាត្រា ១០១.- ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន

មាត្រានេះផ្តល់អំណាចឱ្យអាជ្ញាធរចោទប្រកាន់ ចេញដីកាធ្វើការចាប់ខ្លួនជនណាម្នាក់ជាបណ្តោះអាសន្ន ក្រោយពីមានសំណើពីរដ្ឋបរទេសសុំឱ្យចាប់ខ្លួនជននោះ សម្រាប់បទល្មើសក្រោមច្បាប់របស់រដ្ឋនោះដែលដូចគ្នានឹងបទល្មើសក្រោមច្បាប់នេះ។ ដីកានេះ គប្បីត្រូវបានចេញតែនៅពេលណាដែលរដ្ឋធ្វើសំណើបានផ្តល់ និងសន្យាថាខ្លួននឹងផ្ញើរសំណើសុំធ្វើបត្យាប័នពេញលេញជូនដល់កម្ពុជាក្នុងរយៈពេល ៦០ ថ្ងៃ ក្រោយពេលដែលជននោះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន។ ប្រសិនបើរដ្ឋធ្វើសំណើពុំដាក់ជូនសំណើក្នុងរយៈពេលនេះទេនោះ អាជ្ញាធរចោទប្រកាន់ត្រូវតែដោះលែងជននោះពីការឃុំឃាំង។ ប៉ុន្តែ ប្រការនេះពុំរារាំងដល់ការចាប់ខ្លួនជននោះឡើងវិញទេ ប្រសិនបើគេនៅតែស្ថិតនៅក្នុងប្រទេសកម្ពុជា ហើយរដ្ឋធ្វើសំណើបានដាក់ជូនសំណើសុំធ្វើបត្យាប័នពេញលេញ។

កថាខណ្ឌទី ១០០(២) កំណត់លក្ខណៈវិនិច្ឆ័យដែលកំណត់ថាអាជ្ញាធរចោទប្រកាន់ត្រូវតែគ្មានការសង្ស័យមុនពេលចេញដីកាឃាត់ខ្លួន។

## មាត្រា ១០២.- បត្យាប័នមកពីរដ្ឋដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ

កថាខណ្ឌទី ១០១(១) ចែងពីស្ថានភាពដែលនៅក្នុងនោះ មាត្រានេះត្រូវអនុវត្ត។ កាលៈទេសៈទាំងនេះគឺនៅទីកន្លែងដែលបុគ្គលណាមួយបានប្រព្រឹត្តបទល្មើសក្រោមច្បាប់នេះ នៅក្នុងប្រទេសកម្ពុជា ឬ នៅក្រៅប្រទេសកម្ពុជា ប៉ុន្តែនៅទីកន្លែងណាដែលប្រទេសកម្ពុជាមានយុត្តាធិការក្រោមច្បាប់នេះ ឧទាហរណ៍ នៅលើអាកាសយានមួយដែលចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា។

តាមមាត្រានេះ ប្រទេសកម្ពុជាអាចស្នើសុំការធ្វើបត្យាប័នពីប្រទេសណាមួយដែលខ្លួនមិនមានសន្ធិសញ្ញាបត្យាប័ន នៅពេលណាដែលខ្លួនបានត្រៀមខ្លួនជាស្រេចនឹងផ្តល់ការសន្យាថានឹងធ្វើបដិការ។

## ផ្នែកទី ៣: ជំនួយទៅវិញទៅមក

### មាត្រា ១០៣.- សំណើរបស់រដ្ឋបរទេសចំពោះប្រទេសកម្ពុជាដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស

កថាខណ្ឌទី ១០៣(២) ចែងពីប្រភេទនៃជំនួយខាងច្បាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាតាមរយៈតុលាការរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដូចជានគរបាលជាដើម អាចផ្តល់ចម្លើយចំពោះសំណើសុំជំនួយទៅវិញទៅមកពីរដ្ឋបរទេស។ ជំនួយនេះអាចត្រូវបានផ្តល់នៅពេលណាដែលរាជរដ្ឋាភិបាលកម្ពុជាទទួលសំណើសុំជំនួយ ដើម្បីការស៊ើបអង្កេតលើបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលដូចគ្នានឹងបទល្មើសក្រោមច្បាប់នេះ ឬ ដើម្បីចំណាត់ការតុលាការចំពោះបទល្មើសនេះ។ ប្រការនេះមានន័យថា ជំនួយអាចត្រូវបានផ្តល់ចំពោះតែអំពើ ឬ ការគេចវេសណាដែលរដ្ឋបរទេសនោះមានយុត្តាធិការលើតែប៉ុណ្ណោះ។

ប្រភេទនៃជំនួយដែលមានរាយនៅក្នុងកថាខណ្ឌទី ១០៣(២) ក៏អាចត្រូវបានផ្តល់ជូនជាចម្លើយចំពោះសំណើសុំជំនួយដែលពាក់ព័ន្ធនឹងចំណាត់ការដើម្បីបង្កក ឬ ដកហូតទ្រព្យដែលស្ថិតនៅក្នុងរដ្ឋធ្វើសំណើ ឬ ដើម្បីការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងទ្រព្យកខ្វក់។ ដូចគ្នានេះដែរ ជំនួយអាចត្រូវបានផ្តល់ជាចម្លើយដល់សំណើដែលពាក់ព័ន្ធនឹងការបង្កក ឬ ការរឹបអូសទ្រព្យកខ្វក់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា។

ឧទាហរណ៍នៃជំនួយដែលអាចត្រូវបានផ្តល់ជូនរដ្ឋធ្វើសំណើ រាប់បញ្ចូលការប្រមូលចម្លើយរបស់សាក្សីចំពោះការប្រព្រឹត្តបទល្មើស ការទទួលបាននូវឯកសារធនាគារ ការរៀបចំឱ្យសាក្សីដែលបានយល់ព្រមមានវត្តមាន ដើម្បីផ្តល់ភស្តុតាងនៅក្នុងការកាត់ទោសនៅបរទេសដោយការភ្ជាប់តាមវីដេអូ ឬ ដោយសាក្សីផ្ទាល់នៅក្នុងរដ្ឋបរទេសនោះ និងដោយការផ្តល់កាសែតថតសម្លេងនៃការសន្ទនាតាមទូរស័ព្ទ ដែលត្រូវបានថតយ៉ាងស្របច្បាប់។ ជំនួយ

ក្នុងទម្រង់ដទៃទៀតរួមមាននីតិវិធីពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម ដូចជាការតាមដានមូលនិធិ ការបង្កក និងការរឹបអូសទ្រព្យ។

## មាត្រា ១០៤.- ជំនួយអាចត្រូវបានផ្តល់ជូនផ្អែកលើលក្ខខណ្ឌ

មាត្រានេះអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជា ផ្តល់ជំនួយស្របច្បាប់ជូនរដ្ឋបរទេសបាន ផ្អែកលើលក្ខខណ្ឌណាដែលខ្លួនយល់ឃើញថាសមស្របនឹងដាក់។ លក្ខខណ្ឌបែបនេះ ពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មាន ការរក្សាការសម្ងាត់នៃសំណើ និងជំនួយ ឬ អាចកំណត់ថាការធ្វើបដិការត្រូវតែបានផ្តល់មុនពេលជំនួយត្រូវបានផ្តល់ ពោលគឺ ប្រទេសកម្ពុជាអាចតម្រូវឱ្យរដ្ឋធ្វើសំណើផ្តល់ការសន្យាជាលាយល័ក្ខណ៍អក្សរថា ខ្លួននឹងផ្តល់ជំនួយក្នុងរឿងដូចគ្នានេះ ប្រសិនបើប្រទេសកម្ពុជាធ្វើសំណើដូចគ្នា។

## មាត្រា ១០៥.- មូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើសុំជំនួយ

មាត្រានេះចែងពីមូលហេតុដែលរាជរដ្ឋាភិបាលកម្ពុជា នឹងមិនផ្តល់ជំនួយ ជាចម្លើយតបចំពោះសំណើសុំជំនួយពីរដ្ឋបរទេស។ មាត្រានេះគឺដូចគ្នានឹងមាត្រា ៩៨ ដែលអនុវត្តនៅក្នុងបរិបទនៃសំណើសុំធ្វើបត្យាប័នជនណាម្នាក់។

## មាត្រា ១០៦.- វិធាននៃការសម្ងាត់ធនាគារមិនប៉ះពាល់ដល់ជំនួយទៅវិញទៅមកឡើយ

មាត្រានេះចែងច្បាស់ថា ការសម្ងាត់ធនាគារនឹងមិនត្រូវបានប្រើប្រាស់ជាមូលហេតុនៃការបដិសេធសំណើសុំជំនួយទៅវិញទៅមកឡើយ។

## មាត្រា ១០៧.- សំណើសុំផ្តល់ភស្តុតាងនៅក្នុងសវនាការនៅក្នុងរដ្ឋបរទេស

នៅពេលដែលរដ្ឋបរទេសបានស្នើសុំឱ្យប្រទេសកម្ពុជា សម្រួលដល់ការចូលរួមរបស់ជនណាមួយនៅក្នុងចំណាត់ការ ឬ ការស៊ើបអង្កេតដែលស្ថិតនៅក្នុងកថាខណ្ឌទី ១០៧(១) លក្ខខណ្ឌដែលមានចែងក្នុងមាត្រានេះត្រូវតែត្រូវបានបំពេញជាមុន។ កត្តាសំខាន់បំផុត គឺថាជននោះបានឯកភាពក្នុងការផ្តល់ភស្តុតាងនៅក្នុងរដ្ឋធ្វើសំណើ។

ប្រទេសកម្ពុជា នឹងមិនសម្រួលដល់ការចូលរួមរបស់ជនណាមួយនៅក្នុងសវនាការរបស់

រដ្ឋបរទេសឡើយ តាមបញ្ញត្តិនៃមាត្រានេះ ប្រសិនបើពុំមានមូលហេតុសមហេតុផលនឹងជឿថាជននោះអាចផ្តល់ភស្តុតាងសមស្របទៅនឹងសវនាការនេះ។

កថាខណ្ឌទី ១០៧(២) ចែងពីការសន្យាដែលរដ្ឋបរទេសធ្វើសំណើ ត្រូវតែផ្តល់មុនពេលដែលប្រទេសកម្ពុជាជួយដល់ជនណាម្នាក់ឱ្យចូលរួមក្នុងសវនាការនៅបរទេស។ ការសន្យាទាំងនេះផ្តល់ជូនជននោះនូវកិច្ចការពារមិនឱ្យរដ្ឋបរទេសប្រើឱកាសនៃវត្តមានរបស់ជននោះនៅក្នុងបូរណភាពដែនដីរបស់ខ្លួន សម្រាប់គោលបំណងផ្សេងពីគោលបំណងនៃការផ្តល់ភស្តុតាងនៅក្នុងសវនាការពាក់ព័ន្ធ។ ឧទាហរណ៍ រដ្ឋមួយមិនអាចប្រើដំណើរការនេះដើម្បីគោលបំណងមិនសមស្រប ដូចជាការបកស្រាយមិនស្របច្បាប់ជាដើមដើម្បីធ្វើការចោទប្រកាន់លើសាក្សីនេះ។

កថាខណ្ឌទី ១០៧(២)(ឃ) ចែងពីលក្ខខណ្ឌចំពោះរដ្ឋបរទេសដែលបានស្នើជនណាម្នាក់ដែលស្ថិតនៅក្នុងការឃុំខ្លួននៅក្នុងប្រទេសកម្ពុជា ឱ្យផ្តល់ភស្តុតាងនៅក្នុងសវនាការនៅបរទេស ឧទាហរណ៍ ដូចជាទណ្ឌិតដែលត្រូវបានសម្រេចឱ្យជាប់ទោស។ កាតព្វកិច្ចទាំងនេះគឺបន្ថែមលើលក្ខខណ្ឌទាំងឡាយនៅក្នុងកថាខណ្ឌទី ១០៧(២) និងឆ្លុះបញ្ចាំងនូវភាពចាំបាច់ចំពោះការបន្តឃុំខ្លួនទណ្ឌិតនៅកម្ពុជានោះ នៅក្នុងពេលដែលស្ថិតនៅក្នុងរដ្ឋបរទេស។

## មាត្រា ១០៨.- សំណើដោយប្រទេសកម្ពុជាចំពោះរដ្ឋបរទេសមួយដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការ

មាត្រានេះអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើសំណើដើម្បីសុំជំនួយទៅវិញទៅមកចំពោះរដ្ឋបរទេសពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើសក្រោមច្បាប់នេះ ដើម្បីចំណាត់ការតុលាការដែលពាក់ព័ន្ធនឹងបទល្មើសក្រោមច្បាប់នេះ ឬ ចំណាត់ការតុលាការដែលពាក់ព័ន្ធនឹងការបង្កក ឬ ការរឹបអូសទ្រព្យនៅក្នុងប្រទេសកម្ពុជា ឬ នៅក្នុងរដ្ឋបរទេសដែលជាប់ពាក់ព័ន្ធនឹងបទល្មើសនេះ។ អំណាចនេះគឺមានលក្ខណៈចាំបាច់ ដោយសារអំពើភេរវកម្មអាចពាក់ព័ន្ធនឹងការចូលរួមរបស់មនុស្សដទៃដែលស្ថិតនៅក្នុងរដ្ឋបរទេសផ្សេងៗ ដែលមានព័ត៌មានសំខាន់ៗដែលចាំបាច់សម្រាប់ការចោទប្រកាន់ប្រកបដោយជោគជ័យ។

កថាខណ្ឌទី ១០៨(៤) ចែងពីការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលខ្លួនបានស្នើសុំជនណាមួយដែលស្ថិតក្នុងការឃុំឃាំងនៅក្នុងរដ្ឋបរទេសឱ្យផ្តល់ភស្តុតាង

នៅក្នុងប្រទេសកម្ពុជា។ ការទទួលខុសត្រូវទាំងនេះគឺជាការទទួលខុសត្រូវបដិការចំពោះការទទួលខុសត្រូវរបស់រដ្ឋធ្វើសំណើ ដូចមានចែងក្នុងកថាខណ្ឌរងទី ១០៧(២)(ឃ)។

**មាត្រា ១០៩.- សហប្រតិបត្តិការអន្តរជាតិ**

មាត្រានេះចែងថាគ្មានចំណុចណាមួយក្នុងផ្នែក ២ នេះនឹងមានផលប៉ះពាល់ដល់លទ្ធភាពរបស់អាជ្ញាធរក្នុងការផ្តល់ជំនួយពាក់ព័ន្ធនឹងបទល្មើសក្រោមច្បាប់នេះ ឬ បទល្មើសដូចគ្នាក្រោមច្បាប់របស់រដ្ឋបរទេសតាមវិធីដទៃឡើយ ឧទាហរណ៍ តាមរយៈកិច្ចសហប្រតិបត្តិការក្រៅផ្លូវការរវាងនគរបាល និងនគរបាល។

**ជំពូកទី ១៣ ‿ អវសានប្បញ្ញត្តិ**

**មាត្រា ១១០.- ទំនាក់ទំនងជាមួយច្បាប់ផ្សេងទៀត**

មាត្រានេះចែងថា ច្បាប់នេះនឹងមានអាទិភាពលើច្បាប់ដទៃទៀតក្នុងករណីមានភាពមិនស្របគ្នា។ ប្រការនេះមានន័យថា បទប្បញ្ញត្តិនៃមាត្រានេះត្រូវតែអនុវត្តចំពោះអំពើភេរវកម្ម ទោះបីជាមានបទប្បញ្ញត្តិនៅក្នុងច្បាប់ផ្សេងទៀត ដែលផ្ទុយគ្នានឹងបទប្បញ្ញត្តិនៅក្នុងច្បាប់នេះ។ បទប្បញ្ញត្តិផ្សេងទៀតទាំងនោះ នៅតែមានសុពលភាព និងមានប្រសិទ្ធភាពពេញលេញក្នុងករណីទាំងឡាយណាដែលមិនស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់នេះ។

ឧទាហរណ៍ ប្រសិនបើច្បាប់ផ្សេងទៀតចែងថា បទល្មើសត្រូវតែបានចោទប្រកាន់ក្នុងរយៈពេល ១០ ឆ្នាំ (អាជ្ញាយុកាល) ចំពោះអំពើដែលបានកើតឡើង ប៉ុន្តែអំពើនេះគឺជាបទល្មើសប្រឆាំងនឹងច្បាប់នេះ អំពើនោះអាចត្រូវបានចោទប្រកាន់នៅពេលណាក៏បានដែរ តាមបញ្ញត្តិនៃមាត្រា ៩ នៃច្បាប់នេះ ទោះបីជារយៈពេល ១០ ឆ្នាំ បានកន្លងទៅហើយក្តី។ ច្បាប់ដែលបានបង្កើតអាជ្ញាយុកាលរយៈពេល ១០ ឆ្នាំ សម្រាប់ការចោទប្រកាន់នឹងនៅតែមានសុពលភាព និងអនុវត្តបានចំពោះអំពើណាដែលមិនមែនជាអំពើភេរវកម្ម ទោះបីជាមានចំណុចខ្វែងគ្នាជាមួយច្បាប់នេះក្តី។

**មាត្រា ១១១- ការអនុវត្ត**

ដោយសារសារៈសំខាន់នៃច្បាប់នេះ ច្បាប់នេះនឹងត្រូវបានប្រកាសជាការប្រញាប់។

## មាតិកា


**ជំពូកទី ១ ៊ បទប្បញ្ញត្តិទូទៅ** ១

មាត្រា ១.- គោលបំណង ១

មាត្រា ២.- ការបកស្រាយ ១

មាត្រា ៣.- និយមន័យ ២

មាត្រា ៤.- ការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ៣

មាត្រា ៥.- អ្នកផ្តើមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ៣

មាត្រា ៦.- អ្នកសមគំនិត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ៤

មាត្រា ៧.- បទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល ៥

មាត្រា ៨.- យុត្តិកម្ម ៦

មាត្រា ៩.- អាជ្ញាយុកាលនៃបទល្មើស ៦

**ជំពូកទី ២ ៊ យុត្តាធិការ** ៧

មាត្រា ១០.- យុត្តាធិការកម្ពុជាតាមបញ្ញត្តិច្បាប់នេះ ៧

មាត្រា ១១.- ការអនុវត្តច្បាប់នេះចំពោះអំពើភេរវកម្មដែលមានអ្នកចូលរួមប្រព្រឹត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ៨

**ជំពូកទី ៣ ៊ បទល្មើសដែលត្រូវបានប្រព្រឹត្តនៅលើអាកាសយាន ឬនៅក្នុងអាកាសយានដ្ឋាន** ៩

**ផ្នែកទី ១ ៊ ការបកស្រាយ** ៩

មាត្រា ១២.- ពេលអាកាសយានស្ថិតក្នុងការហោះហើរ ៩

មាត្រា ១៣.- ពេលអាកាសយានស្ថិតក្នុងសេវាកម្ម ១០

មាត្រា ១៤.- ការលើកលែងចំពោះការអនុវត្តជំពូកនេះ ១០

**ផ្នែកទី ២ ៊ បទល្មើស និងទោសបញ្ញត្តិ** ១០

មាត្រា ១៥.- ការជណ្តើមកាន់កាប់អាកាសយាន ១០

មាត្រា ១៦.- ការប្រព្រឹត្តិអំពើហិង្សាលើមនុស្សនៅលើអាកាសយានដែលស្ថិត

ក្នុងពេលហោះហើរ ១១
មាត្រា ១៧.- ការកម្ទេចអាកាសយានអាកាសយានក្នុងសេវាកម្ម ឬ ការបង្កឱ្យខូចអាកាសយានអាកាសយានក្នុងសេវាកម្ម ១១
មាត្រា ១៨.- ការដាក់ ឬ ការបង្កឱ្យមានការដាក់ឱ្យបករណ៍ ឬ សារធាតុនៅលើអាកាសយានក្នុងសេវាកម្ម ១២
មាត្រា ១៩.- ការកម្ទេច ឬ ការធ្វើឱ្យខូចខាតដល់មធ្យោបាយតម្រង់ទិសហោះហើរ ១២
មាត្រា ២០.- ការផ្តល់ព័ត៌មានមិនពិតដែលបណ្តាលឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើរ ១២
មាត្រា ២១.- ការប្រព្រឹត្តិអំពើហិង្សានៅអាកាសយានដ្ឋាន ១៣
មាត្រា ២២.- កាកម្ទេច ការធ្វើឱ្យខូចខាតដល់សម្ភារៈបរិក្ខារនៃអាកាសយានដ្ឋាន អាកាសយានមិនស្ថិតក្នុងសេវាកម្ម និងការបង្អាក់សេវាកម្ម ១៣
មាត្រា ២៣.- បទល្មើសតាមច្បាប់កម្ពុជាផ្សេងទៀតដែលត្រូវបានប្រព្រឹត្តលើអាកាសយាន ១៤

**ផ្នែកទី ៣ ~ សិទ្ធិអំណាចរបស់មេបញ្ជាការអាកាសយាន ១៤**

មាត្រា ២៤.- វិធានការដើម្បីការពារសុវត្ថិភាពនៅលើអាកាសយាន ១៤
មាត្រា ២៥.- បុគ្គលដែលត្រូវបានឃាត់ខ្លួន ១៥
មាត្រា ២៦.- ការដាក់បុគ្គលណាម្នាក់ចុះពីអាកាសយាន ១៥
មាត្រា ២៧.- ជនល្មើសលើអាកាសយាន ១៧
មាត្រា ២៨.- ការមិនទទួលខុសត្រូវចំពោះការឃាត់ខ្លួនស្របច្បាប់ ជាអាទិ៍ ១៧

**ជំពូកទី ៤ ~ បទឧក្រិដ្ឋលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ១៨**

**ផ្នែកទី ១ ~ ការបកស្រាយ ១៨**

មាត្រា ២៩.- និយមន័យ ១៨

**ផ្នែកទី ២ ~ បទល្មើស ១៨**

មាត្រា ៣០.- ឃាតកម្មលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ឬការវាយ

ប្រហារដទៃទៀតលើបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ១៨
មាត្រា ៣១.- ការចាប់ពង្រត់ ការបង្ខាំង ឬ ការបំពារបំពានលើសេរីភាពរបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ១៩
មាត្រា ៣២.- ការវាយប្រហារលើអាគារផ្លូវការ កន្លែងស្នាក់នៅឯកជន ឬ មធ្យោបាយ ធ្វើដំណើររបស់បុគ្គលដែលត្រូវបានការពារជាអន្តរជាតិ ១៩
មាត្រា ៣៣.- ការគំរាមកំហែងប្រព្រឹត្តបទល្មើសលើបុគ្គល ដែលត្រូវបានការពារជាអន្តរជាតិ ២០

**ជំពូកទី ៥ ៖ ការចាប់ចំណាប់ខ្មាំង ២០**

មាត្រា ៣៤.- ការចាប់ចំណាប់ខ្មាំង ២០

**ជំពូកទី ៦ ៖ ការការពារជារូបវន្តលើសារធាតុនុយក្លេអ៊ែរ និងការបង្ក្រាបលើអំពើភេរវកម្មនុយក្លេអ៊ែរ ២១**

**ផ្នែកទី ១: សេចក្ដីផ្ដើម ២១**

មាត្រា ៣៥.- និយមន័យ ២១
មាត្រា ៣៦.- ការអនុវត្តផ្នែកទី ២ និងផ្នែកទី ៣ នៃជំពូកនេះ ២១

**ផ្នែកទី ២: ការការពារជារូបវន្តដែលចាំបាច់សម្រាប់សារធាតុនុយក្លេអ៊ែរ ២១**

មាត្រា ៣៧.- ការកំណត់ប្រភេទសារធាតុនុយក្លេអ៊ែរ ២១
មាត្រា ៣៨.- កម្រិតនៃការការពារជារូបវន្តដែលត្រូវអនុវត្តក្នុងការដឹកជញ្ជូនសារធាតុនុយក្លេអ៊ែរជាអន្តរជាតិ ២២

**ផ្នែកទី ៣: បទល្មើសពាក់ព័ន្ធនឹងការការពារជារូបវន្តនូវសារធាតុនុយក្លេអ៊ែរ ២២**

មាត្រា ៣៩.- កិច្ចការពារជារូបវន្តសារធាតុនុយក្លេអ៊ែរ ក្នុងអំឡុងពេលដឹកជញ្ជូនជាអន្តរជាតិ ២២
មាត្រា ៤០.- ការទទួល ការកាន់កាប់ ការប្រើប្រាស់ ការផ្ទេរ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ ២២

មាត្រា ៤១.- ចោរកម្មសារធាតុនុយក្លេអ៊ែរ ២៣
មាត្រា ៤២.- ការបន្លំយកសារធាតុនុយក្លេអ៊ែរ ២៣
មាត្រា ៤៣.- ការកំហែងយកសារធាតុនុយក្លេអ៊ែរ ២៣
មាត្រា ៤៤.- ការគំរាមកំហែងប្រើសារធាតុនុយក្លេអ៊ែរ ២៣

**ផ្នែកទី ៤: ការគ្រប់គ្រងអាវុធនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ ២៤**

មាត្រា ៤៥.- ការផលិត ការប្រើប្រាស់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ គីមី និងជីវសាស្ត្រ ២៤

**ផ្នែកទី ៥: ការបង្រ្កាបអំពើភេរវកម្មនុយក្លេអ៊ែរ ២៤**

មាត្រា ៤៦.- ការកាន់កាប់ ជាអាទិ៍ នូវសារធាតុនុយក្លេអ៊ែរ ២៤
មាត្រា ៤៧.- អំពើទាំងឡាយដែលពាក់ព័ន្ធនឹងសារធាតុវិទ្យុសកម្ម គ្រឿងនុយក្លេអ៊ែរ បរិក្ខារនុយក្លេអ៊ែរ ២៥
មាត្រា ៤៨.- ការគំរាមកំហែង និងការទាមទារ ២៥

**ជំពូកទី ៧ ~ អំពើប្រឆាំងនឹងសុវត្ថិភាពនៃនាវាចរណ៍ផ្លូវសមុទ្រ ២៥**

**ផ្នែកទី ១: ការអនុវត្ត ២៥**

មាត្រា ៤៩.- ការមិនអនុវត្តជំពូកនេះ ២៥

**ផ្នែកទី ២: បទល្មើស ២៦**

មាត្រា ៥០.- ការរឹបអូស ឬ ការត្រួតត្រាលើនាវា ២៦
មាត្រា ៥១.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើនាវា ២៦
មាត្រា ៥២.- ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតនាវា ២៦
មាត្រា ៥៣.- ការដាក់ឧបករណ៍ ឬ សារធាតុលើនាវា ២៧
មាត្រា ៥៤.- ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតដល់ប្រព័ន្ធឧបករណ៍តម្រង់ទិសនាវាចរណ៍ ២៧
មាត្រា ៥៥.- ការផ្តល់ព័ត៌មានមិនពិតដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវា ២៨

មាត្រា ៥៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ ២៨
មាត្រា ៥៧.- អំពើបង្ករបួសដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ ២៨
មាត្រា ៥៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់នាវាចរណ៍ប្រកបដោយ សុវត្ថិភាពរបស់របស់នាវា ២៨

**ផ្នែកទី ៣: សិទ្ធិអំណាចរបស់មេបញ្ជាការនាវា ២៩**

មាត្រា ៥៩.- សិទ្ធិអំណាចក្នុងការប្រគល់ ជាអាទិ៍ នូវបុគ្គលណាមួយទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ២៩
មាត្រា ៦០.- ពុំមានទោសបញ្ញត្តិសម្រាប់ការឃាត់ខ្លួនស្របច្បាប់ ២៩

**ជំពូកទី ៨ ៖ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃទីតាំងអចល័ត ដែលស្ថិតនៅលើខ្ពង់រាបបាតសមុទ្រ ៣០**

**ផ្នែកទី ១: ការបកស្រាយ ៣០**

មាត្រា ៦១.- និយមន័យ ៣០

**ផ្នែកទី ២: បទល្មើស ៣០**

មាត្រា ៦២.- ការដណ្តើមកាន់កាប់ ការត្រួតត្រាលើទីតាំងអចល័ត ៣០
មាត្រា ៦៣.- ការប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹងមនុស្សនៅលើទីតាំងអចល័ត ៣១
មាត្រា ៦៤.- ការកម្ទេច ការធ្វើឱ្យខូចខាតទីតាំងអចល័ត ៣១
មាត្រា ៦៥.- ការដាក់ឧបករណ៍ ឬ សារធាតុនៅលើទីតាំងអចល័ត ៣១
មាត្រា ៦៦.- អំពើមនុស្សឃាតដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ ៣១
មាត្រា ៦៧.- អំពើបង្ករបួសដែលទាក់ទងនឹងបទល្មើសក្នុងជំពូកនេះ ៣២
មាត្រា ៦៨.- ការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពនៃទីតាំង អចល័ត ៣២

**ជំពូកទី ៩ ៖ ការដាក់សញ្ញាសម្គាល់គ្រឿងផ្ទុះផ្លាស្ទិក សម្រាប់គោលបំណងរកឃើញ ៣៣**

**ផ្នែកទី ១: ការបកស្រាយ ៣៣**

មាត្រា ៦៩.- និយមន័យ ៣៣

មាត្រា ៧០.- ការពិពណ៌នាគ្រឿងផ្ទុះ ៣៣

មាត្រា ៧១.- សារធាតុរកគ្រឿងផ្ទុះ ៣៣

**ផ្នែកទី ២: បទល្មើស** **៣៤**

មាត្រា ៧២.- ការផលិតគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ ៣៤

មាត្រា ៧៣.- ការកាន់កាប់ ការដឹកជញ្ជូន ការនាំចេញ ការនាំចូលនូវគ្រឿងផ្ទុះគ្មានសញ្ញាសម្គាល់ ៣៤

**ជំពូកទី ១០ ~ ការដាក់គ្រាប់បែកភេរវកម្ម** **៣៥**

**ផ្នែកទី ១: ការបកស្រាយ** **៣៥**

មាត្រា ៧៤.- និយមន័យ ៣៥

**ផ្នែកទី ២: បទល្មើស** **៣៥**

មាត្រា ៧៥.- ការបញ្ជូន ការដាក់ ការបាញ់ ឬ ការធ្វើឱ្យផ្ទុះគ្រឿងផ្ទុះ ឬ គ្រឿងប្រល័យនៅទីកន្លែងសាធារណៈ ជាអាទិ៍ ៣៥

**ជំពូកទី ១១ ~ ហិរញ្ញប្បទាន និងជំនួយសម្រាប់ភេរវកម្ម** **៣៦**

**ផ្នែកទី ១: បទល្មើស** **៣៦**

មាត្រា ៧៦.- ការផ្តល់ ឬ ការប្រមូលទ្រព្យសម្រាប់ប្រើប្រាស់ក្នុងអំពើភេរវកម្ម ឬ ការជួយដល់ភេរវករ ៣៦

មាត្រា ៧៧.- ការផ្តល់លទ្ធភាពឱ្យប្រើនូវទ្រព្យសម្បត្តិ ធនធាន ឬ សេវាកម្មដល់ភេរវករ ឬអង្គភាពដែលពាក់ព័ន្ធនឹងភេរវករ ៣៧

មាត្រា ៧៨.- ការកេណ្ឌ និងការបណ្តុះបណ្តាលភេរវករ ៣៧

**ផ្នែកទី ២: ការបង្កក ការឃាត់ទុក និងការរឹបអូសទ្រព្យភេរវកម្ម** **៣៨**

មាត្រា ៧៩.- ការបង្កកទ្រព្យរបស់បុគ្គល ៣៨

មាត្រា ៨០.- ការបង្កកទ្រព្យកន្លក់ ៤០

មាត្រា ៨១.- ការឃាត់ទុកទ្រព្យ ៤១

មាត្រា ៨២.- ការរឹបអូសទ្រព្យ ៤១

មាត្រា ៨៣.- ការចោទប្រកាន់ ឬ ការសម្រេចដាក់ទោសដែលមិនចាំបាច់ ៤១

មាត្រា ៨៤.- ទ្រព្យបញ្ចូលគ្នា ៤២

មាត្រា ៨៥.- បន្ទុករបស់ជនប្រឆាំងនឹងសេចក្តីសម្រេច ៤២

មាត្រា ៨៦.- ការទុកជាមោឃៈនូវអំពើទាំងអស់ដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការរឹបអូស ជាងអាទិ៍ ៤២

មាត្រា ៨៧.- ការលក់ដោយរដ្ឋនូវទ្រព្យដែលបានរឹបអូស ៤៣

មាត្រា ៨៨.- ការតាមដាន ៤៣

មាត្រា ៨៩.- ការសម្ងាត់វិជ្ជាជីវៈធនាគារ ៤៤

មាត្រា ៩០.- ការបង្ក្រាបឧបសគ្គនៃការបង្កក និងការរឹបអូស ៤៤

**ជំពូកទី ១២ - បត្យាប័ន និងជំនួយទៅវិញទៅមក ទាក់ទងនឹងបទល្មើសគេរវកម្ម ៤៥**

**ផ្នែកទី ១: សេចក្តីផ្តើម ៤៥**

មាត្រា ៩១.- ការបកស្រាយ ៤៥

មាត្រា ៩២ .- ពេលដែលបទល្មើសបរទេសស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ៤៥

មាត្រា ៩៣.- បទល្មើសនយោបាយ និងសារពើពន្ធ ៤៦

**ផ្នែកទី ២: បត្យាប័ន ៤៦**

មាត្រា ៩៤.- បត្យាប័នទៅកាន់ ឬ មកពីរដ្ឋបរទេសដែលប្រទេសកម្ពុជាមានសន្ធិសញ្ញាបត្យាប័នជាមួយ ៤៦

មាត្រា ៩៥.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ប៉ុន្តែគឺជាភាគីមួយនៃអនុសញ្ញា ឬ ពិធីសារពាក់ព័ន្ធ ៤៧

មាត្រា ៩៦.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ៤៧

មាត្រា ៩៧.- ការបង្ហាញឯកសារសម្រាប់សំណើសុំធ្វើបត្យាប័ន ៤៧

មាត្រា ៩៨.- មូលហេតុចាំបាច់សម្រាប់បដិសេធសំណើធ្វើបត្យាប័ន ៤៨
មាត្រា ៩៩.- បច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន ៤៩
មាត្រា ១០០.- បត្យាប័នដោយស្ម័គ្រចិត្ត ៤៩
មាត្រា ១០១.- ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន ៥០
មាត្រា ១០២.- បត្យាប័នមកពីរដ្ឋដែលប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ៥០

**ផ្នែកទី ៣: ជំនួយទៅវិញទៅមក ៥១**

មាត្រា ១០៣.- សំណើរបស់រដ្ឋបរទេសចំពោះព្រះរាជាណាចក្រកម្ពុជាដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស ៥១
មាត្រា ១០៤.- ជំនួយអាចត្រូវបានផ្តល់ជូនផ្អែកលើលក្ខខណ្ឌ ៥២
មាត្រា ១០៥.- មូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើសុំជំនួយ ៥២
មាត្រា ១០៦.- វិធាននៃការសម្ងាត់ធនាគារមិនប៉ះពាល់ដល់ជំនួយទៅវិញទៅមកឡើយ ៥២
មាត្រា ១០៧.- សំណើសុំផ្តល់ភស្តុតាងនៅក្នុងសវនាការនៅក្នុងរដ្ឋបរទេស ៥២
មាត្រា ១០៨.- សំណើដោយប្រទេសកម្ពុជា ចំពោះរដ្ឋបរទេសមួយដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬ ចំណាត់ការតុលាការ ៥៣
មាត្រា ១០៩.- សហប្រតិបត្តិការអន្តរជាតិ ៥៤

**ជំពូកទី ១៣ ~ អវសានប្បញ្ញត្តិ ៥៤**

មាត្រា ១១០.- ទំនាក់ទំនងជាមួយច្បាប់ផ្សេងទៀត ៥៤
មាត្រា ១១១- ការអនុវត្ត ៥៤